ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jul-2013, 13:50
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២០៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា មីរាម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

កញ្ញា សុង ឆរ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្អឹម ហេដឌ័រ** (TCE-33)

សួរដោយប្រធានអង្គជំនុំជម្រះ ផ្ដើមពី ....................................................................ទំព័រ ៦៤
សួរដោយលោក ឃីត រេយ៍ន័រ ផ្ដើមពី.......................................................................ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំ-ជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ថា ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ សម្រាប់សវនាការថ្ងៃនេះ គឺមានសាក្សីបម្រុងមួយរូប គឺសាក្សីដែលមានរហស្សនាម TCE-33។ សាក្សីរូបនេះនឹងមានវត្តមាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅពេលរសៀល។

សាក្សីរូបនេះបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានចំណងញាតិលោហិតជាមួយនឹងជនជាប់ចោទទាំងពីររូប ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នោះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។ បាទជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការធ្វើអត្ថាធិប្បាយ ឬក៏ធ្វើការកត់សម្គាល់ជំទាស់ទៅនឹងបណ្តាឯកសារគន្លឹះដែលបានដាក់បង្ហាញដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ថ្ងៃនេះ ខ្ញុំនឹងសូមបន្តនូវការពិភាក្សាអំពីរឿងព្រះរាជអាជ្ញាដាក់ឯកសារគន្លឹះបន្តទៅទៀត។ ថ្ងៃនេះខ្ញុំនឹងនិយាយអំពីមន្ទីរស-២១។

[០៩:០៦:០០]

លោកស្រី លោកចៅក្រមជាទីគោរព! ឥឡូវខ្ញុំសូមងាកមកបង្ហាញអំពីមន្ទីរស-២១វិញ។ ជាបឋមខ្ញុំសូមបញ្ជាក់ឡើងវិញពីការជំទាស់ដែលធ្វើឡើងកាលពីម្សិលមិញដោយសហភាគារបស់ខ្ញុំគឺលោក វ៉ិចទ័រ កូប៉េ។ វាមិនមានន័យអ្វីទេ ការដែលយើងកំពុងតែនិយាយនៅក្នុងសវនាការពីការបង្ហាញឯកសារតួនាទីរបស់ នួន ជា នៅមន្ទីរស-២១ ដែលនៅក្រៅវិសាលភាពនៃការជំនុំជម្រះនេះ។ អង្គជំនុំជម្រះនេះបានបដិសេធពីរលើករួចមកហើយលើសំណើររបស់សហព្រះរាជអាជ្ញាសុំបញ្ចូលស-២១នៅក្នុងវិសាល-ភាពនៃការជំនុំជម្រះនេះ។ តួនាទីរបស់លោក នួន ជា នៅស-២១ មិនមាន -- មិនមែនជាតួនាទីរបស់គាត់ដែលទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ។ វាជាតួនាទីរបស់គាត់នៅទីតាំងបទល្មើស មិនមានភស្តុតាងគ្រប់គ្រាន់នៅចំពោះមុខតុលាការនេះដើម្បីធ្វើការសន្និដ្ឋានលើប្រធានបទនេះទេ។ មានប្រធានបទជាច្រើនដែលអង្គជំនុំជម្រះនេះត្រូវស្តាប់សក្ខីកម្មដោយផ្ទាល់មាត់ដើម្បីធ្វើការសន្និដ្ឋានពីតួនាទីរបស់លោក នួន ជា នៅស-២១។

[០៩:០៧:៤១]

ឧទាហរណ៍ប្រធានតំបន់នេះរួមមានភាពអាចជឿជាក់បាន--

**ប្រធានអង្គជំនុំ៖**

ផ្អាកតិចសិនលោកមេធាវី!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន អរុណសួស្តីភាគី អស់លោក លោកស្រីទាំងអស់។ មេធាវីការពារក្តីជាថ្មីម្តងទៀត ងាកចេញពីគោលបំណងនៃធ្វើការបង្ហាញនៅក្នុងសវនាការនេះ គឺដើម្បីឲ្យឆ្លើយតបទៅនឹងឯកសារដែលបានធ្វើការដាក់បង្ហាញ។ នៅពេលនេះ មេធាវីលើកឡើងទឡ្ហីករណ៍ ថាតើស-២១ គឺជាផ្នែកមួយនៃសំណុំរឿង ឬក៏យ៉ាងណា? ហើយថាតើតម្រូវឲ្យមានការផ្តល់សក្ខីកម្មពីសាក្សីបន្តទៀតដែរ ឬទេពាក់ព័ន្ធនឹងស-២១ នេះ? ដូច្នេះគាត់មិនបានគោរពតាមគោលបំណងរបស់យើងនោះឡើយ។

ខ្ញុំយោងទៅលើកថាខណ្ឌ៨៧៧ ដល់ ៨៧៩ នៅក្នុងដីកាដំណោះស្រាយ។ កថាខណ្ឌទាំងបី គឺពាក់ព័ន្ធទៅនឹងប្រធានបទតែមួយទេ គឺទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ នួន ជា លើស-២១។ ទោះបីយ៉ាងនេះក្តី គោលបំណងនៃសវនាការរបស់យើងមិនមែនតវ៉ាអំពីវិសាលភាពនៃសំណុំរឿងនោះ

ទេ។ គឺអាចឲ្យផ្តល់ឱកាសឲ្យមេធាវីការពារក្តីឆ្លើយតបទៅនឹងឯកសារទាំងឡាយដែលបានដាក់បង្ហាញជូនអង្គជំនុំជម្រះតែប៉ុណ្ណោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅព្រះរាជអាជ្ញា។ នេះជាសេចក្តីផ្តើមមុននឹងចូលទៅដល់ការឆ្លើយតបរបស់ខ្ញុំទៅនឹងព្រះរាជអាជ្ញា ខ្ញុំត្រូវធ្វើសេចក្តីផ្តើមបន្តិចមុន ហើយបានចូលទៅដល់អង្គសេចក្តីដែលត្រូវឆ្លើយតប។ ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំបាទបន្តទៅទៀត ដើម្បីចូលដល់ក្នុង និងអង្គសេចក្តីនៃការឆ្លើយតប។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១០:១៣]

**ប្រធានអង្គជំនុំ៖**

សូមជម្រាបជូនលោកមេធាវី សុន អរុណ ថាអង្គជំនុំជម្រះបានជម្រាប និងកំណត់កាលបរិច្ឆេទនៃសវនាការច្បាស់លាស់ហើយ។ អម្បាញ់មិញនេះ គឺជាការរំឭកបញ្ជាក់ឡើងវិញ ថាផ្តល់ឱកាសជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីបន្តការធ្វើការកត់សម្គាល់អត្ថាធិប្បាយជំទាស់ទៅនឹងបណ្តាឯកសារគន្លឹះទាំងឡាយដែលបានដាក់ដោយភាគីសហព្រះរាអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់បង្ហាញនៅក្នុងអំឡុងពេលសវនាការថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣កន្លងមកនេះ គឺរំលង១សប្តាហ៍ហើយ។

ដូច្នេះ សូមលោកមេធាវីតម្រង់នូវការអត្ថាធិប្បាយ ឬការកត់សម្គាល់របស់លោកឲ្យចំប្រធានបទ និងរបៀបវារៈដែលអង្គជំនុំជម្រះបានកំណត់នេះ។ ជៀសវាងការធ្វើអត្ថាធិប្បាយផ្សេងទៀត រហូតដល់ធ្វើការតបទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ឬក៏ផ្នែកណាមួយជាដើម ដែលវាមិនសមស្របទៅនឹងការកំណត់នៃកាលវិភាគសម្រាប់ធ្វើសវនាការថ្ងៃនេះទេ។

[០៩:១១:៣៤]

**លោក សុន អរុណ៖**

ខ្ញុំហាក់ដូចជាឆ្ងល់ខ្លាំង តាំងពីម្សិលរហូតមកដល់ថ្ងៃនេះ ព្រះរាជអាជ្ញាកាលណាខ្ញុំធ្វើសេចក្តីផ្តើមបន្តិច ដើម្បីចូលទៅដល់អង្គសេចក្តីនៃការឆ្លើយតប ចេះជំទាស់ពីរឿងសេចក្តីផ្តើមរបស់ខ្ញុំ។ បើមិននិយាយពីសេចក្តីផ្តើមទេ អត់យល់ដល់អង្គសេចក្តីហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

មកពីការលើកឡើងរបស់លោកមិនត្រឹមត្រូវ មិនចំនឹងបញ្ហាដែលអង្គជំនុំជម្រះកំណត់ធ្វើការពិភាក្សានៅក្នុងអង្គសវនាការនេះ។ អង្គជំនុំជម្រះបានជម្រាបហើយ ម្សិលមិញលោកលើកជាលក្ខណៈទូទៅ។ ចំណែកឯមេធាវីសហភាតារបស់លោកបានបញ្ជាក់ថា មានឯកសារតែប្រាំទេដែលលើកក្នុងន័យថា អាចទទួលយកជាភស្តុតាងបានដែរ ឬក៏អត់? នេះជាបញ្ហា។ អ៊ីចឹង របៀបខុសគ្នារវាងការយល់នេះ សូម្បីតែលោកជាមួយសហភាតារបស់លោកក៏យល់ខុសគ្នាដែរ។ អ៊ីចឹងសូមលោកដាក់បញ្ហានៃការពិភាក្សាឲ្យចំរបៀបវារៈដែលអង្គជំនុំជម្រះកំណត់ជូនទៅ បានហើយ។

**លោក សុន អរុណ៖**

ដូច្នេះ ខ្ញុំនឹងចូលដល់ចម្លើយដែលសហព្រះរាជអាជ្ញាបានដាក់។ ភស្តុតាងរបស់សហព្រះរាជអាជ្ញាអំពីមុខងាររបស់លោក នួន ជា នៅស-២១ គឺស្ទើរតែទាំងអស់ ជាចម្លើយសារភាពនៅស-២១។ សហព្រះរាជអាជ្ញារៀបរាប់ចម្លើយសារភាពចំនួន២៦ ជាមួយនឹងចំណារដែលបង្ហាញថាចម្លើយសារភាពទាំងនេះ ត្រូវបានបញ្ជូនមកលោក នួន ជា។

[០៩:១៣:១៩]

ជាបន្ទាប់ សហព្រះរាជអាជ្ញាបង្ហាញលោក លោកស្រីចៅក្រមនូវចម្លើយសារភាពប្រាំមួយ ជាមួយចំណារដែលសហព្រះរាជអាជ្ញាបានអះអាងថា សរសេរដោយដៃ -- សរសេរដោយលោក នួន ជា។ សហព្រះរាជអាជ្ញានិយាយថា “ឯកសារទាំងនេះបញ្ជាក់ថាលោក នួន ជា មានតួនាទីនៅមន្ទីរស-២១”។

លោកស្រី លោកចៅក្រមជាទីគោរព! យើងយល់ថាឯកសារភស្តុតាងដែលបង្ហាញដោយសហព្រះរាជអាជ្ញាមិនគាំទ្រដល់ការអះអាងនេះទេ។ តាមពិតយើងស្នើសុំឲ្យពិចារណាថា ប្រសិនបើភស្តុតាងរបស់សហព្រះរាជអាជ្ញាបង្ហាញពីអ្វីមួយនោះវាបង្ហាញថា នួន ជា មិនមានតួនាទីអ្វីទាំងអស់នៅស-២១។

ដើម្បីបង្ហាញលើកចំណុចនេះ ជាបឋមខ្ញុំនឹងពិភាក្សាចម្លើយសារភាពប្រាំមួយដែលសហព្រះរាជអាជ្ញាអះអាងថាមានចំណាររបស់លោក នួន ជា។ ជាបន្ទាប់ ខ្ញុំនឹងពិភាក្សាចម្លើយសារភាពដែលគេចោទប្រកាន់ថាបញ្ជូនមកលោក នួន ជា។

ខ្ញុំសូមចាប់ផ្ដើមពិនិត្យការអះអាងរបស់សហព្រះរាជអាជ្ញា ដែលថាលោក នួន ជា បានធ្វើចំណារលើចម្លើយសារភាពប្រាំមួយរបស់ស-២១ ដោយពិនិត្យឲ្យស៊ីជម្រៅលើចម្លើយសារភាពមួយក្នុងចំណោមចម្លើយសារភាពទាំងនេះ។ ចម្លើយសារភាពមួយនេះជារបស់កម្មាភិបាលម្នាក់ឈ្មោះ សាន

*(ស៊ីក)* អ៊ាប គឺឯកសារលេខ E3/173 *(ស៊ីក)*។ អនុលោមតាមព្រះរាជអាជ្ញា ឌុច បានផ្តល់សក្ខីកម្មថា ចំណារនៅរឹមទំព័រគឺជាចំណាររបស់ នួន ជា។

[០៩:១៥:២៤]

ដើម្បីឆ្លើយនឹងសំណួរនេះ ខ្ញុំសូមបង្ហាញអង្គជំនុំជម្រះនូវឯកសារមួយគឺឯកសារ E3/359។ នៅក្នុងឯកសារនេះមានចម្លើយរបស់ ឌុច ឆ្លើយនឹងសំណួរជាលាយលក្ខណ៍អក្សរមួយចំនួន។ នេះគឺជាឯកសារដែលសហព្រះរាជអាជ្ញាអះអាងថា ឌុច កំណត់អត្តសញ្ញាណប័ណ្ណ -- (សូមទោស!) កំណត់អត្តសញ្ញាណចំណារនៅលើចម្លើយសារភាពរបស់ សាន *(ស៊ីក)* អ៊ាប ថាជារបស់ នួន ជា។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមើលឯកសារដែលមាន ERN ជាអង់គ្លេស 00434339, ជាខ្មែរ 00408224 នៅផ្នែកខាងក្រោមនៃទំព័រនោះ នៅចំណុច១១ ឌុច សរសេរអំពីចម្លើយសារភាពនោះដូចខាងក្រោម៖

“ឯកសារលេខ D43/4 នេះខ្ញុំទើបតែទទួលបានក្នុងសំណុំរឿង០០២ នេះជាឯកសាររបស់សន្តិបាល៨០១តែមួយគត់ដែលខ្ញុំបានឃើញ”។ ដូច្នេះតាមពិត ឌុច មិនដែលនិយាយថា នួន ជា ចារលើចំណារនេះទេ។ គាត់មិនដែលផ្តល់សក្ខីកម្មចំពោះអង្គហេតុនោះទេ ពីព្រោះគាត់មិនដែលឃើញឯកសារនេះនៅមុនថ្ងៃសហចៅក្រមស៊ើបអង្កេតបង្ហាញគាត់។ តែ ឌុច អាចគ្រាន់តែប្រាប់អង្គជំនុំជម្រះនេះថា តើចំណារនៅលើឯកសារនេះដូចអក្សរសរសេរដៃរបស់ នួន ជា ដូចដែលអង្គជំនុំជម្រះជ្រាប ឌុច មិនមែនជាអ្នកជំនាញនៅក្នុងអក្សរសរសេរដៃនោះទេ។ គាត់មិនអាចផ្តល់ជូនតុលាការនូវយោបល់របស់គាត់អំពីថា តើគំរូអក្សរសរសេរដៃពីរដូចគ្នាដែរឬយ៉ាងណាទេ? គាត់គ្រាន់តែអាចជម្រាបតុលាការថាតើគាត់នៅចាំ និងកំណត់អត្តសញ្ញាណអក្សរសរសេរដៃរបស់ នួន ជា។

[០៩:១៨:០៩]

លោកស្រី លោកចៅក្រម ក្នុងការបកស្រាយការអះអាងរបស់សហព្រះរាជអាជ្ញា ដែលថា ឌុច ពិតជានៅចាំអក្សរសរសេរដៃរបស់ នួន ជា យើងសូមអញ្ជើញលោកស្រី លោកចៅក្រមពិនិត្យដូចខាងក្រោម៖

ឌុច អះអាងថា គាត់បានឃើញលោក -- បានឃើញលើកចុងក្រោយ នួន ជា នៅក្នុងឆ្នាំ១៩៧៩ ឌុច ត្រូវបានយកចម្លើយដោយសហចៅក្រមស៊ើបអង្កេតជាលើកដំបូងនៅឆ្នាំ២០០៧ គឺជិត៣០ឆ្នាំក្រោយមក។

យើងស្នើសុំលោក លោកស្រីចៅក្រម ដាក់ខ្លួនរបស់លោក លោកស្រីចៅក្រម ក្នុងស្ថានភាព

របស់ ឌុច យើងស្នើសុំឲ្យសាធារណជននៅក្នុងបន្ទប់សវនាការថ្ងៃនេះ ធ្វើដូចគ្នាដែរ។ តើលោកនៅចាំអក្សរសរសេរដៃរបស់ចៅហ្វាយលោកដូចម្តេចដែរក្នុងពេល៣០ឆ្នាំក្រោយលោកបានជួបគាត់ចុងក្រោយនោះ?

ដូចដែលអង្គជំនុំជម្រះជ្រាបច្បាស់ ឌុច គឺជាសាក្សីដែលវៃឆ្លាត និងទទួលបានព័ត៌មានគ្រប់គ្រាន់គាត់សិក្សាយ៉ាងស៊ីជម្រៅក្នុងសំណុំរឿង០០១។ គាត់តាមដានដោយប្រុងប្រយ័ត្ននៅការវិវត្តន៍នានានៅជុំវិញសាលាក្តីនេះ។ លោកស្រី លោកចៅក្រម អាចដឹងថានៅដើមឆ្នាំនេះអតីតសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុងដ៍ សរសេរសៀវភៅអំពីបទពិសោធន៍របស់គាត់នៅតុលាការនេះ។

សូម្បីតែចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ រំឭកថា គាត់ជាញឹកញាប់លំបាកក្នុងការកំណត់ថាតើ ឌុច និយាយចេញពីការចងចាំ ឬថាតើគាត់--

[០៩:២០:១៧]

**ប្រធានអង្គជំនុំ៖**

ផ្អាកសិនលោកៗលោកមេធាវី!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ផេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ការបង្ហាញពីមេធាវីការពារក្តីអំពីឯកសារទាំងនេះ។ អង្គជំនុំជម្រះបានជំទាស់ឯកសារនេះរួចមកហើយទាំងស្រុង។ ដូច្នេះហើយចៅក្រមនៅ -- មេធាវីនៅពេលនេះ គឺលើកឡើងអំពីអ្វីដែលលោកចៅក្រម ឡឺម៉ុងដ៍ ដែលបានលើកឡើង។ ឯកសារនេះមិនបានទទួលយកនោះទេ ហើយក៏មិនបានដាក់បង្ហាញជូនអង្គជំនុំជម្រះផងដែរ។

[០៩:២១:០៨]

**លោក សុន អរុណ៖**

សូមស្នើទៅលោកៗប្រធាន ថាតើឲ្យខ្ញុំរំលងឃ្លាទាំងអស់ហ្នឹង ឬក៏ខ្ញុំទៅមុខទៀត ឬក៏ខ្ញុំឆ្លើយតបទៅព្រះរាជអាជ្ញា?

**ប្រធានអង្គជំនុំ៖**

នោះជាសិទ្ធិលោក បើលោកឆ្លើយតប គឺលោកឆ្លើយតប។ ជាធម្មតា គឺលោក -- អង់ជំនុំជម្រះរង់ចាំការឆ្លើយតបរបស់លោកចំពោះទៅសេចក្តីជំទាស់ ទើបអង្គជំនុំជម្រះសម្រេចសេចក្តីជាក្រោយ។

ហើយបើសិនលោកយល់ថា ការជំទាស់នោះសមស្រប លោករំលងគឺរំលងទៅ ព្រោះឯកសារនេះ គឺមិនមែនជាប្រភេទឯកសារដែលអង្គជំនុំជម្រះទទួលយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះកន្លងមកទេ ហើយក៏មិនមានការបង្ហាញនៅក្នុងបណ្ដាឯកសារទាំងឡាយដែលដាក់បង្ហាញដោយភាគីនៃក្រុមតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែរ នៅក្នុងរយៈពេលសវនាការកន្លងមក។ ជាពិសេសគឺសវនាការលើឯកសារ ការដាក់បង្ហាញឯកសារកាលពីថ្ងៃទី២៤ រហូតដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ កន្លងមក។

[០៩:២២:២០]

**លោក សុន អរុណ៖**

ខ្ញុំសូមរំលងចំពោះលោកចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុងដ៏។ ខ្ញុំនឹងបន្តទៅមុខទៀត។ ជាថ្មីម្ដងទៀត យើងស្នើសុំឲ្យលោក លោកស្រីចៅក្រមសាកល្បងគិតថាវាទំនាក់ទំនងដែរឬទេ ដែល ឌុច ពិតជានៅចាំអក្សរសរសេរដៃរបស់ នួន ជា ដូចម្ដេចៗនោះ? ៣០ឆ្នាំក្រោយពីគាត់បានឃើញអក្សររបស់លោក នួន ជា លើកចុងក្រោយនោះ។ ឬគាត់ទំនងជាទាញការសន្និដ្ឋានថា ចំណារនោះ ចំណារនៅលើចម្លើយសារភាពជារបស់ នួន ជា ពីព្រោះគាត់ត្រូវបានគេប្រាប់ច្រើនដងអំពីតួនាទីរបស់ នួន ជា នៅឆ្នាំក្រោយៗមក។

លោកស្រីលោកចៅក្រម យើងគិតថា ចម្លើយចំពោះសំណួរនេះ គឺជាក់ស្ដែង យើងគិតថាវាមិនៗទំនងទាល់តែសោះដែល ឌុច នៅចាំអក្សរសរសេរដៃរបស់ នួន ជា។ ប៉ុន្តែអង្គជំនុំជម្រះមិនចាំបាច់ផ្អែកលើមតិយោបល់របស់យើងខ្ញុំទេ។ ឌុច ខ្លួនឯងបានជម្រាបអង្គជំនុំជម្រះថា គាត់មិនអាចស្គាល់អក្សរសរសេរដៃរបស់ នួន ជា នោះទាល់តែសោះ។

គប្បីដើម្បី -- សូមទោស! ដើម្បីគាំទ្រដល់ការអះអាងនេះ ខ្ញុំសូមដាក់បង្ហាញឯកសារលេខ E3/355។ ឯកសារនេះ គឺជាកំណត់ហេតុលាយលក្ខណ៍អក្សរនៃការយកចម្លើយ ឌុច នៅក្នុងករណី ០០២។

[០៩:២៤:២៥]

កំណត់ហេតុនេះត្រូវបានធ្វើ១ថ្ងៃមុន ឌុច ឆ្លើយនឹងសំណួរជាច្រើន ដែលយើងទើបតែឃើញនៅមុននេះ។ នៅក្នុងការឆ្លើយចម្លើយនោះ ឌុច និយាយអំពីចម្លើយសារភាពដូចគ្នានេះ គឺចម្លើយរបស់ សាន អ៊ាប។ នៅលេខ ERN 00239834 ជាភាសាខ្មែរ, និង 00242874 ជាភាសាអង់គ្លេស ឌុច កត់

សម្គាល់ចំណារដែលសហព្រះរាជអាជ្ញានិយាយថា សរសេរដោយ នួន ជា។ គាត់និយាយដូចតទៅ "ខ្ញុំមិនដឹងថា អ្នកណាជាអ្នកសរសេរចំណារនេះនោះទេ ប៉ុន្តែមិនមែនជា ប៉ុល ពត នោះទេ។ អក្សរគាត់គឺស្រដៀងនឹងអក្សរខ្ញុំ ហើយសរសេរ ហើយអក្សរ សុន សេន និង វន វ៉េត ក៏ដូចគ្នាដែរ។ ប្រហែលជា នួន ជា ជាអ្នកចារ ប៉ុន្តែវាគ្រាន់ជាការប៉ាន់ស្មានរបស់ខ្ញុំ ប៉ុណ្ណោះពីព្រោះខ្ញុំមិនបានឃើញអក្សរគាត់ញឹកញាប់នោះទេ"។

លោកស្រី លោកចៅក្រម នេះគឺជាកំណត់ហេតុយកចម្លើយរបស់មនុស្សម្នាក់ដែលភស្តុតាងរបស់គាត់មិនអាចយកធ្វើជាមូលដ្ឋានសម្រាប់តុលាការនេះសន្និដ្ឋានថា នួន ជា បានចំណារលើចម្លើយសារភាពណាមួយនៅស-២១ ឡើយ។ យើងស្នើអង្គជំនុំជម្រះកត់សម្គាល់អង្គហេតុដែលថា ឌុច មានចងចាំជាក់លាក់នៃអក្សរសរសេរដៃរបស់ ប៉ុល ពត, វន វ៉េត, និង សុន សេន ប៉ុន្តែគាត់មិនអាចធ្វើការកំណត់ដោយឯករាជ្យអំពីអក្សរសរសេរដៃរបស់លោក នួន ជា បាន។ វាហាក់ដូចជាថា ឌុច មិនទម្លាប់ទទួលការណែនាំជាលាយលក្ខណ៍អក្សរពី នួន ជា ហើយគាត់ក៏មិនសូវទាក់ទងជាមួយសមាជិកជាន់ខ្ពស់ដទៃទៀតនៃកម្ពុជាប្រជាធិបតេយ្យទេ។

[០៩:២៧:០២]

នៅក្នុងឯកសារដទៃទៀតដែលសហព្រះរាជអាជ្ញានិយាយថា ឌុច បានកំណត់អត្តសញ្ញាណចំណារជាច្រើនថាជារបស់លោក នួន ជា គឺវាច្បាស់លាស់ថាពុំមានមូលហេតុពិតប្រាកដដើម្បីធ្វើការសន្និដ្ឋានបែបនេះទាល់តែសោះ។

ឧទាហរណ៍នៅក្នុងឯកសារលេខ E3/1547 ជាកំណត់ហេតុនៃការយកចម្លើយមួយផ្សេងទៀត។ ឌុច ពិភាក្សាអំពីចម្លើយសារភាពរបស់ មាឃ ទូ *(ស៊ឺក)* ហៅ កែម សម្រាប់ដើម្បីដាក់ឯកសារលើអេក្រង់ -- (សុំទោស!) ខ្ញុំសូមអានឡើងវិញត្រង់ចាប់ពីលេខ E3/1547 ជាអក្សរ ជាកំណត់ហេតុនៃការយកចម្លើយមួយផ្សេងទៀត។ ឌុច ពិភាក្សាអំពីចម្លើយសារភាពរបស់ មាឃ ទូ *(ស៊ឺក)* ហៅ កែម។ នេះគឺជាចម្លើយសារភាពមួយផ្សេងទៀតដែលបង្ហាញដោយសហព្រះរាជអាជ្ញាកាលពីសប្តាហ៍មុន។ ឯកសារ ERN ភាសាខ្មែរ 00174100, និងជាភាសាអង់គ្លេស 00771344។ ឌុច អះអាងថាបានដឹងថា នួន ជា សរសេរអក្សរចំណារ សមមិត្ត -- (សមមិត្ត វ៉ាន់) នៅគែមចម្លើយសារភាពនោះ។ តើគាត់ដឹងដោយរបៀបណា? វិធីតែមួយគត់និយាយថា គាត់ដឹងគឺថាបើសិន សុន សេន សរសេរទៅ អៀង សារី នោះ សុន សេន នឹងសរសេរថា (បងវ៉ាន់)។ ផ្ទុយពីសមមិត្ត វ៉ាន់ តែប៉ុន្មាននិនាទីក្រោយមកនៅលើ

ទំព័រដដែលនៃកំណត់ហេតុយកចម្លើយគាត់សារភាព ហើយខ្ញុំស្រង់សម្ដីគាត់។ "ខ្ញុំមិនដឹងលម្អិតអំពីរបៀបធ្វើការរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់"។

ដូចដែលយើងបានឃើញ ឌុច ក៏បានទទួលស្គាល់ថាគាត់កម្រឃើញអក្សរសរសេរដៃរបស់ នួន ជា ណាស់។ វាពិតណាស់ថាគាត់មិនដឹងរបៀបដែល នួន ជា ឬ សុន សេន ថ្លែងទៅកាន់ អៀង សារី ទេ។

[០៩:២៩:៥៦]

នៅក្នុងឯកសារបីផ្សេងៗដែលសហព្រះរាជអាជ្ញាអះអាងថា ឌុច កំណត់អត្តសញ្ញាណចំណារថាជាច្រើនរបស់ នួន ជា តែ ឌុច មិនអាចផ្ដល់ការពន្យល់អ្វីទាំងអស់ចំពោះការសន្និដ្ឋានរបស់គាត់។

ដើម្បីជាប្រតិចារិក និងប្រយោជន៍ដល់អង្គជំនុំជម្រះ ឯកសារទាំងបីនេះមានលេខ E3/1546 ជាភាសាខ្មែរ, ជាភាសាអង់គ្លេស 00173049។ ជាចម្លើយសារភាពរបស់ ម៉ុក សំអុល ហៅ ហុង។ ឯកសារលេខ E3/1548 ជាភាសាខ្មែរ 00174132, និងអង់គ្លេស 00221776 ជាចម្លើយសារភាពរបស់ សាន ពូ *(ស៊ីក)*, និងលេខ E3/1089 ជាភាសាខ្មែរ 00406602, និងអង់គ្លេស 00524161។

ចំណុចដែលច្បាស់--

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវីលោកមិនបានឲ្យលេខ ERN ជាភាសាអង់គ្លេសទេ អ៎! ជាភាសាបារាំងទេ តើវាមានលេខ ERN ជាភាសាបារាំងដែរទេ? ព្រោះភាគីពាក់ព័ន្ធហ្នឹង ទាំងចៅក្រមផងដែលគាត់ជាជនជាតិបារាំងហ្នឹង គាត់ស្ដាប់មិនបានទេ។

លោកឆ្លើយតាមក្បាលមីក្រូ ដោយបើកក្បាលមីក្រូហ្នូន!

[០៩:៣២:៣០]

**លោក សុន អរុណ៖**

សូមទោសខ្ញុំពុំមាន ERN ជាភាសាបារាំងទេ មានជាខ្មែរ និងអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតទៀត!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី ខ្ញុំគិតថាថ្ងៃនេះលោកមិនបានត្រៀមលក្ខណៈស្រួលបួល។ ដោយហេតុហ្នឹងហើយបានលោកមិនអាចរកយោងជាភាសាបារាំងបាន។ តើយើងតុលាការអាចសង្ឃឹមថា ថ្ងៃខាងមុខនេះលោកនឹងផ្តល់យោងជាភាសាបារាំងនេះឲ្យតុលាការដែរឬទេ?

**លោក សុន អរុណ៖**

ខ្ញុំសូមទោស ដោយការសរសេរខ្វះខាត ខ្ញុំនឹងបំពេញនៅពេលក្រោយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ តើ២ថ្ងៃទៀតនេះលោកអាចផ្តល់យោងជាភាសាបារាំងនេះជូនចៅក្រមបានទេ ២ថ្ងៃខាងមុខនេះ?

[០៩:៣៣:៥៩]

**លោក សុន អរុណ៖**

បាន។ ខ្ញុំសូមបន្តទៅទៀត ចំណុចមួយដែលច្បាស់នៅក្នុងឯកសារទាំងនេះ គឺថា ឌុច មិនមានការចងចាំជាក់លាក់នៃចម្លើយសារភាពទាំងនោះទេ ឬបានដឹងពិតប្រាកដអំពីចំណារនៅលើចម្លើយសារ-ភាពទាំងនោះដែរ។

លោកស្រី លោកចៅក្រម នេះជាការចោទប្រកាន់សំខាន់ណាស់មកលើលោក នួន ជា។ លោក នួន ជា តែងតែបដិសេធភស្តុតាងគាំទ្រនេះគឺចេញតែមកពីសាក្សីមួយរូបប៉ុណ្ណោះ តែដូចដែលយើងលើកមកហើយថា ចម្លើយសាររបស់សាក្សីនេះគឺមិនគួរឲ្យជឿជាក់បានទេ។ ស្ថិតក្នុងកាលៈទេសៈនេះអង្គជំនុំជម្រះគួរតែចាត់តាំងអ្នកជំនាញពិនិត្យលើសំណេរទាំងនេះមុនពេលដែលតុលាការសន្និដ្ឋានថានេះជាសំណេររបស់ នួន ជា។ ប្រសិនបើមិនធ្វើដូច្នេះទេ អង្គជំនុំជម្រះនឹងមិនអាចសម្រេចបានលើពីវិមតិ-សង្ស័យថាវាជាចំណាររបស់ នួន ជា ទេ។

[០៩:៣៥:៤៦]

លោកស្រី លោកចៅក្រម ខ្ញុំសូមបញ្ចប់ការពិភាក្សាអំពីចម្លើយសារភាពដែលសរសេរ -- ដែលសហព្រះរាជអាជ្ញាអះអាងថាមានចំណារសរសេរដោយ នួន ជា។ ពេលនេះ ខ្ញុំនឹងពិភាក្សាចម្លើយសារភាពផ្សេងទៀតដែលសហព្រះរាជអាជ្ញានិយាយថា បានបញ្ជូនមកលោក នួន ជា។

ខ្ញុំចាប់ផ្តើមដោយស្រង់សម្តីថ្មីនេះរបស់សហព្រះរាជអាជ្ញា។ នាពេលថ្មីៗ សហព្រះរាជអាជ្ញា

អាចដាក់សារណាមួយនៅអង្គជំនុំជម្រះតុលាការកំពូលអំពីដីកាបំបែកកិច្ចដំណើរការនីតិវិធី វាជាការ -- ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់យើងខ្ញុំប្រឆាំងនឹងសេចក្តីសម្រេចលើកទី២របស់អង្គជំនុំជម្រះនេះ បំបែកដីកាដំណោះស្រាយនេះ គឺជាឯកសារលេខ E284/4/3, ភាសាខ្មែរ ERN ភាសាខ្មែរ 00921840, និងជាភាសាអង់គ្លេស 00921816។ នៅកថាខណ្ឌ២១ក្នុងចម្លើយតបនោះ សហព្រះរាជអាជ្ញាព្យាយាម បង្ហាញថាលោក នួន ជា មានតួនាទីនៅស-២១។ សហព្រះរាជអាជ្ញានិយាយអំពីចម្លើយសារភាពជាច្រើន។

[០៩:៣៧:២០]

ខ្ញុំស្រង់ប្រយោគមួយពីសារណារបស់សហព្រះរាជអាជ្ញាដែលនៅក្នុងកថាខណ្ឌ២១។ “សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ចម្លើយសារភាពចំនួន២៧មានចំណារបញ្ជាក់ថា មួយច្បាប់ត្រូវបានផ្ញើទៅឲ្យលោក នួន ជា ហើយចម្លើយសារភាពស-២១ ចំនួនប្រាំមួយផ្សេងទៀតមានចំណារសរសេរដោយដៃលោក នួន ជា”។ សូមបញ្ចប់ការដកស្រង់។

លោកប្រធាន នេះជាអ្វីដែលយើងខ្ញុំចាប់អារម្មណ៍ចំពោះការដកស្រង់នេះ។ សហព្រះរាជអាជ្ញាព្យាយាមបញ្ចុះបញ្ចូលអង្គជំនុំជម្រះថា ព្រោះតែលោក នួន ជា បានឃើញចម្លើយសារភាពចំនួន៣៣។ ដូចនេះគាត់ពិតជាមានតួនាទីនៅមន្ទីរស-២១។ យើងមានសំណួរ តើចម្លើយសារភាព៣៣នេះជាអ្វី? តើវាជាចំនួនច្រើនទេ ចំនួន៣៣ ក្នុងចំណោមសារភាពប៉ុន្មាន? តើមានចម្លើយសារភាព? យើងខ្ញុំក៏យល់ស្របនឹងសហព្រះរាជអាជ្ញាថាជាការគួរឲ្យចាប់អារម្មណ៍ដែលចម្លើយសារភាពទាំង១៣នេះពាក់កណ្តាល -- ពាក់ព័ន្ធនឹងអង្គភាពយោធាមួយ។ យ៉ាងហោចណាស់ វាទំនងថាចម្លើយសារភាពទាំងនេះត្រូវបានផ្ញើទៅ នួន ជា មិនមែនព្រោះតែចម្លើយសារភាពនេះមកពីមន្ទីរស-២១ នោះទេ។ ប៉ុន្តែព្រោះចម្លើយសារភាពនេះសម្រាប់អង្គភាពយោធាមួយដែលសម្រាប់ហេតុផលខ្លះលោក នួន ជា បានចាប់អារម្មណ៍ ហើយគាត់ភ្លេចបាត់ទៅហើយ។

[០៩:៣៩:២៩]

ហើយជាការពិត សហព្រះរាជអាជ្ញាខ្លួនឯងបានប្រកាន់ជំហរនេះដោយលើកឡើងថា មូលហេតុដែលចម្លើយសារភាពនេះត្រូវបានផ្ញើទៅ នួន ជា ដោយសារតែគាត់មានតួនាទីទាក់ទងនឹងយោធា និងទាក់ទងនឹងការបោសសម្អាតអង្គភាពមួយនេះ។ នេះជាការដកស្រង់នៅទំព័រ៥៤ ប្រតិចារឹកថ្ងៃទី២៧ មិថុនា។

លោកស្រី លោកចៅក្រម ដើម្បីឲ្យបានច្បាស់ លោក នួន ជា មិនយល់ស្របនឹងការចោទប្រកាន់ពីតួនាទីរបស់គាត់ក្នុងការបោសសម្អាតអង្គភាពយោធាមួយនៅភូមិភាគកណ្តាលនោះទេ។ ក៏ប៉ុន្តែយើងខ្ញុំលើកឡើងដើម្បីទាញការចាប់អារម្មណ៍ពីអង្គជំនុំជម្រះថា សូម្បីតែសហព្រះរាជអាជ្ញាខ្លួនឯង ក៏មិនមានពន្យល់ឲ្យស៊ីសង្វាក់គ្នាពីមួយ -- ពីមូលហេតុដែលចម្លើយសារភាពទាំងនេះផ្ញើជូន នួន ជា នោះដែរ។ តើចម្លើយសារភាពទាំងនេះ ត្រូវបានផ្ញើដោយសារតែមកពីស-២១? ហើយ នួន ជា ទាក់ទងអង្គភាពយោធានៅភូមិភាគកណ្តាល ឬក៏ត្រូវបានផ្ញើសម្រាប់ហេតុផលផ្សេង? ឯកសារមិនបានបញ្ជាក់នោះទេ។ សហព្រះរាជអាជ្ញាក៏មិនដឹង ហើយអង្គជំនុំជម្រះក៏មិនអាចសម្រេចបានដែរ។

[០៩:៤១:១៥]

ខ្ញុំអស់មានអត្ថាធិប្បាយតទៅ ខ្ញុំសូមចប់ត្រឹមណេះ។ ខ្ញុំបន្តទៅនេះ ខ្ញុំសូមឲ្យលោក នួន ជា គាត់មានសេចក្តីថ្លែងការណ៍មួយ បន្ទាប់ពីខ្ញុំប្រហែលជា១ម៉ោង បើលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! លោក នួន ជា អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍តប ឬធ្វើអត្ថាធិប្បាយតបទៅនឹងបណ្តាឯកសារគន្លឹះទាំងឡាយដែលអង្គជំនុំជម្រះបានស្តាប់នូវការដាក់បង្ហាញដោយភាគីនៃលោកសហព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកន្លងមក។ សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ--

[០៩:៤២:៤៧]

*(មានបញ្ហាបច្ចេកទេស)*

[០៩:៤៦:៣៣]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅខាងផ្នែកសោតទស្សន៍ តើអាចដំណើរការបានដែរឬទេ? ឬក៏មានបញ្ហាធ្ងន់ធ្ងរយ៉ាងម៉េចលើបញ្ហាបច្ចេកទេស ដើម្បីអង្គជំនុំជម្រះសម្រេច ថាតើគួរសម្រាកសិន ឬយ៉ាងណា?

**លោក នួន ជា៖**

ខ្ញុំ នួន ជា សូមធ្វើសេចក្តីថ្លែងការណ៍ឆ្លើយតបទៅនឹងការបង្ហាញឯកសារដាក់បន្ទុករបស់ព្រះ-

រាជអាជ្ញាកាលពីថ្ងៃទី២៤ ដល់ ២៧ ខែមិថុនា ឆ្នាំ២០១៣។ តុលាការជាទីគោរព! ក្នុងរយៈពេលប៉ុន្មានថ្ងៃគឺចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា កន្លងទៅនេះ ខ្ញុំបានស្ដាប់ការបង្ហាញឯកសាររបស់លោកសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិពីបន្ទប់ឃុំឃាំងខាងក្រោមសាលាជំនុំជម្រះដោយយកចិត្តទុកដាក់។ ពេលខ្លះខ្ញុំយល់នូវអ្វីដែលលោកព្រះរាជអាជ្ញាបានលើកឡើង ហើយពេលខ្លះក៏តាមដានមិនទាន់ដែរ ដោយសារសុខភាពរបស់ខ្ញុំមិនសូវល្អ។

[០៩:៤៨:៣២]

តែទោះជាយ៉ាងនេះក្ដី ខ្ញុំបានដឹង និងយល់ថាអ្វីដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងនោះហាក់ដូចជាមិនត្រឹមត្រូវ និងឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងដែលកើតឡើងនៅក្នុងសម័យកាលនោះទេ។ ហេតុនេះហើយ ខ្ញុំសូមបំភ្លឺអង្គសវនាការឲ្យបានជ្រាបច្បាស់អំពីបញ្ហាទាំងអស់នេះ។ ក្នុងន័យនេះខ្ញុំសូមជំទាស់ទាំងស្រុងទៅនឹងខ្លឹមសារ និងទម្រង់នៃឯកសារដែលបានបង្ហាញដោយលោកសហព្រះរាជអាជ្ញាដូចតទៅនេះ៖

ជាបឋមខ្ញុំសូមឆ្លើយតប និងជម្រាបជូនអង្គសវនាការទាំងមូលអំពី៖

I. ក) ការជម្លៀប្រជាជន។ ដូចខ្ញុំបានជម្រាបជូនអង្គសវនាការរួចមកហើយកាលពីប៉ុន្មានឆ្នាំមុននេះ។ ក្រោយថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ដែលបានរស់នៅក្នុងទីក្រុងនានា ត្រូវបានជម្លៀសចេញពីទីក្រុងពិតមែន តែការជម្លៀសនេះមិនមែនជាការជម្លៀសដោយបង្ខំនោះទេ។ មានហេតុផលពីរយ៉ាងដែលថ្នាក់ដឹកនាំបានបង្ខំចិត្តធ្វើសេចក្ដីសម្រេចបែបនេះ។ ទី១ គឺដោយសារមានការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុងក្រោយរដ្ឋាភិបាល លន់ នល់ បានទទួលបរាជ័យ។ ចំណុចនេះវាជាមូលហេតុដែលអាចធ្វើឲ្យថ្នាក់ដឹកនាំ និងប្រជាជនខ្មែរជឿបានថានឹងមានយន្តហោះមកទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាជាថ្មីទៀត ជាពិសេសនៅទីក្រុងភ្នំពេញ។

[០៩:៥១:១១]

តុលាការជាទីគោរព! អ្នកណាក៏បានដឹងដែរ នៅក្នុងសម័យកាលនោះសហរដ្ឋអាមេរិកបានគាំទ្ររបប លន់ នល់ និងវៀតណាមខាងត្បូង។ ចំណែកវៀតណាមខាងជើងបានគាំទ្រកម្ពុជាប្រជាធិបតេយ្យ និងប្រឆាំងជាមួយវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក។ ហេតុនេះហើយ សហរដ្ឋអាមេរិកមើលឃើញថា វៀតណាមខាងជើង និងកម្ពុជាប្រជាធិបតេយ្យជាសត្រូវរបស់ខ្លួន។ ទើបសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើទឹកដីនៃប្រទេសកម្ពុជាអស់រាប់លានតោនក្នុងរយៈពេល៣០០យប់ ៣០០ថ្ងៃ។

ការទម្លាក់គ្រាប់បែកនេះបានបំផ្លិចបំផ្លាញ និងធ្វើឲ្យវិនាសអន្តរាយទ្រព្យសម្បត្តិ ផ្ទះសម្បែង វត្តអារាម គោក្របី និងសម្លាប់ប្រជាជនស៊ីវិលស្លូតត្រង់អស់រាប់ពាន់នាក់។

ដោយមើលឃើញវិនាសកម្មដែលនឹងអាចកើតឡើងបែបនេះជាថ្មីទៀត និងដើម្បីធានាឲ្យបាននូវសន្តិសុខ និងសុវត្ថិភាពរបស់ប្រជាជន ទើបថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ ជាពិសេស ប៉ុល ពត បានសម្រេចចិត្តជម្លៀសប្រជាជនចេញពីទីក្រុង។

ហេតុផលមួយទៀតគឺថា ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលអស់ជាង៥ឆ្នាំមកហើយ។ តាមរយៈសង្គ្រាមនេះ ប្រជា -- ប្រទេសកម្ពុជាបានជួបប្រទះបញ្ហាប្រឈមជាច្រើន រួមទាំងស្បៀងអាហារផងដែរ។ ករណីស្បៀងអាហារ វាជាបញ្ហាមួយដែលត្រូវបានដោះស្រាយដោយជាបន្ទាន់។ នៅពេលនោះ ប្រទេសកម្ពុជាក៏មិនមានជំនួយពីបរទេសដែរ។ ស្ថិតក្នុងកាលៈទេសៈបន្ទាន់បែបនេះ វាទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯង សម្រាប់ផ្គត់ផ្គង់ជីវិត ជីវភាពរស់នៅ និងកសាងប្រទេសជាតិ។

[០៩:៥៣:៥៦]

ទោះជាមានហេតុផលទាំងពីរនេះក្តី ក៏ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំ គ្មានប្រើអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ។ ប្រការនេះត្រូវបានអនុវត្តតាមរយៈការពន្យល់ប្រជាជនឲ្យបានយល់ដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់ និងការទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង។

នៅពេលនោះ ប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និងតម្រូវការចាំបាច់របស់ប្រទេសជាតិ។ ជាពិសេសប្រជាជនបានគាំទ្រ និងស្រលាញ់បដិវត្តន៍។ ដូច្នេះហើយប្រជាជនបានចាកចេញពីទីក្រុងជាបណ្តើរៗតាមការអំពាវនាវ និងការពន្យល់របស់យើង។

[០៩:៥៥:១១]

តុលាការជាទីគោរព! ខ្ញុំសូមលើកឡើងនូវឯកសារមួយចំនួនដែលមានលក្ខណៈមិនសមហេតុផលដើម្បីធ្វើជាមូលដ្ឋានសម្រាប់ឲ្យតុលាការពិចារណាក្នុងការរកយុត្តិធម៌ជូនខ្ញុំ ក៏ដូចជាជនរងគ្រោះ។

គឺ ១) ទង់បដិវត្ត។ លោកសហព្រះរាជអាជ្ញាបានលើកយកអំណះអំណាង ជាច្រើនទាក់ទងនឹងទង់បដិវត្ត ដើម្បីធ្វើជាមូលដ្ឋានដាក់បន្ទុកមកលើរូបខ្ញុំ។ តាមពិតទៅទង់បដិវត្ត នេះមិនមានការទាក់ទងអ្វី

នឹងខ្ញុំទេ។ ខ្ញុំសំអាងបែបនេះដោយហេតុថា ទង់បដិវត្តគឺជាសារនយោបាយរបស់មេដឹកនាំជាន់ខ្ពស់នៅក្នុងរបបនោះតែប៉ុណ្ណោះ។ វាមិនមែនជាអត្ថបទច្បាប់ដែលត្រូវតែអនុវត្តតាមនោះទេ។

មុនពេលទទួលបានជ័យជម្នះថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ក៏ដូចជាក្រោយពេលរំដោះ វាគឺជាសារនយោបាយដើម្បីទាក់ទាញកម្លាំងគាំទ្របក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។ ដោយហេតុថាប្រទេសកម្ពុជានៅក្នុងសម័យកាលនោះ ក្រោយពេលបញ្ចប់សង្គ្រាមផ្ទៃក្នុងភ្លាមក៏ចាប់ផ្តើមមានសង្គ្រាមឈ្លានពានពីខាងក្រៅពីសំណាក់ប្រទេសវៀតណាមបន្តទៀត។ វៀតណាមមិនឱ្យប្រទេសកម្ពុជាបានសុខសាន្តនោះទេ ពួកវាបានប្រើប្រាស់គ្រប់ល្បិចកលដើម្បីឈ្លានពាននិងផ្តួលរំលំប្រទេសកម្ពុជា។ ហេតុនេះហើយ ប៉ុល ពត ត្រូវតែបញ្ចេញសារនយោបាយនៅក្នុងទស្សនាវដ្តីនោះដើម្បីបង្ហាញឱ្យឃើញថា ការគ្រប់គ្រងរបស់ខ្លួនរឹងមាំ និងខ្លាំងក្លា។ តាមពិតទៅភាគច្រើននៃព័ត៌មានទាំងនោះ គឺមិនត្រឹមត្រូវទេ។

[០៩:៥៧:៤៣]

បើយើងពិនិត្យឱ្យបានច្បាស់នៅក្នុងទស្សនាវដ្តីទង់បដិវត្តនោះ យើងឃើញថា អត្ថបទភាគច្រើនដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តីនោះគឺជាសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត និងរបាយការណ៍ដែលបានមកពីតំបន់នីមួយៗទូទាំងប្រទេស។ ចំណុចនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារយោងរបស់លោកសហព្រះរាជអាជ្ញាដែលបានកត់ត្រានៅក្នុងកំណត់ហេតុសវនាការចាប់ពីថ្ងៃ២៤ ដល់ ២៧ ខែ មិថុនា ឆ្នាំ២០១៣ កន្លងទៅនេះ។

ជាក់ស្តែង ទង់បដិវត្តត្រូវបានត្រួតពិនិត្យដោយគណៈមជ្ឈិមបក្ស តែជាក់ស្តែងមានតែ ប៉ុល ពត ទេ ជាអ្នកសម្រេច និងជ្រើសរើសអត្ថបទឱ្យចុះផ្សាយ។ កិច្ចការនេះមិនមែនជាគំនិតរួមរបស់គណៈមជ្ឈិមបក្សនោះទេ។ ប៉ុល ពត មានក្រុមជំនួយការងារផ្ទាល់របស់គាត់ ដែលជាអ្នកទទួលខុសត្រូវក្នុងការសរសេរអត្ថបទ និងបោះពុម្ពផ្សាយទស្សនាវដ្តីនោះ។ ខ្ញុំចាំបានថា ដូចជាមានឈ្មោះ គឹម វុន ហៅ ឆោម ធ្វើការនៅក្នុងការងារនោះ។ នៅពេលនោះបើទោះជាសមាជិកគណៈមជ្ឈិមបក្សមើលឃើញថា មានភាពខុសឆ្គងខ្លះក៏ដោយក៏គ្មាននរណាម្នាក់ហ៊ាននិយាយរិះគន់ដែរ។ ប៉ុល ពត មានអំណាចខ្លាំងណាស់ឱ្យតែគាត់និយាយថាយ៉ាងណាវាពិតជាដូចគាត់និយាយហើយ។ ជាក់ស្តែង នៅក្នុងរបបសង្គមនិយមអ្នកដែលមានអំណាចខ្លាំងនិងសម្រេចលើជោគវាសនាប្រទេសជាតិនោះមានតែមនុស្សម្នាក់គត់គឺលេខាបក្ស។

[០៩:៥៩:៥៩]

តុលាការជាទីគោរព! ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងទៅនឹងភាពត្រឹមត្រូវនូវរាល់ឯកសារ រួមទាំងទង់

បដិវត្តដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងកន្លងទៅនេះ។ ចំណុចដែលខ្ញុំចាប់អារម្មណ៍នោះ គឺឯកសារដើមនៃឯកសារដែលលោកសហព្រះរាជអាជ្ញាបានដាក់ជូនអង្គសវនាការ។ ចំណុចនេះខ្ញុំបានស្នើសុំតុលាការឲ្យស្វែងរកឯកសារដើមតាំងពីដំបូងម្ល៉េះ តែហាក់ដូចជាគ្មានចម្លើយ និងដំណោះស្រាយអ្វី។ ខ្ញុំមិនបានយល់ដឹងច្បាស់ទេអំពីវិធានភស្តុតាង តែខ្ញុំយល់នូវអ្វីជាយុត្តិធម៌។

កន្លងទៅនេះ ឯកសារដែលបានលោកសហព្រះរាជអាជ្ញាបានបង្ហាញជូនអង្គសវនាការ ដើម្បីចោទប្រកាន់ខ្ញុំនោះ គឺសុទ្ធតែជាឯកសារចម្លង។ ប្រការនេះវាមិនមានយុត្តិធម៌សម្រាប់ខ្ញុំទេ ដោយហេតុថាគ្មាននរណាម្នាក់អាចដឹងថាតើឯកសារដែលបានបង្ហាញនោះវាជាឯកសារពិត ឬក៏ឯកសារក្លែងក្លាយ? ម្យ៉ាងទៀតប្រសិនបើតុលាការអនុញ្ញាតឲ្យប្រើឯកសារបែបនេះ ឱកាសច្រើនណាស់ដែលឯកសារទាំងនោះអាចត្រូវបានគេផ្លាស់ប្តូរ ឬកែតម្រូវបានដោយងាយ។ ពេលនោះហើយភាពយុត្តិធម៌នឹងអាចកើតឡើង ហើយការពិតក៏មិនអាចរកឃើញបានដែរ។ ដូច្នេះហើយខ្ញុំសូមច្រានចោលនូវឯកសារចម្លងទាំងអស់ដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ប្រឆាំងនឹងខ្ញុំនាពេលនេះ។

[១០:០២:១២]

២) ការដកស្រង់ឯកសារចេញពីសៀវភៅ។ តាមរយៈសវនាការនេះផងដែរ ខ្ញុំបានពិនិត្យឃើញថា អត្ថបទសៀវភៅជាច្រើនត្រូវបានលោកសហព្រះរាជអាជ្ញាលើកយកមកប្រើប្រាស់ប្រឆាំងនឹងខ្ញុំ។ ដូចជាអត្ថបទសៀវភៅរបស់លោក ហ្វីលីព ស្បត, លោក ដេវីដ ឆេនឌ័ល័រ, លោក ប៉ុងសូដ៍ ហ្វ្រង់ស្វ័រ, និងលោក ប៊ែន ឃៀរនិន ។ល។ និយាយដល់ចំណុចនេះ ខ្ញុំហាក់ដូចជាមិនយល់ទាល់តែសោះ ថាតើហេតុអ្វីបានជាលោកសហព្រះរាជអាជ្ញាប្រើប្រាស់ឯកសារបែបនេះជាឯកសារគោលប្រឆាំងនឹងរូបខ្ញុំ។ តាមពិតទៅអត្ថបទសៀវ-ភៅ បើទោះជាព័ត៌មាននៅក្នុងនោះ ពេលខ្លះជាការពិតក៏ដោយ តែវាមិនអាចមានការពិត ឬភាពត្រឹមត្រូវ១០០ភាគរយនោះទេ។

ជាទូទៅដើម្បីឲ្យអត្ថបទមួយប្រកបដោយអត្ថន័យ និងអត្ថរស អ្នកនិពន្ធត្រូវបញ្ចូលសិល្បៈវិធីរបស់ខ្លួនទៅតាមចំណង់ចំណូលចិត្តរបស់អ្នកអាន និងសង្គម ដើម្បីទាក់ទាញការចាប់អារម្មណ៍ឲ្យគេចង់មើល ចង់អានសៀវភៅរបស់ខ្លួន។ នៅពេលនោះហើយការពិតត្រូវបានបាត់បង់។

[១០:០៣:៤៥]

ខ្ញុំយល់ថា សវនាការនេះគឺពិតជាមិនមែនជាឆាកល្ខោននោះទេ វាត្រូវការហេតុផល និងភស្តុតាងមួយដ៏ត្រឹមត្រូវនិងច្បាស់លាស់ ដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី។ ម្យ៉ាងវិញទៀតបើ

យើងពិនិត្យឲ្យបានស៊ីជម្រៅ យើងឃើញថាព័ត៌មានដែលអ្នកនិពន្ធប្រមូលបានមកចុះផ្សាយនោះ គឺបានមកដោយរយៈការសម្ភាសបុគ្គលមួយចំនួន ដែលអ្នកនិពន្ធយល់ហៅថា អ្នកទាំងនោះអាចផ្តល់ព័ត៌មានដែលមានតម្លៃមកឲ្យខ្លួន។ ចំណុចនេះហើយ តើអ្នកណាម្នាក់ប៉ានអះអាងឲ្យបានច្បាស់ថា អ្វីដែលបុគ្គលនោះប្រាប់ខ្លួននោះវាជាការពិត? អ្នកនិពន្ធក៏ដូចជាអ្នកសារព័ត៌មានដែរ គាត់មិនប៉ានអះអាងថាព័ត៌មានដែលគាត់ទទួលបានពីការសម្ភាសនោះជាការពិត១០០ភាគរយនោះទេ។ គាត់ត្រឹមតែប៉ានអះអាងថា គាត់បានព័ត៌មាននោះពីឈ្មោះ ក ឬឈ្មោះ ខ តែប៉ុណ្ណោះ។

ក្រៅពីនោះ គាត់មិនប៉ាននិយាយអ្វីទៀតទេ។ ប្រសិនបើចង់ដឹងការពិតនៅក្នុងរឿងនោះ ការជួបផ្ទាល់ជាមួយជននោះដើម្បីសាកសួរព័ត៌មាន វាជាជម្រើសល្អបំផុត។ តែទោះជាយ៉ាងនេះក្តី ក៏នៅតែមានចំណុចខ្វះខាតផងដែរ។ ហេតុនេះហើយទើបសាក្សីដែលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ តម្រូវឲ្យធ្វើសម្បថ និងសួរដេញដោលបើតាមខ្ញុំចាំ។ បើមិនដូច្នោះទេ តើនរណា -- អត់ទោស! តើព័ត៌មានទាំងអស់នោះគ្មានតម្លៃ និងប្រើប្រាស់បានទេ។

[១០:០៥:៥៣]

ចំណុចសំខាន់មួយទៀតនោះ គឺអ្នកនិពន្ធដែលសរសេរអត្ថបទសៀវភៅស្ទើរតែទាំងអស់ជាជនបរទេស។ ពួកគាត់មិនចេះភាសាខ្មែរទេ។ ដូចនេះព័ត៌មានដែលគាត់ទទួលបាន គឺតាមរយៈអ្នកបកប្រែដែលជាព័ត៌មានមួយមានលក្ខណៈមិនសុក្រឹត ហើយសច្ចភាពក៏គ្មានផងដែរ។

សរុបមកព័ត៌មានដែលបានមកពីការសម្ភាសនោះ គឺសុទ្ធតែជាព័ត៌មានបានមកពីគេប្រាប់ឮ ឬឮគេមិន -- មកឮគេនិយាយតៗគ្នា។ ចំណុចនេះវាមិនខុសអ្វីពីពាក្យចចាមអារ៉ាមនោះទេ។ បើយើងប្រៀបធៀបទៅនឹងរឿងនិទានខ្មែរវិញ គឺរឿងក្អែកមួយក្អែក១០ នោះវាមិនខុសគ្នាទេ។ រឿងតូចក្លាយជាធំ ការកុហកក្លាយជាការពិត ដោយសារតែឮគេនិយាយប្រាប់។ រឿងនេះបានអប់រំមនុស្សមិនឲ្យជឿលើពាក្យចចាមអារ៉ាមចាប់ពីបុរាណមកម្ល៉េះនៅក្នុងសង្គមខ្មែរ។

[១០:០៧:១៦]

ប្រសិនបើ អង្គសវនាការយកពាក្យចចាមអារ៉ាមធ្វើជាភស្តុតាងវិញនោះ ខ្ញុំជឿថាមនុស្សក្នុងលោកនឹងជឿថាការសម្រេចសេចក្តីនេះនឹងមិនមានយុត្តិធម៌ទាល់តែសោះ។ ដូច្នេះហើយ ខ្ញុំសូមបដិសេធ និងស្នើសុំឲ្យអង្គសវនាការសម្រេចច្រានចោលនូវរាល់ភស្តុតាងដែលបានដកស្រង់ចេញពីសៀវភៅទាំងនោះដោយក្តីអនុគ្រោះ។

៣) ឯកសារប្រជុំ ឬចម្លងជូន។ ទាក់ទងនឹងចំណុចនេះ ខ្ញុំឃើញថាលោកសហព្រះរាជអាជ្ញាក៏បានលើកយកមកប្រើប្រាស់ប្រឆាំងនឹងខ្ញុំដែរ។ ការលើកឡើងភាគច្រើនគឺទាក់ទងនឹងការមានវត្តមានរបស់ខ្ញុំនៅក្នុងអង្គប្រជុំ ឬក៏ឯកសារខ្លះដាក់ថា "ចម្លងជូនអ៊ំជា ឬ នួន ជា"។

[១០:០៨:២៧]

ប្រការនេះ ខ្ញុំសូមធ្វើការកត់សម្គាល់ថា ខ្ញុំមិនបាន ខ្ញុំចាំមិនបានថា តើខ្ញុំបានចូលរួមប្រជុំជាមួយ ប៉ុល ពត ប៉ុន្មានដងទេនៅក្នុងអំឡុងពេលខ្ញុំធ្វើការជាមួយគាត់នោះ។ ខ្ញុំមានអារម្មណ៍ថាមានព័ត៌មានខ្លះអាចមិនមែនជាការពិត ឬមានចំណុចសង្ស័យ។ តែបើទោះជាបានខ្ញុំចូលរួម ក៏វាមិនប្រាកដថាខ្ញុំបានចូលរួមធ្វើសេចក្តីសម្រេចនោះទេ។ មានកិច្ចប្រជុំច្រើនណាស់ដែលមនុស្សជាច្រើនបានចូលរួម តែមិនបានធ្វើសេចក្តីសម្រេចអ្វីនោះទេ។ តែក៏មិនប៉ះពាល់ទៅនឹងសេចក្តីសម្រេចនោះដែរ។

ចំណុចនេះលោកសហព្រះរាជអាជ្ញាមិនអាចសន្និដ្ឋានបានថា ការមានវត្តមានរបស់ខ្ញុំនៅក្នុងអង្គ-ប្រជុំ គឺជាការចូលរួមធ្វើសេចក្តីសម្រេចទេ។ ដូចគ្នានេះដែរ ឯកសារមួយចំនួនបានដាក់ថា "ចម្លងជូនខ្ញុំ"។ នេះមានន័យថា ខ្ញុំមិនបានចូលរួម ឬមានអំណាចក្នុងការធ្វើសេចក្តីសម្រេចនោះទេ។ បើទោះបីដាក់ពាក្យនេះក៏ដោយ ពេលខ្លះខ្ញុំក៏មិនបានទទួលដែរ។ ហើយបើទោះបីជាខ្ញុំដឹង តើខ្ញុំអាចធ្វើអ្វីបាន? ខ្ញុំគ្មានអំណាចអ្វីទាំងអស់ ដើម្បីទប់ស្កាត់ចំពោះការអនុវត្តសេចក្តីសម្រេចទាំងនោះ។ ដូច្នេះហើយ ខ្ញុំសូមជំទាស់ទៅនឹងការប៉ុនប៉ងទាំងឡាយណាដែលយកភស្តុតាងបែបនេះ មកដាក់បន្ទុកលើរូបខ្ញុំ។

[១០:១០:២៦]

ខ. ការគ្រប់គ្រងនិងតួនាទី។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ខ្ញុំមានតួនាទីតែបីប៉ុណ្ណោះ គឺ៖ ១) អនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងមុខតំណែងនេះខ្ញុំមានតួនាទីជាអ្នកផ្សព្វផ្សាយ និងឃោសនាអប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស។ នៅពេលនោះ សមាជិកបក្សមិនមានច្រើនប៉ុន្មានទេ។ ចំពោះខ្លឹមសារនៃការផ្សព្វផ្សាយវិញ ខ្ញុំមិនដែលបានផ្សព្វផ្សាយឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ ឬមានអាកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ។

ខ្ញុំបានអប់រំឲ្យសមាជិកបក្សចេះស្រឡាញ់ប្រជាជន និងប្រទេសជាតិរបស់ខ្លួន។ ខ្ញុំមិនដែលអប់រំណែនាំសមាជិកបក្សណាម្នាក់ឲ្យធ្វើបាប កាប់សម្លាប់ បង្អត់អាហារប្រជាជន ឬប្រល័យពូជសាសន៍ម្តងណាទេ។ ការជាពិតណាស់ ខ្ញុំបានបញ្ជាក់អំពីការពង្រឹងសន្តិសុខ និងប្រឆាំងនឹងខ្មាំង។ ប្រការនេះ វាមិនចម្លែកឡើយអ្វីទេ ថ្នាក់ដឹកនាំគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកត្រូវមានតួនាទីបែបនេះ ដើម្បី

ការពារសន្តិសុខ និងប្រទេសរបស់ខ្លួន។

ឧទាហរណ៍ ថ្មីៗនេះ សហរដ្ឋអាមេរិកបានប្រកាសចាប់ខ្លួនលោក អេដវើដ ស្នូដិន យកមកផ្តន្ទាទោស ដោយហេតុថាគាត់បានប្រឆាំង និងរំលោភដល់កិច្ចការសន្តិសុខរបស់ប្រទេសអាមេរិក។

[១០:១២:៣២]

២) អនុប្រធានកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម។ ក្នុងតួនាទីនេះ ខ្ញុំបានព្យាយាមធ្វើកិច្ចការជាច្រើនដើម្បីសម្របសម្រួល និងចរចាជាមួយប្រទេសវៀតណាមក្នុងន័យបង្កើនមិត្តភាព និងសន្តិភាពជាមួយប្រទេសជិតខាង។ តែកិច្ចការនេះមិនបានសម្រេចទេ ប្រទេសវៀតណាមនៅតែមានមហិច្ឆតាធ្វើសង្គ្រាម និងឈ្លានពានប្រទេសកម្ពុជា។

៣) ប្រធានកម្មាធិការសភាតំណែងប្រជាជនកម្ពុជា។ ដូចអស់លោកស្រីជ្រាបស្រាប់ហើយ ការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាប្រទេសកុម្មុយនីស្តផ្សេងទៀតដែរ គឺមានបក្សដឹកនាំ និងរដ្ឋគ្រប់គ្រង។ ការគ្រប់គ្រងរដ្ឋនៅក្នុងសម័យកាលនោះ បានបែងចែកជាបីគឺ ១) នីតិប្រតិបត្តិ។ ២) នីតិបញ្ញត្តិ និង៣) អំណាចតុលាការ។ ចំណុចនេះ ប៉ុល ពត បានទទួលតួនាទីក្នុងនីតិប្រតិបត្តិ ចំណែករូបខ្ញុំមានតួនាទីជាប្រធានគណៈកម្មាធិការសភាតំណាងប្រជាជន។ នៅក្នុងតួនាទីនេះ ខ្ញុំទទួលខុសត្រូវក្នុងការអនុម័តច្បាប់។ នៅពេលនោះដោយសារប្រទេសកម្ពុជាទើបតែចប់សង្គ្រាម ហើយក៏មានសង្គ្រាមបន្តជាមួយវៀតណាមទៀតនោះ។ ក្នុងរយៈពេលខ្លីបែបនេះ យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើច្បាប់ច្រើននោះទេ។

[១០:១៤:៣១]

ចំពោះតួនាទីផ្សេងទៀត ខ្ញុំមិនដែលបានធ្វើនោះទេ។ ខ្ញុំសូមជំទាស់ទៅនឹងការលើកឡើងថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទី ឬក៏គណៈកម្មាធិការកិច្ចការយោធា ឬក៏មានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១ ដោយសារតែគេឆ្លើយដាក់នោះទេ។

ប៉ុល ពត គាត់មានឧបនាយករដ្ឋមន្ត្រីរបស់គាត់ គឺលោក អៀង សារី, សុន សេន និង វន វេត។ ដូចនេះវាគ្មានហេតុផលអ្វីដែល ប៉ុល ពត តែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទី ក្រៅពីឧបនាយករដ្ឋមន្ត្រីរបស់គាត់នោះទេ។ ជាការពិតណាស់ គាត់មិនអាចតែងតាំងខ្ញុំធ្វើជានាយករដ្ឋមន្ត្រីស្តីទី នៅពេលដែលគាត់អវត្តមានពីប្រទេស។

ខ្ញុំសូមអះអាងយ៉ាងឱឡារិកថា អ្វីដែលខ្ញុំបានចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺ

មានបំណងចង់រំដោះប្រទេសជាតិ និងការពារទឹកដីមិនឲ្យមានការឈ្លានពានពីប្រទេសជិតខាងដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយ។ ខ្ញុំស្រលាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានហេតុផលណាមួយធ្វើបាប ឬប្រល័យពូជសាសន៍ឯងនោះទេ។

ចុងបញ្ចប់នេះ ខ្ញុំសូមស្នើសុំតុលាការមេត្តាពិចារណារាល់សំណើរបស់ខ្ញុំ ក្នុងការច្រានចោលឯកសារនានាដែលបានបង្ហាញជូនដោយលោកសហព្រះរាជអាជ្ញា សម្រាប់ជាប្រយោជន៍នៃការពិត និងយុត្តិធម៌សម្រាប់រូបខ្ញុំដោយក្ដីអនុគ្រោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា។

[១០:១៦:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៧:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះមុននឹងសម្រាកនេះ អង្គជំនុំជម្រះសូមសួរទៅតំណាងសហព្រះរាជអាជ្ញា តើពីម្សិលមិញអង្គជំនុំជម្រះបានទទួលនូវសំណើសុំបន្ទាន់មួយរបស់តំណាងសហព្រះរាជអាជ្ញាតាមរយៈអ៊ីម៉ែលថា ខ្លួនសុំធ្វើការថ្លែងការណ៍តបដោយផ្ទាល់មាត់ទៅនឹងឯកសារ E288/4 ដែលបានដាក់ដោយខាងក្រុមមេធាវីការពារក្ដី ខៀវ សំផន។ ឯកសារហ្នឹងចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣។ តើពេលនេះលោកតំណាងសហព្រះរាជអាជ្ញាបានត្រៀមលក្ខណៈក្នុងការឆ្លើយតបហើយនៅ ហើយអាចឆ្លើយតបបាននាពេលនេះដែរ ឬទេ? ប្រសិនេះជាបាន សូមអញ្ជើញបាទ!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពភាគី អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ។ សូមថ្លែងអំណរគុណលោកប្រធានអង្គជំនុំជម្រះ ដែលឲ្យខ្ញុំលើកសេចក្ដីសន្និដ្ឋានដោយសង្ខេបពាក់ព័ន្ធទៅនឹងការដាក់ឯកសារដែលលោកចៅក្រមបានទទួលកាលពីម្សិលមិញ។ ខ្ញុំសូមនិយាយនៅពេលដំបូងនេះតែម្ដង គឺថាយើងខ្ញុំនៅខាងសហព្រះរាជអាជ្ញា មានការភ្ញាក់ផ្អើលតែម្ដងចំពោះការផ្លាស់ប្ដូរជំហរដំណាក់កាលចុងក្រោយ ជាពិសេសរបស់ក្រុមមេធាវីការពារក្ដី ជាពិសេសគឺការប្ដូរជំហររបស់ជនជាប់ចោទនេះតែម្ដង។

[១០:១៨:៤២]

ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត ដើម្បីឲ្យយល់ពីបរិបទ គឺខ្ញុំសូមគូសបញ្ជាក់សំណើសុំចំនួនប្រាំចំណុច ដែលក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើង ហើយគាត់បានជំទាស់។ ហើយទំនងចំណុចទាំងអស់នេះមានក្នុងសេចក្តីសម្រេចដែលយើងខ្ញុំបានទទួលការជូនដំណឹង។

ចំណុចទី១ គឺមាននៅក្នុងឯកសារ E288/4 កថាខណ្ឌ៧ ចំណុចទី១ នោះ គឺថាយើងខ្ញុំបានទទួលដំណឹងថា ហេតុផលចម្បងរបស់លោក ខៀវ សំផន មិនធ្វើការឆ្លើយនោះ គឺដោយសារតែអង្គជំនុំជម្រះមិនបានផ្តល់បញ្ជីសំណួរទៅតាមប្រធានបទដែលគាត់ទាមទារថា គាត់នឹងឆ្លើយតបទៅតាមប្រធានបទ បើសិនជាមានសំណួរទាំងអស់នោះ។

ចំណុចទី២ គឺខាង ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះមិនបានចេញសេចក្តីបង្គាប់ឲ្យសរសេរនៅបញ្ជីសំណួរសម្រាប់ការពិនិត្យដេញដោលគាត់ ហើយបញ្ជីនោះគឺថាគាត់គិតថាមានលក្ខណៈតិចតួចតែប៉ុណ្ណោះទៅតាមការយល់ឃើញថាសមហេតុផលពីខាង ខៀវ សំផន។

ទី៣ គឺដោយសារតែការបដិសេធសំណើសុំ៣អាទិត្យឲ្យគាត់រៀបចំមុនពេលដែលពិនិត្យដេញដោលទៅលើគាត់ និងចំណុចទី៤ បញ្ហាពាក់ព័ន្ធទៅនឹងមេធាវីការពារក្តី គាត់មិនអាចចូលទៅមន្ទីរឃុំឃាំងនៅថ្ងៃចុងសប្តាហ៍។ ដូច្នេះបញ្ហានេះមិនទាន់បានដោះស្រាយសម្រាប់ពួកគាត់។ ចំណុចចុងក្រោយ មិនមែនជាការបដិសេធទេ តែជាសំណើរបស់ពួកគាត់ គឺគាត់សុំតែផ្តល់សក្ខីកម្មពាក់កណ្តាលថ្ងៃតែប៉ុណ្ណោះ។ បានន័យថា១ថ្ងៃ គាត់សុំឆ្លើយតែកន្លះថ្ងៃតែប៉ុណ្ណោះ។

[១០:២០:៥០]

មូលដ្ឋានទាំងអស់នេះ គឺថាយើងខ្ញុំយល់ ក៏ប៉ុន្តែវាមាននីតិវិធីការតវ៉ាសផ្សេងទៀត ដែលបានលើកឡើង។ យើងខ្ញុំបានពិចារណា ហើយការលើកឡើងតវ៉ាទាំងអស់នោះ មិនគួរឲ្យជឿជាក់នោះទេ។ យើងខ្ញុំនឹងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ។ ទាំងអស់នេះហើយគឺជានីតិវិធីចំនួនប្រាំដែលលើកឡើងដោយមេធាវីការពារក្តី ហើយបានផ្លាស់ប្តូរជំហររបស់គាត់ក្នុងដំណាក់កាលចុងក្រោយនេះ។

វាមានសារៈសំខាន់ណាស់ដោយសារតែសេចក្តីសម្រេចនេះ គឺក្រោយពីយើងពិនិត្យមើលទៅមើលសវតានីតិវិធីទៅលើបញ្ហាទាំងអស់នេះ។ វាមានសារៈសំខាន់ណាស់ដែលយើងខ្ញុំសូមលើកឡើងជាសាធារណៈក្នុងពេលដែលជនរងគ្រោះមានវត្ត -- កំពុងតែសម្លឹងមើល និងប្រជាជនកម្ពុជាកំពុងតែសម្លឹងមើល រួមទាំងមានវត្តមានជនជាប់ចោទ។ លោក ខៀវ សំផន បានលើកឡើងស៊ីសង្វាក់គ្នានៅមុន

ដំណាក់កាលជំនុំជម្រះ គាត់ឆ្លើយថាគាត់នឹងផ្តល់សក្ខីកម្ម គាត់នឹងព្រមឆ្លើយ។ គាត់បានឆ្លើយដូច្នេះនៅថ្ងៃ១៣ ខែកញ្ញា ឆ្នាំ២០១១ នៅពេលដែលអង្គជំនុំជម្រះបង្គាប់ឲ្យ ខៀវ សំផន បង្ហាញជំហររបស់គាត់។

[១០:២២:០៥]

គាត់បានលើកឡើងពីខាងមុខពីៗពេលមុនផងដែរ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ គឺគាត់ថាគាត់នឹងឆ្លើយតប ប្រសិនគាត់បានស្តាប់ភស្តុតាងរួចរាល់។ ហើយជំហរនេះក៏បានមេធាវីការពារក្តីលើកឡើងផងដែរ។ ការសម្រេចបែបនេះ គឺមិនមានការប្រែប្រួលផ្លាស់ប្តូរនោះទេ។ ជាការពិត លោក ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍ផ្តល់ភស្តុតាងក្នុងពេលដំណើរការក្តី ហើយគាត់ក៏បាននៅថ្មីៗនេះ គឺគាត់បានចាប់ផ្តើមនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ គឺគាត់បានឆ្លើយតបជាក់លាក់ពីខាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះបានន័យថាគាត់បានផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

មុនពេលដែលខ្ញុំបន្តលើកឡើងអំពីសាវតារនីតិវិធី ខ្ញុំសូមបញ្ឈប់នៅត្រង់ចំណុចនេះសិន ហើយខ្ញុំលើកឡើងការសង្កេតរបស់ខ្ញុំថា ផលប៉ះពាក់ផ្នែកផ្លូវច្បាប់កើតចេញពីជំហរផ្លាស់ប្តូររបស់គាត់ និងការលើកឡើងឆ្លើយបតទៅនឹងភស្តុតាងនោះ គឺៗគាត់ខ្លួនឯងបានបោះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ គាត់មិនបានអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ។ ជាការពិត គឺគាត់ជ្រើសរើសឆ្លើយបតទៅនឹងភស្តុតាង ហើយគាត់បានសម្រេច និងធ្វើការផ្តល់សក្ខីកម្មរួចមកហើយ។ នេះគឺជាផលប៉ះពាល់ផ្លូវច្បាប់ដែលវាអាចមានឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់គាត់នៅពេលនេះតែម្តង។ ខ្ញុំនឹងលើកឡើងចំណុចនេះក្នុងពេលបន្តិចទៀតនេះ។

[១០:២៣:៤១]

ចំពោះលក្ខខណ្ឌទាំងឡាយដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីរបស់គាត់ ការពិភាក្សាទៅលើលក្ខខណ្ឌទាំងអស់នេះ គឺបានចាប់ផ្តើមនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣។ លោក លោកស្រីចៅក្រមប្រហែលជាចាំហើយ គឺមេធាវីការពារក្តី -- អង្គជំនុំជម្រះបានបង្គាប់ឲ្យជនជាប់ចោទបង្ហាញជំហរឆ្លើយនៅក្នុងដំណាក់កាលចុង -- បញ្ជាក់ថា ឆ្លើយ ឬមិនឆ្លើយនៅក្នុងដំណាក់ចុងក្រោយ។ ហើយមេធាវី -- ហើយខាងការពារក្តីបានលើកឡើងថាត្រូវការពីរបីថ្ងៃ ដើម្បីប្រឹក្សាជាមួយនឹងមេធាវីការពារក្តី។

ក្រោយមក លោក ខៀវ សំផន បានបញ្ជាក់ថា គាត់ព្រមនិងឆ្លើយតបទៅនឹងសំណួរទាំងឡាយ។ គាត់ឆ្លើយដូច្នេះនៅពេលនោះ គឺនៅត្រង់ម៉ោង ០៩:០៩:០១ គឺគាត់បានលើកឡើងថា "ខ្ញុំត្រូវដឹងអំពី

ខ្លឹមសារសំណួរដែលចោទសួរទៅកាន់គាត់ជាមុន។ អង្គជំនុំជម្រះបានបានបង្គាប់ថា វាមិនទំនងនោះទេ ដោយសារតែអង្គជំនុំជម្រះមិនអាចសរសេរសំណួរជាមុនសួរទៅកាន់ជនជាប់ចោទ ដូចនៅក្នុងសាលាដែលសរសេរសំណួរនៅលើក្ដារខៀននោះទេ”។

[១០:២៤:៥៧]

ហើយយើងខ្ញុំសូមបញ្ជាក់ថា វាការធ្វើដូច្នេះ គឺវាខុសពីបទដ្ឋានអន្តរជាតិ ឬក្នុងស្រុកនានាដែលយើងបានដឹងផងដែរ។ ក្រោយពីការឆ្លើយឆ្លងគ្នានៅម៉ោង ០៩:១២:១៥ លោក វែកគែន បានបញ្ជាក់លើបញ្ហានេះ ហើយបញ្ជាក់ថាលោក ខៀវ សំផន មិនស្នើសុំបញ្ជីសំណួរនោះទេ ក៏ប៉ុន្តែលោក ខៀវ សំផន ខ្ញុំសូមដកស្រង់សម្ដីគាត់ “លោក ខៀវ សំផន គឺចង់បានតែប្រធានបទទូទៅដែលនឹងគ្រោងសួរតែប៉ុណ្ណោះ រួមទាំងបញ្ជីសំណួរប្រសិនបើមាន”។ នេះជាជំហរលើកឡើងថ្ងៃទី២៧ ឧសភា ២០១៣។

ខ្ញុំសូមបញ្ជាក់នៅត្រង់នេះថា សំណើសុំបញ្ជីសំណួរ និងសំណើរសុំបញ្ជីប្រធានបទ គឺវាហួសពីបទដ្ឋានអន្តរជាតិរួចទៅហើយ។ យើងមិនចាត់ការទៅលើបញ្ហានេះ ក៏ប៉ុន្តែយើងខ្ញុំនឹងលើកឡើងចំណុចទាំងអស់នេះ នៅពេលដែលយើងខ្ញុំអញ្ជើញលោក ខៀវ សំផន ឲ្យពិចារណាចំណុចនេះឡើងវិញ ជា-ពិសេសទៅលើជំហររបស់គាត់។

សំណើសុំរបស់គាត់បន្ថែមទៅលើបញ្ជីសំណួរគឺលេចចេញនូវថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ នៅពេលដែលរៀបចំសវនាការ រៀបចំរបស់យើង ឯកសារ E288/2១ ដែលក្នុងនោះបញ្ជីសំណួរបានលើកឡើងជាលើកទី១។ វាជាការចាប់អារម្មណ៍នៅក្នុងការរៀបចំសវនាការនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៣ បញ្ហានេះគឺមិនបានមេធាវីការពារក្ដីលើកឡើងនោះទេ បានន័យថា គាត់មិនបានស្នើសុំឲ្យផ្ដល់ឯកសារបន្ថែមជូនទៅកាន់គាត់នៅពេលនោះឡើយ។

[១០:២៦:៥៧]

សំណើរសុំនាពេលនោះគឺគាត់សុំទុកពេល៣អាទិត្យឲ្យគាត់ ដើម្បីឲ្យគាត់ត្រៀមខ្លួន។ សំណើសុំនោះគឺយើងដឹងហើយ គឺថាគាត់ក៏បានស្នើសុំបញ្ជីសំណួរ រួមទាំងបញ្ជីប្រធានបទដែលគ្រោងនឹងសួរផងដែរ។

ពាក់ព័ន្ធទៅនឹងការតវ៉ាទៅលើពេលវេលាសម្រាប់សួរសំណួរទៅកាន់គាត់នោះ លោក លោកស្រីចៅក្រមចាំហើយថាអញ្ជើញភាគី បញ្ជាក់ថាតើភាគីត្រូវការពេលវេលាប៉ុន្មាន? យើងខ្ញុំត្រូវការ៦ថ្ងៃសម្រាប់ពិនិត្យទៅលើលោក ខៀវ សំផន ហើយនិងសុំឲ្យមានភាពបត់បែន។ អង្គជំនុំជម្រះក៏បានយល់

ឃើញថាមិនគួរដាក់ពេលវេលាកំណត់នោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចថា អនុញ្ញាតឱ្យនីតិវិធីពិនិត្យជនជាប់ចោទនេះគឺថាបន្តទៅមុខ ហើយប្រសិនបើសំណួរពាក់ព័ន្ធនោះគឺអាចអនុញ្ញាតឱ្យបន្តទៅមុខបាន។ ហើយក្នុងករណីដែលជនជាប់ចោទមានសុខភាពល្អ គឺអាចបន្តទៅមុខដោយមិនមានពេលវេលាកំណត់ជាក់លាក់។ នេះគឺជាហេតុផលដែលអង្គជំនុំជម្រះលើកឡើងក្នុងដំណាក់កាលនីតិវិធីនាពេលនេះ។

[១០:២៨:២២]

ត្រឡប់មកលើកឡើងអំពីសំណើជាក់លាក់ ដែលបានធ្វើឡើងដោយក្រុមមេធាវីការពារក្តីវិញម្តង ខ្ញុំសូមបញ្ជាក់យ៉ាងច្បាស់ក្នុងនាមតំណាងសហព្រះរាជអាជ្ញា ទោះបីជាសំណើទាំងអស់នេះវាលើសពីអ្វីដែលយើងទទួលស្គាល់នៅក្នុងបទដ្ឋានអន្តរជាតិក៏ដោយ ទោះបីជាវាលើសពីសិទ្ធិដែលជនជាប់ចោទទទួលបានក៏ដោយ យើងខ្ញុំចង់ធានាធ្វើយ៉ាងណាផ្តល់ឱកាសទៅកាន់ជនជាប់ចោទ ឱ្យគាត់ឆ្លើយតបទៅនឹងសំណួរតាមតែគាត់សន្យាជិត២ឆ្នាំមកហើយ។

ពីខាងតំណាងសហព្រះរាជអាជ្ញា យើងខ្ញុំបានត្រៀមខ្លួនរួចជាស្រេចផ្តល់នូវបញ្ជីសំណួរដែលអង្គជំនុំជម្រះនឹងធ្វើការសម្របសម្រួល ហើយយើងខ្ញុំក៏បានត្រៀមរៀបចំរួចមកហើយនូវបញ្ជីប្រធានបទដែលនឹងយកមកពិភាក្សាគ្នាក្នុងពេលពិនិត្យជនជាប់ចោទ ហើយបញ្ជីនៃឯកសារ ឬបញ្ជីនៃប្រធានបទនោះគឺមិនមែនថាយើងផ្តល់ជូនបានគ្រប់ទាំងអស់នោះទេ។ ដូចដែលលោកប្រធានបានបញ្ជាក់រួចមកហើយ ការពិនិត្យជនជាប់ចោទគឺជាគោលការណ៍តទល់មុខគ្នា។ ដូច្នេះហើយយើងមិនអាចបញ្ជូនលើប្រធានបទ ឬឯកសារគ្រប់ទាំងអស់នោះទេ។ ក៏ប៉ុន្តែយើងខ្ញុំត្រៀមខ្លួនរួចជាស្រេចនូវផ្តល់បញ្ជីលម្អិតសមស្របថាប្រធានបទណាខ្លះដែលគ្រោងនឹងយកមកពិភាក្សា។

[១០:២៩:៥១]

ជាការពិត គឺបញ្ជីទាំងអស់ហ្នឹងបន្ថែមនឹងទៅនឹងបញ្ជីប្រធានបទដែលមាននៅក្នុងដីកាដំណោះស្រាយ ជាពិសេសទៅលើបញ្ហាដែលអង្គជំនុំជម្រះចាប់អារម្មណ៍នៅក្នុងវគ្គសវនាការវគ្គនេះ។ យើងខ្ញុំរៀបចំរួចមកហើយ យើងខ្ញុំអាចផ្តល់ជូនក្នុងរយៈពេល២៤ម៉ោងបាន ប្រសិនបើជនជាប់ចោទនៅពេលនេះឯកភាពឆ្លើយតបទៅនឹងសំណួរ។

ចំពោះពេលវេលាបន្ថែមក្នុងការត្រៀមរៀបចំសម្រាប់ខាងក្រុមមេធាវីការពារក្តី យើងខ្ញុំឯកភាពជាមួយនឹងអង្គជំនុំជម្រះថា ការពិនិត្យមើលឯកសារទាំងអស់នេះរយៈពេល៥ឆ្នាំរួចមកហើយ ហើយការ

ចូលរួមក្នុងរយៈពេល១ឆ្នាំកន្លះនៅក្នុងសវនាការនេះ គឺជនជាប់ចោទ គាត់អាចដឹងទៅលើអ្វីដែលគេគ្រោងនឹងសួរ។

ដូច្នេះវាមិនចាំបាច់ត្រូវផ្តល់ពេលវេលាបន្ថែមនោះទេ។ ក៏ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះគិតថាគួរតែផ្តល់ពេលវេលាបន្ថែម និងធ្វើការសម្របសម្រួលនោះ យើងខ្ញុំមិនជំទាស់នោះទេ។ យើងខ្ញុំគ្រាន់តែចង់ធ្វើយ៉ាងណាឲ្យជនជាប់ចោទទទួលបាននូវឱកាសបានសមរម្យ និងឱកាសសមហេតុផលក្នុងការត្រៀមខ្លួនឆ្លើយតបទៅនឹងសំណួរ ដែលគាត់សន្យាថាគាត់នឹងឆ្លើយតាំងពីដើមមក។

នៅពេលនេះ គឺខ្ញុំលើកឡើងអំពីផលប៉ះពាល់ផ្លូវច្បាប់ចេញមកពីសេចក្តីសម្រេចរបស់ខាងជនជាប់ចោទ ដែលគាត់ថានឹងមិនឆ្លើយតបទៅនឹងសំណួរ។ ជាការពិតយើងបានឮនៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ ថាយើងនឹងមកដល់ដំណាក់កាលនេះ។ យើងខ្ញុំបានដាក់សំណើគឺឯកសារ E174 ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ដែលយើងខ្ញុំសូមអញ្ជើញអង្គជំនុំជម្រះជូនដំណឹងទៅកាន់ជនជាប់ចោទអំពីផលប៉ះពាល់នៃការអនុវត្តសេចក្តីសម្រេចរបស់គាត់តាមការជ្រើសរើសថា ឆ្លើយ ឬក៏មិនឆ្លើយនោះ។

[១០:៣១:៥២]

អង្គជំនុំជម្រះបានទទួលសំណើរបស់យើងខ្ញុំ ហើយបន្ទាប់មកគឺបានជូនដំណឹងជនជាប់ចោទទាំងអស់អំពីផលប៉ះពាល់ ដែលអាចកើតចេញពីសេចក្តីសម្រេចរបស់គាត់ ធ្វើការជ្រើសរើសឆ្លើយតប ឬមិនឆ្លើយតប។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ប្រតិចារិកគឺ E1/63.1 ហើយការណែនាំរបស់អង្គជំនុំជម្រះធ្វើឡើងនៅម៉ោង ១១:១២:៣២។ នៅក្នុងនោះអង្គជំនុំជម្រះបានបញ្ជាក់ហើយ យុត្តិសាស្ត្រអន្តរជាតិលើកឡើងថា ការសន្និដ្ឋានពីការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះអាចទាញចេញពីនោះបាន។ ការណែនាំគឺស្របជាមួយនឹងយុត្តិសាស្ត្រអន្តរជាតិនានា នៅពេលដែលជនជាប់ចោទផ្តល់ភស្តុតាងរួចមកហើយ ដូចដែលលោក ខៀវ សំផន បានធ្វើឡើងរួចមកហើយការបដិសេធមិនឆ្លើយតបទៅនឹងសំណួរនៅក្នុងដំណាក់កាលក្រោយនោះ គឺអាចឲ្យទាញសន្និដ្ឋានថា ភស្តុតាងដែលគាត់ឆ្លើយនោះគឺជាភស្តុតាងទៅលើគាត់។

[១០:៣៣:០៤]

យើងខ្ញុំគិតថា មកដល់ដំណាក់កាលនេះគឺវាមិនមែនជាដំណាក់កាលធ្វើសម្ចតិកម្មនោះទេ ក៏ប៉ុន្តែនៅពេលនេះគឺជាដំណាក់កាលដែលជនជាប់ចោទធ្វើការបដិសេធមិនឆ្លើយតប។ ខ្ញុំសូមលើកឡើងយុត្តិសាស្ត្រឯកសារសំអាងពីរ ឬក៏បី។ ទី១ ចេញមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺចុះថ្ងៃ១៣ ខែ

កញ្ញា ឆ្នាំ២០១១ នៅក្នុងរឿងក្តី ឡឹថាងហ្កា។ កថាខណ្ឌដែលពាក់ព័ន្ធគឺត្រង់កថាខណ្ឌ៧ និង៨ ដែលបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលជនជាប់ចោទបានផ្តល់ភស្តុតាងឆ្លើយតបរួចហើយ សេចក្តីសម្រេចរបស់គាត់មិនឆ្លើយតបៗនោះ គឺយើងអាចទាញសេចក្តីសន្និដ្ឋានទៅលើភស្តុតាងរបស់គាត់បាន។

ឯកសារមូលដ្ឋានទី២ គឺសហព្រះរាជអាជ្ញានិង ប្តេករូលផូរិក សេចក្តីសម្រេចថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ ដែលតុលាការអាយ.ស៊ី.ធី.វ៉ាយ នៅទីនោះគឺបានបង្ហាញអំពីសិទ្ធិរបស់ជនជាប់ចោទ។ យើងឃើញនៅមាននៅក្នុងកថាខណ្ឌ២៤ នៃសេចក្តីសម្រេចនេះ ដែលបានលើកឡើងពាក់ព័ន្ធទៅនឹងការទាញសេចក្តីសន្និដ្ឋាន។

[១០:៣៤:១៨]

បន្ថែមទៀត គោលការណ៍នេះបានបង្ហាញនៅក្នុងប្រព័ន្ធនានា ហើយត្រូវបានសម្រេចដោយតុលាការសិទ្ធិអឺរ៉ុបផងដែរ គឺឃើញមាននៅក្នុងសេចក្តីសម្រេចរបស់ករណី ម៉ារី ជាមួយនឹងសហរដ្ឋចក្រភពអង់គ្លេស គឺនៅចុះនៅក្នុងឆ្នាំ១៩៩៦ ខែកុម្ភៈ។ គោលបំណង -- គោលការណ៍ទាំងអស់នោះគឺអាចចេញមកពីសិទ្ធិដែលគាត់នៅស្ងៀមមិនឆ្លើយតប ហើយអាចទាញសន្និដ្ឋានជាភស្តុតាងសម្រាប់ជនជាប់ចោទ។

ដូច្នេះសំណើរបស់យើងខ្ញុំ គឺមានពីរ ទី១ គឺអង្គជំនុំជម្រះអនុញ្ញាតការសម្របសម្រួលបន្ថែម ដូចដែលយើងខ្ញុំបានលើកឡើងអ៊ីចឹង ជាពិសេសពាក់ព័ន្ធទៅនឹងបញ្ជីសំណួរ និងបញ្ជីនូវប្រធានបទ និងបញ្ជីឯកសារ។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា សមស្របក្នុងរយៈពេលមួយសមស្រប ២ ឬ៣ សប្តាហ៍។ ហើយប្រសិនបើគិតថាសមស្របសម្រាប់រៀបចំត្រៀមខ្លួនទៅកាន់ -- សម្រាប់ជនជាប់ចោទ។ ហើយគឺដើម្បីឲ្យគាត់នេះមានពេលវេលាសមស្របដើម្បីរៀបចំខ្លួន។ នៅពេលនេះជនជាប់ចោទគឺឲ្យគាត់បញ្ជាក់ថា តើគាត់យល់យ៉ាងម៉េចទៅនឹងការសម្របសម្រួលរបស់អង្គជំនុំជម្រះ ហើយគាត់គិតថាតើគាត់ឆ្លើយ ឬក៏មិនឆ្លើយ?

សំណើទី២របស់យើងខ្ញុំ គឺប្រសិនបើជនជាប់ចោទឆ្លើយថា គាត់នឹងមិនព្រមឆ្លើយនោះទេ អង្គ-ជំនុំជម្រះត្រូវតែតម្កល់សេចក្តីជូនដំណឹងរបស់ខ្លួនកាលពីលើកមុនថា ការទាញសន្និដ្ឋានលក្ខណៈវិជ្ជមាននឹងធ្វើឡើងចំពោះជនជាប់ចោទ។ ជាពិសេសការទាញសន្និដ្ឋានទៅលើភស្តុតាង នៅពេលដែលអង្គជំនុំជម្រះធ្វើការពិភាក្សាសម្រេចរៀបចំនូវសាលក្រមនៅក្នុងរឿងក្តីនេះ។

[១០:៣៦:១៨]

ទាំងអស់នេះ ជាសំណើសុំរបស់យើងខ្ញុំ ហើយយើងខ្ញុំនឹងត្រៀមខ្លួនសម្រាប់ឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលអង្គជំនុំជម្រះគ្រោងនឹងសួរមកកាន់យើងខ្ញុំ ប្រសិនបើមាននោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមបន្តិចបន្តួចដើម្បីជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ទាប់ពីការសម្រេចចិត្តរបស់លោក ខៀវ សំផន ហើយនិងក្រុមការពារក្ដីរបស់គាត់ ជារឿងធម្មតាទេ គឺថាយើងសោកស្ដាយណាស់អំពីការសម្រេចចិត្តរបស់លោក ខៀវ សំផន ដែលត្រូវបានផ្ដល់ជូនដំណឹងដល់យើងកាលពីម្សិលមិញ ហើយយើងក៏សោកស្ដាយខ្លាំងផងដែរ បន្ទាប់ពីបានស្ដាប់សវនាការនៅចុងខែឧសភា និងដើមខែមិថុនា ដែលយើងបានឃើញថាមានសារៈសំខាន់ណាស់ដែលលោក ខៀវ សំផន បានយល់ព្រមឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយយើងឃើញថាការឆ្លើយតបរបស់គាត់នេះ មានសារៈសំខាន់មែនទែន ដែលគាត់ឆ្លើយតបទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី។

[១០:៣៧:៣៣]

លោក ខៀវ សំផន ឥឡូវនេះ គាត់មកបង្ហាញថាគាត់ជាអ្នកដែលមិននឹងឆ្លើយតប។ យើងយល់ពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប ក៏ប៉ុន្តែយើងក៏សោកស្ដាយអំពីពាក្យសម្ដីដែលគាត់បានឡើង គាត់បាននិយាយហើយគាត់និយាយបញ្ជាក់ផងដែរ គាត់ថានៅពេលដែលសវនាការចប់ហ្នឹង គាត់នឹងឆ្លើយតបទៅនឹងសំណួរ។ ដូចព្រះរាជអាជ្ញាដែរ យើងគិតថាទាក់ទងនឹងការត្រៀមលក្ខណៈឆ្លើយតបនឹងសំណួរនោះលោក ខៀវ សំផន គាត់មិនខុសពីអ្នកដទៃទេ គឺជាការកាត់ក្ដីអស់រយៈពេល២ឆ្នាំជាងមកហើយ ហើយមានដំណាក់កាលស៊ើបអង្កេតដែលធ្វើឲ្យលោក ខៀវ សំផន អាចត្រៀមខ្លួនបាន ដើម្បីការពារខ្លួនឆ្លើយតបទៅនឹងសំណួរនៅពេលដំណាក់កាលចុងក្រោយនៃការជម្រះសេចក្ដី។ យើងគិតថា ការលំបាកចំពោះគាត់ហ្នឹង ដូចអ្នកដទៃក៏លំបាកដែរ គឺខ្វះបុគ្គលិក ខ្វះពេលវេលា ខ្វះឯកសារ។ អ៊ីចឹងសុទ្ធតែយើងទាំងអស់គ្នាជួបនឹងស្ថានភាពដូចគ្នា។

ទាក់ទងទៅនឹងពេលវេលាសួរសំណួរ ក្រុមរបស់លោក ខៀវ សំផន សុំថារយៈពេល៤សប្ដាហ៍

ឬក៏លើសពីហ្នឹង ខ្ញុំគិតថាមិនត្រឹមត្រូវទេ។ ខ្ញុំអង្កាល់ណោះ ខ្ញុំយល់ថាអង្គជំនុំជម្រះមិនបានកំណត់ពេលវេលាសួរនោះទេ។ គឺជាសេចក្តីសម្រេចមួយដើម្បីជាប្រយោជន៍ជនជាប់ចោទដែរ គឺថាដើម្បីឲ្យជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្រាក ដើម្បីពិចារណា ហើយនិងដើម្បីនៅស្ងៀម បើមិនចង់ឆ្លើយតបអីជាដើមនោះ។

[១០:៣៩:១២]

អ៊ីចឹងខ្ញុំគិតថា អង្គជំនុំជម្រះមិនបានប្រាប់ថា ពេលវេលាមានកម្រិតនោះទេ។ គឺថាបើមិនអ៊ីចឹងទេ វាផ្ទុយពីសិទ្ធិរបស់ជនជាប់ចោទ។

ខ្ញុំសូមគូសបញ្ជាក់ផងដែរ ឆ្លើយតបទៅនឹងសំណួរ ចំពោះខ្ញុំវិញនេះ ខ្ញុំគិតថាមិនមែនដើម្បីតែប្រយោជន៍របស់សហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីទេ ក៏ប៉ុន្តែដើម្បីប្រយោជន៍របស់ជនជាប់ចោទផងដែរ។ ហើយត្រង់ចំណុចនេះ ខ្ញុំគាំទ្រសហព្រះរាជអាជ្ញា ហើយខ្ញុំគិតថាឥឡូវនេះ គឺជាពេលវេលាចំពោះអ្នកដែលប្រកាសថាខ្លួនពុំមានកំហុស ពុំមានពិរុទ្ធភាពនោះ ក្នុងការឆ្លើយតបនឹងសំណួរ និងធ្វើការពន្យល់ ដើម្បីជាប្រយោជន៍របស់ខ្លួន។ ព្រោះថានេះជាពេលវេលាដ៏សំខាន់ណាស់ចំពោះគាត់ ក្នុងការនិយាយស្តី។

ខ្ញុំនឹងបញ្ចប់ដើម្បីនិយាយនៅលើចំណុចមួយដែលខ្ញុំបាននិយាយមុនគេអម្បាញ់មិញនេះ។ ខ្ញុំស្មានតែលោក ខៀវ សំផន ហ្នឹងចង់ឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំស្ទើរតែច្បាស់ក្នុងចិត្តហើយថា គាត់ឆ្លើយតបទៅនឹងសំណួរតាមដែលអាចធ្វើទៅបាន។ ខ្ញុំគិតថា គឺជាឱកាសមួយសំខាន់ណាស់ចំពោះគាត់ ហើយនិងចំពោះដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាប្រជាជនខ្មែរទាំងមូលតែម្តង ហើយជាការសោកស្តាយណាស់បើសិនជាមិនឆក់យកឱកាសនេះឲ្យបាន។ យើងនឹងផ្តល់សំណួរជូនគាត់ជាមុន បញ្ជើសំណួរជូនគាត់ជាមុន ហើយយើងចង់ចោទសំណួរទាំងអស់នេះ ក្នុងរយៈពេញមួយសមរម្យ ហើយយើងមិនអូសបន្លាយពេលទៅលើប្រធានបទដែលពុំមានប្រយោជន៍ទេ។

[១០:៤១:០៥]

យើងយល់ណាស់អំពីចំណុចនេះថា យើងមិនចង់ចំណាយពេលច្រើនដោយឥតប្រយោជន៍នោះទេ។ ហើយខ្ញុំសង្ឃឹមថា លោក ខៀវ សំផន នឹងត្រឡប់មកដូរចិត្តវិញ ដើម្បីឆ្លើយតបនឹងសំណួរវិញ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងភាគីមេធាវី ខៀវ សំផន ហើយនិងលោក ខៀវ សំផន ផ្ទាល់តើមានអ្វីចង់ឆ្លើយតបទៅនឹងសេចក្តីឆ្លើយតបរបស់ភាគីម្ខាងទៀតដែលបានលើកឡើងអម្បាញ់មិញនេះដែរឬទេ?

**លោក អាកទួរ វែកគែន៖**

បាទ យើងបានធ្វើការជូនដំណឹងមួយដើម្បីពន្យល់អំពីគោលជំហររបស់យើងដ៏ច្បាស់លាស់។ ខ្ញុំបាទលោកប្រធានខ្ញុំគិតថា លោកប្រធានមិនចង់ឲ្យខ្ញុំនិយាយឡើងវិញអំពីខ្លឹមសារនៃសារណារបស់យើងដែលមាន១១ទំព័រនោះទេ។ នៅពេលដែលខ្ញុំឮសហភាគារបស់ខ្ញុំនៅម្ខាងទៀតនោះ និយាយអម្បាញ់មិញនេះ យើងមិនមែននៅក្នុងកន្លែងកាត់ក្តីនោះទេ ហើយយើងនៅក្នុងទីកន្លែងសន្និសីទអន្តរជាតិទាក់ទងពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ហើយគេមិនយល់ថា ហេតុអីក៏លោក ខៀវ សំផន អល់អែកមិនព្រមនិយាយស្តីទៅតាមលក្ខខណ្ឌដែលតុលាការកំណត់។ នេះ គឺជាការយល់ឃើញពីកាលៈទេសៈនេះខុសគ្នា។ នៅទីនេះគឺជាការជម្រះសេចក្តី ហើយកាលណាយើងធ្វើសំណើសាមញ្ញយ៉ាងដូច្នេះ ហើយសំណើយើងនេះត្រូវបានបដិសេធចោទទាំងអស់នេះ យើងយល់ឃើញថា ការបដិសេធទាំងអស់នេះមិនគោរពសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន នោះទេ។ ហើយចាប់ពីពេលហ្នឹងទៅ គឺនៅពេលដែលយើងនៅតែបន្តចូលរួមទទួលការជម្រះសេចក្តីទៀតនេះ មិនមានន័យអ្វីទាល់តែសោះចំពោះលោក ខៀវ សំផន នោះ ពីព្រោះថាសេចក្តីសម្រេចចិត្តរបស់លោក ខៀវ សំផន គាត់ធ្វើឡើងដោយខ្លួនឯង ហើយគាត់ប្រហែលជាអាចឆ្លើយតបបានខ្លះ ហើយចំពោះព័ត៌មានលម្អិតនោះ វាមាននៅក្នុងឯកសារ E288/4 ហ្នឹងខ្លឹមសារជាក់លាក់អស់ហើយនៅក្នុងហ្នឹង។ បាទ សូមអរគុណលោកប្រធាន។

[១០:៤៣:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ម៉េចទៅលោក ខៀវ សំផន មានអ្វីឆ្លើយតបទៅនឹងសេចក្តីឆ្លើយតបរបស់ភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះដែរឬទេ?

**លោក ខៀវ សំផន៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ដែលមានមុខនៅទីនេះ បងប្អូនរួមជាតិទាំងអស់ជាទីគោរពស្នេហា។ ខ្ញុំសូមជម្រាបថា ខ្ញុំៗសូមជម្រាបនូវហេតុផលដែលខ្ញុំសម្រេចប្រើប្រាស់សិទ្ធិរបស់ខ្ញុំនៅស្ងៀមស្ងាត់។ ហេតុផលគឺមកពីតុលាការមិនបានគោរពនូវសិទ្ធិរបស់

ខ្ញុំ និងមេធាវីការពារក្ដីរបស់ខ្ញុំ។ ពីមុនដំបូង ខ្ញុំជឿលើតុលាការនេះ ប៉ុន្តែជាបន្តបន្ទាប់មក ហូរហែមករហូតដល់ដំណាក់កាលចុងក្រោយនេះ ខ្ញុំលែងជឿហើយ ខ្ញុំអស់ជំនឿហើយ។ ខ្ញុំសូមជម្រាបខ្លីប៉ុណ្ណោះ។ សូមអរគុណ។

[១០:៤៥:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៦នាទី ដល់ម៉ោង ១១:១០នាទី)*

[១១:១០:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការជាបន្តទៅនេះគឺធ្វើការកត់សម្គាល់ ឬអត្ថាធិប្បាយតបទៅនឹងបណ្ដាឯកសារគន្លឹះដែលដាក់ដោយភាគីតំណាងសហព្រះរាជអាជ្ញា និងក្រុមខាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃសវនាការដាក់ឯកសារគន្លឹះកន្លងមក ដោយក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ប៉ុន្តែមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន អង្គជំនុំជម្រះសូមសួរមួយសំណួរទៅលោក ខៀវ សំផន។

សូមអញ្ជើញក្រោកឈរ លោក ខៀវ សំផន!

អង្គជំនុំជម្រះសូមសួរទៅលោក ខៀវ សំផន ថាប្រសិនបើអង្គជំនុំជម្រះអនុវត្តទៅតាមលក្ខខណ្ឌមួយចំនួនដែលបានលើកឡើងនិងស្នើសុំដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះថា សុំឱ្យអង្គ-ជំនុំជម្រះពិចារណាឡើងវិញ អំពីការផ្ដល់ពេលវេលាសមស្របសម្រាប់លោកក្នុងការត្រៀមរៀបចំខ្លួន

ហើយនិងផ្តល់ប្រធានបទជាក់លាក់ ហើយនិងបញ្ជីឯកសារដែលពាក់ព័ន្ធទៅនឹងសំណួរដែលគ្រោងនឹងសួរ ថាតើលោកអាចនឹងសម្រេចចិត្តយ៉ាងដូចម្តេចដែរក្នុងការអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែលលោកបានសម្រេចកន្លងមកនេះ ឬក៏លោកកែប្រែផ្លាស់ប្តូរជំហរពីការលះបង់សិទ្ធិឆ្លើយតបនេះទៅជាការឆ្លើយតបវិញ បានន័យថាលោកមានការកែសម្រួល កែប្រែនូវជំហររបស់លោកដែរឬទេ ប្រសិនបើលក្ខខណ្ឌដូចខ្ញុំបានជម្រាបអម្បាញ់មិញនេះ?

[១១:១២:៣៣]

**លោក ខៀវ សំផន៖**

សូមជម្រាបលោកប្រធាន។ សូមជម្រាបអស់លោក លោកស្រីចៅក្រម។ សូមជម្រាបអស់លោក លោកស្រីទាំងអស់ដែលនៅទីនេះ។ សូមជម្រាបបងប្អូនរួមជាតិទាំងអស់ជាទីគោរពស្នេហា។ ដែលខ្ញុំប្រើប្រាស់សិទ្ធិរបស់ខ្ញុំនៅស្ងៀមស្ងាត់ មិនមែនត្រឹមតែមកពីរឿងតុលាការមិនបានសម្រេចតាមការស្នើសុំរបស់ខ្ញុំដូចព្រះរាជអាជ្ញាបានរៀបរាប់អំម្បាញ់មិញនេះទេ។ វាមានបញ្ហាផ្លូវច្បាប់ជាច្រើនទៀតដែលវាចោទ។ ឧទាហរណ៍ខ្ញុំលើកតែមួយទេ ការរាំងខ្ទប់មិនឲ្យមេធាវីរបស់ខ្ញុំអាចការពារខ្ញុំបានឲ្យបានពេញលេញ។ ការអនុញ្ញាតឲ្យត្រឹមតែ១០០ទំព័រ ដើម្បីនឹងធ្វើសេចក្តីសន្និដ្ឋាននៅទីបញ្ចប់ដើម្បីមេធាវីខ្ញុំធ្វើសេចក្តីសន្និដ្ឋាននៅទីបញ្ចប់។ អានេះខ្ញុំឃើញថាវាជាការរាំងខ្ទប់មិនឲ្យមេធាវីខ្ញុំការពារខ្ញុំបានពេញលេញ។ ខ្ញុំសូមជម្រាបលោកប្រធានប៉ុណ្ណឹង បាទសូមជ្រាប។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អស់លោក លោកស្រីចៅក្រមមានសំណួរអីចង់សួរបន្ថែមបញ្ជាក់ចំពោះលោកខៀវ សំផន ដែរឬទេ?

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាកឡាវែន៍!

[១១:១៤:៣៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីឲ្យច្បាស់លាស់ទាំងអស់គ្នា កាលពីព្រឹកមិញយើងបានស្តាប់សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា។ សំណើទាំងអស់នោះសំដៅឲ្យក្រុមលោក ខៀវ សំផន រៀបចំខ្លួនក្នុងការទទួលការចោទសំណួរ។ គឺទាក់ទងនឹងការបន្ថែមពេលវេលាក្នុងការចោទសំណួរ ហើយនិងធ្វើយ៉ាងណាដើម្បីឲ្យមានការជូនដំណឹងជាមុនទៅជនជាប់ចោទអំពីបញ្ជីឯកសារ ហើយនិងបញ្ជីសំណួរ។ ខ្ញុំគិតថាចំណុច

ទាំងអស់នេះខាងក្រុមការពារក្ដីលោក ខៀវ សំផន បានគិតពិចារណាអស់ហើយ ហើយខ្ញុំក៏គិតថាលោក ក្រុម ខៀវ សំផន ក៏បានឮផងដែរអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំនិយាយឡើងវិញអំពីសេចក្ដីសម្រេចរបស់តុលាការអំពីលទ្ធភាពនៃការបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរក្នុងដំណាក់កាលនេះ។

ហើយក្រុម ខៀវ សំផន លោក ខៀវ សំផន ដោយផ្ទាល់យល់ឃើញថាសិទ្ធិមួយចំនួនរបស់ខ្លួន មិនត្រូវបានគោរព ហើយខ្ញុំសូមឲ្យច្បាស់ទាំងអស់គ្នានៅទីនេះ។ អ៊ីចឹងខ្ញុំសូមឲ្យគេពន្យល់ថា លោក ខៀវ សំផន សិទ្ធិរបស់គាត់យ៉ាងម៉េច ហើយយើងមិនគោរពសិទ្ធិគាត់នោះត្រង់ចំណុចណា? សូមបំភ្លឺចំណុចនេះឲ្យច្បាស់លាស់។ ហើយចង់សួរថា តើចំនួនទំព័រសម្រាប់សារណាបញ្ចប់បិទការដេញដោលនេះថាសំណើចំនួនទំព័រយ៉ាងម៉េច ហើយសំណួរដែលថាគាត់មិនបដិសេធ មិនព្រមឆ្លើយតបទៅនឹងសំណួរប្រភេទណា?

[១១:១៦:៥៧]

**លោក អាកទួរ វែកគែន៖**

ខ្ញុំសូមឆ្លើយតបទៅដោយសង្ខេបទៅនឹងសំណួរទាំងអស់នេះ។ បាទ ជាសំណាងល្អណាស់ដែល

សំណើរបស់យើងទាំងអស់ -- សារណារបស់យើងហ្នឹងជាសារណាដែលជាមូលដ្ឋាននៃគំនិតរបស់ក្រុមយើង ហើយក្នុងសារណាយើងនេះមានប្រធានបទជាច្រើន ក្នុងរសៀលនេះបើសិនជាអង្គជំនុំជម្រះមិនកាត់សម្ដីខ្ញុំទេ ខ្ញុំនឹងលើកយកប្រធានបទមួយក្នុង -- ឧទាហរណ៍ដូចជាការរំលោភសិទ្ធិលោក ខៀវ សំផន ជាដើមនេះ។ តុលាការបានកំណត់ពីដែនកម្រិតនៃការទទួលឯកសារយ៉ាងទាបបំផុត គឺថាសវនាការស្ដាប់អំពីភាពទទួលយកបាននៃឯកសារនៅក្នុងការកាត់ក្ដីយើងនេះ ប្រព្រឹត្តទៅបួនដងហើយ។ ឯកសាររាប់ពាន់ឯកសារត្រូវបានប្រកាសថាអាចទទួលយកបាន ដោយគ្រាន់តែមើលមួយក្រឡេកភ្នែកនោះទេ។ ឧទាហរណ៍ដូចជាកំណត់ត្រាជើងទំព័រនៃដីកាដំណោះស្រាយ ដែលត្រូវបានចាត់ទុកថាត្រូវតែមាន -- គិតថាមានយថាភាព គឺជាកំណត់ត្រានៅក្នុង -- កំណត់ត្រាជើងទំព័រនៅក្នុងដីកាដំណោះស្រាយ។

[១១:១៨:៤៤]

នៅសវនាការនេះលោកប្រធានបាននិយាយថា គឺជាឯកសារទាំងអស់ដែលគេបានលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេតហើយៗ។ អ៊ីចឹងត្រូវតែទទួលយកឯកសារនេះដោយមិនចាំបាច់ពិភាក្សាដេញដោលអ្វីទេ។ អត់បញ្ហាអ្វីទេចំពោះខ្ញុំ ក៏ប៉ុន្តែទន្ទឹមនឹងហ្នឹងពេលដែលពិភាក្សាអំពីឯកសារនៅក្នុង

សវនាការ។ តុលាការបានលើកឡើងថា ជាការចាំបាច់ចំពោះសាធារណជននោះត្រូវរៀបចំសវនាការនិយាយអំពីឯកសារគន្លឹះ។

អង្គជំនុំជម្រះបានបញ្ជាក់ផងដែរថា សវនាការនេះមានប្រហែលជាបួនសវនាការ ហើយមិនត្រូវនិយាយអំពីភាពទទួលយកបាននោះទេ ពីព្រោះថាតែសវនាការនេះបានប្រព្រឹត្តទៅដោយដាច់ពីគ្នា ហើយបន្ទាប់មកទៀតចាប់ពីសវនាការបីដំបូងនោះ តុលាការបាននិយាយថា យើងមិនត្រូវ -- ក៏មិនត្រូវនិយាយអំពីតម្លៃភស្តុតាងជាឯកសារដែលត្រូវបានបង្ហាញដោយភាគីផងដែរ។ ហើយនៅក្នុងឱកាសនៃសវនាការនិយាយពីបញ្ហាហ្នឹងនៅក្នុងសវនាការ និយាយអំពីឯកសារគន្លឹះ។ អ៊ីចឹងយើងមិន -- យើងពុំមានសិទ្ធិអ្វីនិយាយទាំងអស់ ហើយជាពិសេសខាងការពារក្ដី លើកលែងតែជនជាប់ចោទនោះទេមានសិទ្ធិនិយាយ។

ក្នុងសវនាការបន្តបន្ទាប់មកទៀតនោះ គឺថាសវនាការទី៣ យើងមានសិទ្ធិឆ្លើយតប ក៏ប៉ុន្តែសូមប្រយ័ត្នៗមិនមែនសិទ្ធិឆ្លើយតបតែផ្ដេសផ្ដាសនោះទេ។ ហើយកាលពីម្សិលមិញនៅក្នុងពេលដែលតុលាការនិយាយថា យើងអាចនិយាយអំពីឯកសារជាភស្តុតាងគន្លឹះនោះ អង្គជំនុំជម្រះបានហាមឃាត់ដល់សហភាគាររបស់ខ្ញុំ មេធាវីរបស់លោក នួន ជា មិនឲ្យនិយាយអំពីយថាភាពនៃឯកសារ ហើយនិងមិនឲ្យបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាទាំងអស់ដាក់ក្នុងបរិបទច្បាស់លាស់ ហើយនិងសក្ខីកម្មរបស់សាក្សីមកទីនេះ ហើយថែមទាំងឯកសារប្រវត្តិសាស្ត្រ ហើយហាមមិនឲ្យនិយាយអំពីការងារ ឬក៏សារណាទាំងឡាយដែលបានដាក់ជូនតុលាការផងដែរ។

[១១:២១:២៧]

បើសង្ខេបទៅ គឺយើងយល់ឃើញថាការងាកចេញពីគោលដៅ ជាអន្ទាក់មួយដែលថាប្រាប់យើងថា អំពីឯកសារគន្លឹះនេះភាគីអាចនិយាយអំពីពេលនោះ គឺថាមានខណៈមួយដ៏សំខាន់ ដែលគន្លឹះ រកពាក្យឲ្យឃើញដើម្បីនិយាយ។ គឺថាជាការបង្វិលក្បាលយើង ថាយើងអាចនិយាយអំពី កាលនោះលោកស្រីចៅក្រមអ្នកនិយាយ គាត់និយាយថា យើងអាចនិយាយអំពីតម្លៃជាភស្តុតាង។ បាទនេះជាពិតត្រឹមត្រូវណាស់ ខ្ញុំគិតថាការពិភាក្សាម្សិលមិញនេះពុំមែនជាការជជែកតទល់គ្នាអំពីតម្លៃជាភស្តុតាងទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះក្នុងពេលតែមួយ នៅពេលដែលនៅក្នុងអនុស្សរណៈពីមុន ទាក់ទងទៅនឹងកិច្ចសវនាការរៀបចំសវនាការលោកប្រធានបានលើកឡើងថា ចាប់ពីពេលដែលក្រុម ខៀវ សំផន ជំទាស់មិនព្រមចូលរួមក្នុងសវនាការពិភាក្សាអំពីឯកសារគន្លឹះ បាទ ខ្ញុំសូមត្រឡប់មកក្រោយវិញបន្តិច ព្រោះថាគេប្រាប់ខ្ញុំថាខ្ញុំនិយាយលឿនពេក។

[១១:២២:៥៦]

បាទ នៅក្នុងអនុស្សរណៈមួយ ដែលបានជូនដំណឹងទៅដល់ភាគីនៅថ្ងៃទី១៣ មិថុនា ឆ្នាំ២០១៣ លោកប្រធានបានសរសេរថា "បើសិនជាក្រុមការពារលោក ខៀវ សំផន ជំទាស់មិនព្រមចូលរួមក្នុងសវនាការនិយាយពីឯកសារគន្លឹះនេះ អង្គជំនុំជម្រះនឹងមានសិទ្ធិក្នុងការដំឡើង -- បដិសេធក្នុងការឲ្យសរសេរសារណាចំនួនទំព័រហ្នឹងច្រើន ហើយនិងការពិភាក្សាដេញដោលចុងក្រោយ"។ នេះគឺជាការដាក់អន្ទាក់មួយនៅក្នុងកថាខណ្ឌ១០នៃអនុស្សរណៈដដែលនេះ។ លោកប្រធានបានសរសេរថា ទោះបីជាយ៉ាងណាក៏ដោយចំនួនទំព័រសារណាបញ្ចប់ការដេញដោលនោះនឹងមិនត្រូវបានកែប្រែទេ។

ក៏ប៉ុន្តែសំណួរដែលយើងសួរចំពោះខ្លួនយើងវិញនេះ ថាតើៗការជជែកតវ៉ាគ្នាដែលមានចែងនៅមាត្រា៨៧ នៃវិធានផ្ទៃក្នុងនោះយកមកអនុវត្តនៅពេលណា? តើ១០០ទំព័រនេះសម្រាប់រយៈពេល៩ម៉ោងជាងនេះអាចឲ្យយើងការពារលោក ខៀវ សំផន យ៉ាងម៉េចបាន បើសវនាការនេះអស់រយៈពេលជាង២០ខែមកហើយ ហើយមានសាក្សីជាង៩២នាក់មកផ្តល់សក្ខីកម្ម ហើយឯកសារជាង ៦.០០០ឯកសារត្រូវបានទទួលយកជាភស្តុតាង ហើយចំនួនទំព័រវិញរាប់ម៉ឺនទំព័រ។ តើយើងនិយាយពីបញ្ហានេះនៅក្នុង១០០ទំព័រយ៉ាងម៉េច នៅពេលដែល ហើយយើងនិយាយក្នុងរយៈពេល៩ម៉ោង នៅដំណាក់ចុងក្រោយយ៉ាងម៉េច? យើងទាញការសន្និដ្ឋានយ៉ាងម៉េច?

[១១:២៥:០៣]

ពីព្រោះថានៅពេលណាមួយ យើងពីដំបូងមក យើងទុកចិត្តតុលាការនេះ យើងមិនដែលបានប្តឹងឧទ្ធរណ៍អំពីដីកាបំបែកសំណុំរឿងអ្វីនោះទេ។ យើងមិនដែលមានឱកាសក្នុងការនិយាយឲ្យក្នុងលក្ខខណ្ឌសមស្របនោះទេ ក៏ប៉ុន្តែនៅពេលណាមួយ នៅក្នុងតថាភាពយើងត្រូវតែទាញការសន្និដ្ឋានមួយដែលថាក្រុមការងារលោក ខៀវ សំផន ថាត្រូវបានគេបិទមាត់ ហើយការជជែកតទល់គ្នានៅ ដោយមានសាក្សីនិងអ្នកជំនាញយ៉ាងច្រើន ចំនួនទំព័រយ៉ាងច្រើននោះ ទៅជាអត់មានពេលសម្រាប់ការជជែកវែកញែកឲ្យតិតដល់ទៅវិញ។ អ៊ីចឹង ខ្ញុំសួរសំណួរថា តើយើងកំពុងតែស្ថិតនៅក្នុងការកាត់សេចក្តី ឬក៏យ៉ាងម៉េច? ដូចដែលខាងសហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីនិយាយអម្បាញ់មិញ ខ្ញុំនិយាយអម្បាញ់មិញនេះ ថានេះជាសន្និសីទឬក៏យ៉ាងម៉េច? ជាសន្និសីទដែលគេអញ្ជើញ ខៀវ សំផន ឲ្យមកនិយាយ ហើយដែលប្រាប់គាត់ថាមិនមានគ្រោះថ្នាក់អីទេ។ និយាយអំពីដែលកើតមានឡើងកាលពី៤០ឆ្នាំមុននោះ។

[១១:២៦:២៧]

អ៊ីចឹងដើម្បីសង្ខេបទៅ គឺថាយើងៗមិនលាក់ពីគោលជំហរយើងនោះទេ។ យើងតែងតែបញ្ជាក់យ៉ាងច្បាស់ពីគោលជំហររបស់យើង ហើយយើងនឹង -- យើងតែងប្រាប់ថា យើងចង់ទៅណា? យើងវិភាគការជម្រះសេចក្តីនេះយ៉ាងម៉េច? ហើយឥឡូវនេះ ពីរបីសប្តាហ៍ទៀតនេះ យើងនឹងចប់ការជម្រះសេចក្តីហើយ។ ហើយជាពេលដែលយើងត្រូវធ្វើការសន្និដ្ឋានអំពីការសម្រេចចិត្តរបស់តុលាការនោះ។ ខ្ញុំគិតថា ឥឡូវតុលាកាធ្វើសេចក្តីសម្រេចយ៉ាងម៉េច សម្រេចទៅ ហើយយើងៗគិតពីរឿងយើង ការយល់ឃើញរបស់យើងខុសពីគ្នាប៉ុណ្ណឹងឯង។

[១១:២៧:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣២:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញខ្លីទៅបានហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយដោយសង្ខេប។ ខ្ញុំងើបឡើងដើម្បីកែតម្រូវកំណត់ត្រាតុលាការទាក់ទងទៅនឹងនិយាយអំពីបញ្ហាមួយ ខ្ញុំចង់ប្រាកដថា ឲ្យកំណត់ត្រាតុលាការត្រឹមត្រូវ ទាំងភាគីទាំងអស់ និងសាធារណជនផងដែរ។ អ្វីដែលយើងចង់ស្តាប់ គឺត្រូវតែឲ្យមានប្រាកដ ឲ្យច្បាស់ ហើយមានសេចក្តីពន្យល់ដែលមិនត្រឹមត្រូវ ហើយនិងការចោទប្រកាន់ដែលនិយាយថា ជនជាប់ចោទបាទ និយាយលើពាក្យថា ខ្លួនត្រូវបានដាក់អន្ទាក់អីជាដើមហ្នឹង ដោយថាមិនមានមូលដ្ឋានអ្វីសមស្របនោះទេ។

[១១:៣៣:០២]

ខ្ញុំនឹងលើកឡើងពីបញ្ហាមួយចំនួន ជាបឋមមេធាវីការពារក្តីចោទប្រកាន់ថា អង្គជំនុំជម្រះបានទទួលយកនូវឯកសារដែលយោងនៅក្នុងដីកាដំណោះស្រាយដោយមិនអនុញ្ញាឲ្យមានការពិភាក្សា និងដេញដោល។ នេះជាសេចក្តីអះអាងមិនពិតទេ។ អង្គជំនុំជម្រះបានលើកយកឯកសារទាំងអស់នោះដោយពិនិត្យលើសេចក្តីសន្និដ្ឋាននៃភាពជឿជាក់បាន ប៉ុន្តែឯកសារទាំងអស់នោះ តុលាការបានអនុញ្ញាតឲ្យមេធាវីការពារក្តីដាក់ពាក្យជំទាស់សំណើ ហើយបានស្តាប់នូវក្នុងសវនាការ ហើយបានស្តាប់ការឆ្លើយ

តប ហើយនិងធ្វើសេចក្ដីសម្រេចផ្អែកទៅលើហ្នឹង។ ការអះអាងបែបនោះ គឺមិនជាការពិតទេ មិនផ្អែកទៅលើអង្គហេតុទេ។

និយាយអំពីឱកាសក្នុងការឆ្លើយតបទៅនឹងឯកសារនោះវិញ មេធាវីការពារក្ដីប្រកាន់យកបញ្ហា ដោយមានការណែនាំដែលផ្ដល់ឲ្យបញ្ជាក់អំពីតម្លៃភស្ដុតាង គឺអាស្រ័យទៅលើមេធាវីការពារក្ដីក្នុងប្រកាន់យកដូចជាមេធាវីរបស់ នួន ជា ដែរ។ គេ -- គាត់បានទទួលពេល ហើយឲ្យផ្ដល់ពីពេលវេលាដែលគាត់ត្រូវការដើម្បីធ្វើឆ្លើយតប។ តុលាការបានផ្ដល់ពេលឲ្យគាត់ ហើយការអះអាងថា រាំងមិនឲ្យខ្លួនសម្ដែងមតិយោបល់ ការការពារនោះវិញ គឺជាការអះអាងមិនពិតទេ ក្លែងក្លាយនោះដែរ។

[១១:៣៤:៤០]

និយាយអំពីការពង្រីកចំនួនទំព័រនៃឯកសារសារណាវិញ គឺថាយើងមិនឃើញថាមានការទាក់ទងទៅនឹងការកម្រិតអំពីសារណារចុងក្រោយនោះទេ ទាក់ទងទៅនឹងសិទ្ធិរបស់គាត់ របស់ជនជប់ចោទ និងការប្រើសិទ្ធិក្នុងការឆ្លើយតបក្នុងការធ្វើសក្ខីកម្មនោះទេ ដែលនេះជាគោលជំហរមួយដែលបាន -- គាត់បានបដិសេធ។

ចំពោះចំនួន១០០ទំព័រសម្រាប់មេធាវីការពារក្ដី ២០០ទំព័រសម្រាប់សហព្រះរាជអាជ្ញា អ៊ីចឹងគឺថា បើយើងមើលជនជាប់ចោទទាំងពីរ ថាតើចំនួននេះបំពានលើសិទ្ធិដែរឬទេ? ថាតើវាបញ្ជាក់អំពីសមភាពនៃអំណាចដែរឬទេ? ប្រសិនបើជនជាប់ចោទកំណត់ថាការកំណត់ចំនួនទំព័រវារាំងមិនឲ្យការបង្ហាញការការពារក្ដីរបស់គាត់នោះចំពោះមុខតុលាការ ចំពោះភាគី ចំពោះប្រជាជនទាំងអស់ ដែលលោក ខៀវ សំផន បានសន្យាថានឹងផ្ដល់នូវចម្លើយនោះ។

នេះជាឱកាសមួយដែលគាត់បញ្ជាក់ការពារក្ដីក្នុងរឿងក្ដីរបស់គាត់ ដែលគាត់ផ្ដល់នូវចម្លើយរបស់គាត់ទៅនោះ។ ហើយគាត់អះអាងថាត្រូវបានបិទមាត់មិនឲ្យនិយាយ។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងស្ដង់ដារអន្តរជាតិនោះ យើងឃើញថាមេធាវីបានទទួលគឺគ្រប់គ្រាន់ គាត់អាចមានពេលនឹងឆ្លើយបតនឹងការឆ្លើយតប។ ហើយគាត់បានចោទប្រកាន់ដោយមិនត្រឹមត្រូវទៅលើអង្គជំនុំជម្រះ។ ហើយជនជាប់ចោទបានសម្រេចថាគាត់មិនឆ្លើយតប។ នេះជាសិទ្ធិរបស់គាត់។

[១១:៣៦:២០]

ហើយយើងយល់ថាការប្រើសិទ្ធិបែបនេះមិនសមស្របទេ ដូចដែលខ្ញុំបញ្ជាក់នៅខាងដើមអ៊ីចឹង។ ហើយគឺជាសិទ្ធិរបស់គាត់ៗអាចប្រកាន់យកបាន ប៉ុន្តែគាត់មិនបានគោរពតុលាការទេ ហើយក៏គាត់មិន

គោរពដោយចៅក្រមទេ។ ហើយគាត់និយាយមិនត្រឹមត្រូវនៅក្នុងកំណត់ត្រាតុលាការដែលថា សេចក្តីសម្រេចទាំងអស់នោះ គឺបំពានទៅលើនីតិវិធី ហើយនិងវិធានផ្ទៃក្នុង។ ដូច្នេះខ្ញុំសូមបញ្ចប់ត្រឹមប៉ុណ្ណេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បានហើយ ប៉ុណ្ណឹងបានហើយលោកមេធាវី! អង្គជំនុំជម្រះនឹងពិចារណាលើបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៧:៥០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអង្គជំនុំជម្រះប្រគល់ភារៈជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់ជូនលើបញ្ហានេះ ចំពោះភាគី។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អរគុណលោកប្រធាន។ អង្គជំនុំជម្រះបានស្តាប់ទឡ្ហីករណ៍ជាច្រើនអំពីបញ្ហាថាតើលោក ខៀវ សំផន ចង់ប្រើសិទ្ធិរបស់គាត់នៅក្នុងការនៅស្ងៀមមិនឆ្លើយតប ឬទេ? ហើយនិងការយល់ឃើញរបស់គាត់ៗបានបដិសេធមិនឆ្លើយទៅនឹងសំណួរនានា ទោះបីជាអង្គជំនុំជម្រះយល់ស្របទៅនឹងសំណើដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាក៏ដោយ ដើម្បីផ្តល់ពេលវេលាឲ្យគាត់រៀបចំច្រើនក៏ដោយ។ ផ្ទុយទៅវិញគាត់អះអាងថា មានការបំពានសិទ្ធិក្នុងទទួលការជំនុំជម្រះដោយយុត្តិធម៌ ក៏ប៉ុន្តែអង្គជំនុំជម្រះបានប្រគល់ឲ្យលោក ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់នូវឱកាសដូចគ្នាក្នុងការឆ្លើយតបទៅនឹងបញ្ហាទាំងអស់ដែលស្ថិតនៅក្នុងការជំនុំជម្រះ។ ហើយមិនមែនជាការលើកលែងតែមូលហេតុនៃការបដិសេធមិនប្រើសិទ្ធិក្នុងការឆ្លើយនោះទេ។

[១១:៣៩:២៤]

ឥឡូវនេះ ចំណុចយើងឈានដល់ចំណុចមួយដែលថាលោក ខៀវ សំផន ហើយនិងមេធាវីការពារក្តីរបស់គាត់មានឱកាសដែលបានកំណត់ទុក ហើយនិងជូនដំណឹងដល់ភាគីរួចមកហើយ ដើម្បីឆ្លើយតបទៅនឹងឯកសារគន្លឹះទាំងឡាយដែលសហព្រះរាជអាជ្ញាបានបង្ហាញ ឬក៏ឲ្យលើកឡើងនូវឯកសារគន្លឹះរបស់ខ្លួន។

លោកប្រធានបានស្នើខ្ញុំឱ្យអញ្ជើញមេធាវីលោក ខៀវ សំផន ដើម្បីឱ្យចាប់ផ្ដើមនូវការឆ្លើយតប ឬក៏ការបង្ហាញរបស់ខ្លួន។ សូមអរគុណលោកប្រធាន។

[១១:៤០:១៥]

**លោក អាកឡូវ វែកគែនៈ**

បាទ ចំណុចទី១ ដែលខ្ញុំចង់ធ្វើនោះគឺឆ្លើយតបទៅនឹងសំណើជាលាយលក្ខណ៍អក្សរ -- ជាផ្ទាល់មាត់ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងសវនាការថ្ងៃទី២៤ មិថុនា ឆ្នាំ២០១៣ ដែលសវនាការទាក់ទងទៅនឹងឯកសារគន្លឹះ។ ហើយសំណើដោយផ្ទាល់មាត់របស់លោក រេយ៍ន័រ គឺសុំឱ្យឯកសាររបស់ *"ខាំបូឌីយ៉ា ហ្វាក់ ស៊ីតស៍"* ចុះថ្ងៃទី១៧ មីនា ឆ្នាំ៧៥ ដែលសរសេរឡើងដោយក្រុមប្រឹក្សាសន្តិសុខជាតិអាមេរិកាំង ប៊ីល ខេនឌល ត្រូវបានទទួលយកដោយតុលាការយើងនេះស្របតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងយើងនេះ។ ឯកសារនេះព្រះរាជអាជ្ញាបានបង្ហាញ ហើយមានលេខកូដ D366/7.1.370។ ថ្ងៃទី២៤ មិថុនា ថ្មីៗនេះ លោកស្រី អង់តា ហ្គីសសេ បានជំទាស់នឹងការបង្ហាញឯកសារនេះ ដែលពីមុនមកមិនទាន់បានដាក់ចូលមកបង្ហាញពិភាក្សាដេញដោលនៅទីនេះទេ ហើយដែលតម្រូវឱ្យមានការធ្វើសំណើមួយដាក់ឯកសារនេះ ស្របតាមវិធាន ៨៧(៤)។

អ៊ីចឹងសហព្រះរាជអាជ្ញាកាលនោះគាត់យល់ស្រប ហើយគាត់សុំការអនុញ្ញាតក្នុងការធ្វើសំណើដោយផ្ទាល់មាត់ក្នុងការដាក់ឯកសារនេះ។ ហើយអង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើសំណើដោយផ្ទាល់មាត់។ តុលាការបានជូនដំណឹងដល់យើងថាយើងនឹងអាចឆ្លើយតបនៅពេលក្រោយ។

[១១:៤២:៣៧]

នេះអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅថ្ងៃទី២៤ មិថុនា ឆ្នាំ២០១៣ គឺនៅទំព័រ៨៥, ៨៦ នៃប្រតិចារឹក ហើយនៅម៉ោង១៥:១០នាទីទៅដល់ ១៥:១២នាទី។ សហព្រះរាជអាជ្ញាលើកឡើងថាឯកសារនេះមិនមាននៅក្នុងកំណត់ហេតុ កំណត់ត្រាជើងទំព័រនៃដីកាដំណោះស្រាយទេ។ អ៊ីចឹងអ្វីដែលខ្ញុំអាចធ្វើបាននោះគឺសុំដាក់ឯកសារនេះអនុលោមទៅតាមវិធាន៨៧(៤) ដើម្បីជាប្រយោជន៍យុត្តិធម៌។

ជាសង្ខេប គាត់សរសេរបន្តទៀតមានឧទាហរណ៍ចំនួន១៥ ដែលមានចំណងជើងថា "ការភ័យរន្ធត់នឹងកុម្មុយនីស្តនៅកម្ពុជា" មានឧទាហរណ៍ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ ការកាប់សម្លាប់មនុស្ស ហើយនិងដែលមានលើកអំពីរឿងរ៉ាវរបស់ជនភៀសសឹក ហើយដែលមានបោះពុម្ពផ្សាយនៅភ្នំពេញប៉ុស្តិ៍ ហើយនិងវ៉ាស៊ីនតោន និងកាសែតមួយចំនួនទៀត ហើយនិងរបាយការណ៍របស់ស្ថានទូត

អាមេរិក ហើយនិងកាសែតឡាវផងដែរ។ បើតាមយើង -- សហព្រះរាជអាជ្ញា ក៏បន្តយ៉ាងដូច្នេះ "ឯកសារនេះមានភាពពាក់ព័ន្ធខ្លាំងណាស់នៅក្នុងសវនាការយើងនេះ ការកាត់សេចក្ដីយើងនេះ។ អ៊ីចឹងខ្ញុំគិតថាយើងមានមូលដ្ឋានក្នុងការដាក់ឯកសារនេះហើយ"។ សូមបញ្ចប់ការដកស្រង់។

[១១:៤៤:១៤]

ឥឡូវសព្វថ្ងៃនេះ យើងសូមជំទាស់ទៅនឹងសំណើដោយផ្ទាល់មាត់របស់សហព្រះរាជអាជ្ញាដោយយោងលើមូលហេតុដូចតទៅនេះ។ ទី១ គឺសំណើថ្ងៃទី២៤ មិថុនា ឆ្នាំ២០១៣ នេះមិនស្របតាមទម្រង់បែបស្នើនោះទេ។ ទី២ គឺលក្ខខណ្ឌទទួល សំណើដែលត្រូវគោរពទៅតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងយើងនេះមិនត្រូវបានបំពេញ។ ដូច្នេះសំណើគាត់នេះមិនឆ្លើយតបទៅនឹងវិធានទេ។ ការស្នើដែលឈរលើមូលដ្ឋានមាត្រា៨៧(៤) នេះត្រូវតែធ្វើជាមុន មិនមែននៅនាទីចុងក្រោយយ៉ាងដូច្នេះទេ។ វិធានទី២ គឺថាការសំណើ -- សំណើទាំងអស់នេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ មិនមែនដោយផ្ទាល់មាត់ទេ។

ចំណុចទី៣ វិធានទី៣ ទៀតនោះគឺឯកសារដែលត្រូវយកមកដាក់មកពិភាក្សាក្នុងសវនាការត្រូវតែដាក់ជាបីភាសាជាផ្លូវការនៅតុលាការយើងនេះ។ បាទ ដូច្នេះហើយទាក់ទងនឹងរយៈពេលកាលកំណត់នោះ ខ្ញុំសូមដកស្រង់ប្រតិចារឹកនៅថ្ងៃទី១៨ កក្កដា ២០១២ ឯកសារ E1.91.1 ទំព័រទី៧ ទី៨ -- ៦, ៧ (សូមទោស) មានលើកឡើងដូចតទៅនេះ អង្គជំនុំជម្រះលើកឡើងថា "អង្គជំនុំជម្រះបានប្រាប់ ជូនដំណឹងហើយថាភាគីទាំងឡាយដែលចង់ប្រើឯកសារ ហើយដែលឯកសារទាំងអស់នេះមិនទាន់ទទួលលេខកូដ E3 នោះទេ ឬក៏មិនទាន់មាននៅក្នុងបញ្ជីឯកសារណាមួយដែលស្នើដើម្បីដាក់មកជជែកតវ៉ានោះទេ អ៊ីចឹងត្រូវឯកសារទាំងអស់នេះត្រូវតែគោរពតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង"។

[១១:៤៦:២៨]

អង្គជំនុំជម្រះក៏បានលើកឡើងផងដែរថា "ស្របតាមគោលការណ៍នៃការកាត់ក្ដីដោយយុត្តិធម៌ លក្ខខណ្ឌជាអប្បបរមានោះដើម្បីទទួលយកឯកសារមួយដែលមិនទាន់បានដាក់ចូល ឬក៏បង្ហាញពិភាក្សាត្រូវតែបង្ហាញ ឬក៏ធ្វើសំណើក្នុងពេលសមស្របដើម្បីដាក់ចូលទៅក្នុងសំណុំរឿង ហើយនិងត្រូវសុំបង្ហាញនៅក្នុងសវនាការឲ្យសមស្របទៅតាមបទប្បញ្ញត្តិដែលមានចែង"។

បាទ ខ្ញុំសូមដកស្រង់ទាក់ទងទៅនឹងសម្រង់អម្បាញ់មិញនេះទៀត នៃសម្រង់នៃអនុស្សរណៈថ្ងៃទី ៣ សីហា ចុះឆ្នាំ២០១២ នៅកថាខណ្ឌ -- នៅទំព័រ២២ កថាខណ្ឌ២២ ដែលមានចែង សរសេរអំពីកាលវិភាគនៃសវនាការ។ វគ្គដែលខ្ញុំចង់អាននេះគឺដូចតទៅនេះ៖ "សំណើដែលស្នើឡើងនៅនាទីចុងក្រោយ

តាមវិធាន៨៧(៤) ចាប់ពីពេលនេះទៅនឹងត្រូវបដិសេធចោល"។ បាទ សូមបញ្ចប់ការដកស្រង់។

អង្គជំនុំជម្រះបានអនុវត្តវិធាននេះជាច្រើនដងមកហើយ។ ឧទាហរណ៍ដូចនៅពេលដែល -- ឧទាហរណ៍ ពេលដែលមានសំណើឲ្យសាក្សីមួយផ្តល់សក្ខីកម្មរបស់យើងហ្នឹង គឺថាយើងត្រូវបាន បដិសេធចោល។ ឯកសារ E1/104.1 ទំព័រ២-៣ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២។ អង្គជំនុំជម្រះបាន បដិសេធសំណើចោល គឺសវនាការថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ឯកសារ E1/129.1 ទំព័រ៧៨-៧៩។

[១១:៤៨:៥១]

ហើយសំណើនេះបានធ្វើឡើងនៅមុនថ្ងៃដែលសាក្សីមួយមកផ្តល់សក្ខីកម្ម។ សំណើនេះត្រូវបាន បដិសេធចោល។ ហើយសំណើមួយទៀតដែលស្នើនៅថ្ងៃសវនាការតែម្តង គឺសវនាការស្តីអំពីការសុំឲ្យ ដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំ។ គឺពេលនោះគឺជាសម្រង់របស់សៀវភៅរបស់ចៅក្រម ម៉ាសែល ឡឺម៉ុងដ៍ ដែលគេបាន -- ដែលសហព្រះរាជអាជ្ញាបានបង្ហាញអម្បាញ់មិញនេះថា សៀវភៅ នេះគឺត្រូវបានបដិសេធរួចមកហើយ ហើយពេលសហព្រះរាជអាជ្ញានិយាយនេះបាននិយាយទៅកាន់ លោក សុន អរុណ ថា ក៏ប៉ុន្តែតាមពិតទៅការប្រាប់បែបនេះកុហកទេ ពីព្រោះថាមិនទាន់សេចក្តីសម្រេច ជាផ្លូវការរបស់តុលាការដែលបដិសេធក្នុងការបង្ហាញសៀវភៅនេះនោះទេ។ ហើយការបង្ហាញសៀវភៅ នេះវាមានសារៈសំខាន់ណាស់ក្នុងការនិយាយអំពីតម្លៃជាភស្តុតាង។

យើងនឹងត្រឡប់មកនិយាយអំពីតម្លៃភស្តុតាង ដែលទទួលបាននៅដំណាក់កាលស៊ើបអង្កេតនៅ ពេលក្រោយ ហើយនិងនិយាយអំពីលក្ខខណ្ឌនៃការប្រមូលបានភស្តុតាងនេះ។

អ៊ីចឹងរហូតដល់ពេលនេះៗមួយសល់តែពីរបីសប្តាហ៍ទៀតនេះ ចប់ការជម្រះសេចក្តីហើយ យើង មិនទាន់មានព័ត៌មានអីច្បាស់លាស់នោះទេ ហើយមន្ត្រីតុលាការជាន់ខ្ពស់នោះបានបញ្ជាក់ប្រាប់ថា សំណើ សុំហ្នឹងនឹងត្រូវបានបដិសេធ។ ឧទាហរណ៍ទី៣ គឺថាសំណើយើងបានស្នើសុំជាមុន ក៏ប៉ុន្តែត្រូវបាន បដិសេធចោល។

[១១:៥០:៥១]

ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីលក្ខណៈជាលាយលក្ខណ៍អក្សរនៃសំណើ ដែលធ្វើស្រប តាមវិធាន៨៧(៤) ថ្ងៃទី២៣ ឧសភា ឆ្នាំ២០១២ ឯកសារ E1/75.1 ទំព័រ២៥ ពេលនុំងគឺលោកប្រធាន ជាអ្នកនិយាយ។ បាទ ខ្ញុំសូមដកស្រង់លោកប្រធាន "បាទ ខ្ញុំសូមជម្រាបជូនថា ចំពោះការបង្ហាញ ឯកសារថ្មីដែលត្រូវយកមកជជែកតវ៉ានៅក្នុងសវនាការត្រូវតែធ្វើឡើងជាលាយលក្ខណ៍ ស្របតាមវិធាន

៨៧(៤)។ អង្គជំនុំជម្រះនឹងមិនឆ្លើយតប និងមិនធ្វើសេចក្ដីសម្រេចទៅលើការស្នើជាលាយលក្ខណ៍ -- ដោយផ្ទាល់មាត់នោះទេ”។

នៅថ្ងៃទី២៤ កក្កដា ២០១២ ឯកសារ E1/95 ពេលនោះលោកស្រីចៅក្រម ខាតវ៉ាយថ៍ និយាយ គឺនៅទំព័រ១១៩ នៃប្រតិចារឹក “បាទ សូមអរគុណលោកប្រធាន” ពាក្យសម្ដីរបស់លោកស្រីចៅក្រម ខាយវ៉ាយថ៍។ លោកស្រី ខាតវ៉ាយថ៍ និយាយបន្តទៀត៖ “លោកត្រូវតែធ្វើសំណើជាលាយលក្ខណ៍អក្សរ ហើយមូលហេតុដែលយើងសុំឲ្យសរសេរជាលាយលក្ខណ៍អក្សរនេះ គឺថាដោយយោងទៅតាមវិធាននៃភាពទទួលយកបាននៃឯកសារ។ ហើយយើងត្រូវតែឲ្យឯកសារនោះត្រូវបកប្រែជាភាសាផ្លូវការផងដែរ ដើម្បីឲ្យយើងអាចធ្វើសេចក្ដីសម្រេចបាន”។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់។

[១១:៥២:៤១]

បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយ -- ចូលមកនិយាយអំពីចំណុចទី៣ ទាក់ទងទៅនឹងភាពការតម្រូវឲ្យមានជាបីភាសានៃឯកសារនៅចំពោះមុខ អ.វ.ត.ក យើងនេះ។ បាទ ខ្ញុំសូមលើកមកយោងទៅអនុស្សរណៈរបស់តុលាការលើបញ្ជីសាក្សី ដែលនឹងកោះមកផ្ដល់សក្ខីកម្មរយៈដែលត្រូវដាក់ឯកសារនោះ ឬក៏ភស្តុតាងត្រូវឆ្លើយតបទៅនឹងឯកសារ E109/5 នេះគឺជាអនុស្សរណៈចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១១ ឯកសារ E3 -- E131/1 ទំព័រទី៣។ អង្គជំនុំជម្រះលើកឡើងថា “ឯកសារដែលមកបង្ហាញនៅក្នុងឯកសារនេះត្រូវតែមានទាំងបីភាសាដែលជាភាសាផ្លូវការរបស់អ.វ.ត.ក ហើយភាគីដែលស្នើសុំនោះត្រូវធ្វើយ៉ាងណាឲ្យមានការបកប្រែជាបីភាសា ដែលភាសាផ្លូវការនេះទៅតាមពេលសមស្រប”។

ហើយឆ្ងាយជាង -- ហើយក្រោមហ្នឹងបន្តិច អង្គជំនុំជម្រះបានសុំឲ្យភាគីទាំងអស់បង្ហាញថា “ខ្លួនចង់បង្ហាញឯកសារណាខ្លះក្នុងដំណាក់កាលទី១ ហើយនិងធ្វើយ៉ាងណាត្រូវឲ្យឯកសារនេះបានបកប្រែ។ ឯកសារនេះត្រូវបញ្ជូនទៅ -- ធ្វើយ៉ាងណាឲ្យឯកសារនេះបញ្ជូនទៅ អាយ.ធី.យូ អង្គភាពបកប្រែ ហើយធ្វើយ៉ាងណាបកប្រែឲ្យបានក្នុងរយៈពេលសមស្រប។ ហើយភាគីដែលលទ្ធភាពក្នុងការប្រើឯកសារនេះនឹងមិនត្រូវបានរឹតត្បិត បើសិនមិនមានការបកប្រែទេ ក្នុងរយៈពេលសមស្របនោះ”។ បាទ សូមបញ្ចប់ការដកស្រង់នៃអនុស្សរណៈ E131/1។

[១១:៥៤:០១]

បាទ សំណើមួយទៀត សំណើរបស់សហព្រះរាជអាជ្ញានៅសវនាការថ្ងៃទី២៤ មិថុនា ឆ្នាំ ២០១៣។ នោះសំណើហ្នឹង គឺស្នើនៅនាទីចុងក្រោយ គឺនៅថ្ងៃសវនាការតែម្ដង ហើយដោយផ្ទាល់មាត់

ទៀតផង។ ឯកសារដែល ឯកសារហ្នឹងមានតែជាភាសាអង់គ្លេសទេ។ ឯកសារហ្នឹងមាន២៦ទំព័រ។ ដូច្នេះបើអនុលោមតាមវិធានដែលអនុវត្តន៍នៅតុលាការយើងនេះ ខ្ញុំសូមរំឭកថា សំណើនេះគ្រាន់ -- ត្រូវតែបដិសេធចោលតែប៉ុណ្ណោះ។ ហើយសំណើនេះ ត្រូវតែបដិសេធចោលដោយសារលក្ខខណ្ឌកំណត់នៅក្នុងវិធាន៨៧(៤) នោះមិនត្រូវបានបំពេញ។ លក្ខខណ្ឌទទួលឯកសារតម្រូវ លក្ខខណ្ឌតម្រូវនោះមិនត្រូវបានបំពេញ។ ខ្ញុំសូមដកស្រង់វិធាននេះ "នៅក្នុងអំឡុងពេលសវនាការតាមការផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬក៏តាមការស្នើតាមរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬក៏ស្តាប់ចម្លើយបុគ្គលម្នាក់ៗក្នុងឋានៈសាក្សី ឬទទួលនូវភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។

ភាគី គ្រប់ភាគីដែលបានស្នើត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬក៏ភស្តុតាងដែលស្នើសុំនោះពុំអាចរកបាននៅពេលមុនការចាប់ផ្តើមជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាពដូចគ្នានឹង--"

[១១:៥៧:១៥]

លោកប្រធាន ឲ្យខ្ញុំបន្តទៀត ឬក៏សម្រាកសិន។ ព្រោះថាខ្ញុំត្រូវការពេលវេលាយូរទៀតដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមក្នុងសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៥៨នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការធ្វើអត្ថាធិប្បាយ ឬក៏ធ្វើការកត់សម្គាល់ជំទាស់ទៅនឹងបណ្តារឯកសារគន្លឹះ ដែលបានដាក់បង្ហាញដោយក្រុមតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលនៃសវនាការដាក់ឯកសារកន្លងមក។

សូមអញ្ជើញ!

**លោក អាកទ្បូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ មុននឹងបន្តឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាននៃឯកសារ D366/7.1.366។ ខ្ញុំចង់បំភ្លឺចំណុចមួយដែលខ្ញុំបានលើកឡើងនៅព្រឹកមិញនេះពីរដងរួចមកហើយ ហើយវាដែលហាក់ដូចជាមិនសូវច្បាស់។ គឺជាសំណើពីរ ខ្ញុំបាននិយាយតែមួយ។ អ៊ីចឹងហើយបានជាមិនច្បាស់ តាមពិតទៅគឺសំណើពីរ ដើម្បីឲ្យអង្គជំនុំជម្រះទទួលយកសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេតលោក ម៉ាសែល ឡឺម៉ុងដ៍។

[១៣:៣៤:៥១]

អ្វីដែលខ្ញុំចង់បញ្ជាក់នោះ គឺថាយើងបានដាក់សំណើលើកទី១ សម្រាប់សវនាការសុំដោះលែងលោក ខៀវ សំផន នៅក្រៅឃុំ គឺឯកសារលេខ E280 សំណើនេះត្រូវបានច្រានចោលនៅថ្ងៃទី១១ ខែមេសា ២០១៣ ដែលលើកហេតុផលថាបានដាក់យឺតពេល។ គឺដាក់នៅមុនសវនាការស្តីអំពីការសុំដោះលែងឲ្យនៅក្រៅឃុំ១ថ្ងៃ។

ហើយបន្ទាប់មកទៀត មានសំណើទី២ទៀតពីខាងយើងខ្ញុំ គឺដើម្បីសុំដាក់ឲ្យជជែកដេញដោលដែលជាឯកសារពាក់ព័ន្ធទៅនឹងសៀវភៅរបស់លោកចៅក្រម ម៉ាសែល ឡឺម៉ុងដ៍។ សំណើនេះគឺផ្អែកទៅលើលទ្ធភាពដែលសៀវភៅនេះអាចបង្ហាញឲ្យឃើញពាក់ព័ន្ធទៅនឹងការវាយតម្លៃ ការជជែកពិភាក្សា និងការដេញដោលទៅលើអ្វីដែលពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត គឺលេខ E280/2។ នេះជាសំណើដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ។ ហើយសំណើនេះមិនបានទាន់បានច្រានចោលនៅឡើយទេ ក៏ប៉ុន្តែនៅក្នុងឧបសម្ព័ន្ធ៤ គឺជាតារាងមួយដែលបានផ្ញើជូនរួមជាមួយនឹងអ៊ីម៉ែលរបស់លោកស្រី ស៊្វហ្សាន

ឡែម ដែលជាមន្ត្រីច្បាប់ជាន់ខ្ពស់។ អង្គជំនុំជម្រះបានលើកឡើងថា ខ្លួនមានបំណងនឹងបដិសេធសំណើនេះចោល ដោយសារតែសំណើនេះមិនមានភាពពាក់ព័ន្ធ។ ដូច្នេះមកទល់នឹងថ្ងៃនេះ យើងមិនទាន់ដឹងច្បាស់លាស់នៅឡើយទេ ថាតើអង្គជំនុំជម្រះបដិសេធ ឬក៏យ៉ាងណានេះ។

នេះជាការបញ្ជាក់ជូនដ៏សំខាន់ដល់អង្គជំនុំជម្រះ ពីព្រោះអម្បាញ់មិញនេះនៅពេលដែលខ្ញុំលើកឡើងនោះ យើងមានអារម្មណ៍ហាក់ដូចជាថាមានសំណើតែមួយ។ តែតាមពិតគឺខ្ញុំសំដៅទៅលើសំណើទាំងពីរនេះ។

[១៣:៣៦:៥៥]

ឥឡូវនេះ ខ្ញុំបន្តពាក្យពេចន៍របស់ខ្ញុំដែលបានបញ្ឈប់នៅមុនពេលឈប់សម្រាកទទួលទានអាហារថ្ងៃត្រង់ គឺខ្ញុំនិយាយអំពីលក្ខណៈវិនិច្ឆ័យនៃភាពអាចទទួលយកបាន ដែលតម្រូវដោយវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដែលមានន័យថាសំណើដែលធ្វើឡើងដោយផ្អែកតាមវិធាននេះ មិនត្រឹមតែត្រូវមានសំអាងហេតុនោះទេ គឺត្រូវតែបង្ហាញថាមានការខិតខំប្រឹងប្រែង ខ្នះខ្នែង ហើយឯកសារទាំងអស់នោះត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការទទួលយកតាមវិធាន៨៧(៤)។

ពាក់ព័ន្ធទៅនឹងភាពគ្មានសំអាងហេតុ និងភាពការខ្វះការប្រឹងប្រែងនោះ ខ្ញុំបានបញ្ជាក់ពីព្រឹកមិញនេះហើយ ដែលថាខាងសហព្រះរាជអាជ្ញាបានផ្តល់សំអាងហេតុពាក់ព័ន្ធទៅនឹងសំណើរបស់ខ្លួនជូនអង្គជំនុំជម្រះ ហើយសំអាងហេតុតែមួយគត់ដែលយើងអាចទាញចេញពីសំណើនោះ គឺថាដើម្បីតែផលប្រយោជន៍នៃយុត្តិធម៌។

ដូច្នេះយើងដូចជាមិនឃើញមានអីលើសពីហ្នឹងទេ គឺថាគ្រាន់តែដើម្បីផលប្រយោជន៍នៃយុត្តិធម៌ ហើយអត់មានការពន្យល់ថាហេតុអ្វីទេ។ ហើយខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញានោះមិនបានពន្យល់ ឬក៏ថាតាមធ្យោបាយណាដែលខ្លួនបានរកឃើញឯកសារនោះទេ។ អត់មានបញ្ជាក់ជូនទាល់តែសោះ។ ហើយដែលបញ្ជាក់ -- យើងអាចសួរបានថាតើរកឯកសារហ្នឹងឃើញឆាប់ជាងហ្នឹងឬក៏យ៉ាងម៉េច? យើងមិនដឹងទេ ពីព្រោះថានេះជាវិធានរបស់អង្គជំនុំជម្រះដែលបានកំណត់ថាឲ្យបញ្ជាក់ឲ្យបានច្បាស់។

[១៣:៣៨:៤៨]

ហើយនៅក្នុងឯកសារ E260 កថាខណ្ឌ៥ ហើយនិងឯកសារ E290 កថាខណ្ឌ២២-២៣ នោះបានបញ្ជាក់ថា ភាគីដែលដាក់សំណើនោះ ត្រូវតែផ្តល់ជូននូវអង្គជំនុំជម្រះឲ្យឃើញនូវភស្តុតាងនៃការ

ទទួលយកបាន គឺថាដោយសារតែខ្លួនមិនអាចរកបាននៅមុនពេលបើកសវនាការ ឬក៏មិនអាចរកបាន ទោះបីជាខ្លួនខិតខំប្រឹងប្រែងរកយ៉ាងណាក៏ដោយ។ នេះគឺមានលក្ខខណ្ឌលើកលែងពាក់ព័ន្ធទៅនឹងការតម្រូវបែបនេះ។

ចំពោះ ហើយជាពិសេសគឺថានៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឲ្យមានការពិនិត្យទៅលើភស្តុតាងដែលត្រូវដាក់ជូនអង្គជំនុំជម្រះនោះ ហើយវាមានបញ្ហាអំពីទំនាក់ទំនងជិតស្និទ្ធ ហើយអង្គជំនុំជម្រះក៏បានទទួលយកនូវខ្សែភាពយន្តឯកសារ នៅក្នុងឯកសារ E90 ហើយនៅក្នុងនោះបានបញ្ជាក់ថាវាមានទំនាក់ទំនងជិតស្និទ្ធ។

ដូច្នេះយើងមើលឃើញថា សំណើរបស់សហព្រះរាជអាជ្ញាមិនអាចធៀបទៅនឹងស្ថានភាពនេះបានទេ។ ហើយក៏យើងមិនអាចចាត់ទុកថាសំណើនេះជាអញ្ញត្តិកម្មបាននោះទេ ពាក់ព័ន្ធទៅនឹងការខិតខំប្រឹងប្រែងហើយនិងការរកឯកសារនោះ។

[១៣:៤០:១០]

ជាក់ស្ដែងគឺអង្គជំនុំជម្រះគឺ -- សុំទោស! គឺសហព្រះរាជអាជ្ញាបានដឹងអំពីរបាយការណ៍របស់កណ្ដាល គឺថាគាត់ដឹងតាំងពីពេលមុនបើកសវនាការពាក់ព័ន្ធទៅនឹងឯកសារគន្លឹះនេះទៅទៀត។ គឺមុនពេលដែលបើកសវនាការនៅក្នុងសប្ដាហ៍នៃខែមិថុនា គឺនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ដែលជាថ្ងៃដាក់សំណើនោះ ពីព្រោះថានៅក្នុងខែឧសភា ឆ្នាំ២០១០ ឬក៏នៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ គឺឯកសារលេខ D366 គឺសហព្រះរាជអាជ្ញាបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតដាក់បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿង។ ហើយនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ នោះ ដូច្នេះមានន័យថាការដាក់នេះគឺថាតាំងពី៣ឆ្នាំមកហើយការដាក់ឯកសារសុំឲ្យទទួលយកឯកសារនោះ។ ហើយសហព្រះរាជអាជ្ញាក៏មិនបានពន្យល់ថាហេតុអីបានជាឯកសារនេះមិនមាននៅក្នុងបញ្ជីដំបូងរបស់ខ្លួនតាមវិធាន៨៧(៤) ដែលត្រូវបានដាក់កាលពីខែមេសា ឆ្នាំ២០១១។ ដូច្នេះខ្ញុំសូមរំឭកផងដែរថា សវនាការលើឯកសារពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមត្រូវបានទាមទារឬក៏ស្នើសុំដោយសហព្រះរាជអាជ្ញា។

[១៣:៤១:៤៥]

ដូច្នេះយើងឃើញថា ច្បាស់ណាស់ថាសហព្រះរាជអាជ្ញាគឺថា គាត់ខ្វះនូវការខិតខំប្រឹងប្រែងនៅក្នុងការបង្ហាញអំពីឯកសារ។

ខ្ញុំចូលទៅនិយាយអំពីភាពអាចទទួលយកបានយោងតាមវិធាន៨៧(៣) ដែលបានបញ្ជាក់ថា

ឯកសារនឹងមិនត្រូវបានទទួលយកទេ ប្រសិនបើមានលក្ខណៈស្នើសុំជាន់គ្នា ឬមិន សមស្របបញ្ជាក់ -- សម្រាប់បញ្ជាក់អំពីអង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ ពាក់ព័ន្ធទៅនឹងចំណុចនេះ ខ្ញុំចង់គូសបញ្ជាក់ថា ជាបឋមឯកសារនេះជាឯកសារស្កេន គឺជាឯកសារដែលថតចម្លងតាមប្រព័ន្ធកុំព្យូទ័រ។ ដូច្នេះយើងខ្ញុំគ្មានលទ្ធភាពក្នុងការពិនិត្យភាពអាចជឿជាក់បាន និងយថាភាពនៃឯកសារនេះទេ។ ឯកសារនេះគឺជាឯកសារជាន់គ្នា ត្រួតគ្នា ពីព្រោះថាសហព្រះរាជអាជ្ញាបានបញ្ជាក់ថាឯកសារនេះមានបង្ហាញពីការជម្លៀសដោយបង្ខំ និងការសម្លាប់មនុស្ស ហើយនិងរឿងរ៉ាវរបស់ជនភៀសខ្លួន។

ដូច្នេះខ្ញុំគិតថា អង្គជំនុំជម្រះបានស្តាប់នូវឧទាហរណ៍ជាច្រើនពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ការសម្លាប់មនុស្ស ហើយនិងរឿងរ៉ាវរបស់ជនភៀសខ្លួនហើយ។ ដូច្នេះអង្គជំនុំជម្រះអាចយល់ឃើញថា ឯកសារនេះជាឯកសារស្នើសុំជាន់គ្នា។

[១៣:៤៣:២៤]

ជាចុងក្រោយ ខ្ញុំចង់គូសបញ្ជាក់ផងដែរថា ឯកសារនេះមានព័ត៌មានមិនអព្យាក្រឹតពីព្រោះឯកសារនេះចេញមកពីអង្គការសន្តិសុខអាមេរិក ដែលនិយាយពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលទំនងជាកើតឡើងនៅប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥។ ដូច្នេះឯកសារនេះមិនមានបញ្ជាក់អំពីការវិភាគដោយមិនលម្អៀងនោះទេ។ ហើយអង្គការដែលធ្វើឯកសារនេះគឺថាគាត់មានគោលដៅជាក់លាក់ក្នុងការបង្ហាញនូវការយល់ឃើញរបស់ខ្លួនទៅលើអង្គហេតុ ឬក៏ការផ្សព្វផ្សាយព័ត៌មានដែលតាមការយល់ឃើញរបស់ខ្លួន។ ដូច្នេះឯកសារនេះមានលក្ខណៈលម្អៀង។ ឧទាហរណ៍ដូចជា របាយការណ៍បានបញ្ជាក់ថា ការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនោះ គឺធ្វើឡើងដោយមានការគាំទ្រពីសម្តេច នរោត្តម សីហនុ។ ឬរបាយ-ការណ៍បានបដិសេធថាអាមេរិកាំងមិនបានចូលរួមក្នុងការវាយប្រហារទម្លាក់សីហនុនោះទេ។

ដូច្នេះ ឯកសារនេះត្រូវបានសរសេរឡើងដោយបុគ្គលមួយរូបដែលធ្វើការឲ្យក្រុមប្រឹក្សាសន្តិសុខអាមេរិកាំង អាមេរិកនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដែលនៅពេលនោះ គឺថាសហរដ្ឋអាមេរិកបានចូលរួមយ៉ាងសកម្មជួយដល់ខាងកងទ័ព លន់ នល់ ហើយអ្នកនិពន្ធនៃឯកសារនេះ ក៏មិនត្រូវបានកោះហៅដោយអង្គជំនុំជម្រះឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះដែរ។

ដូច្នេះ យើងអាចនិយាយបានថា ឯកសារនេះមិនផ្តល់ប្រយោជន៍អ្វីដល់សវនាការយើងនេះទេ ដោយសារតែក្នុងនោះគឺថាមានការសរសេរអំពីប្រភពនៃកុម្មុយនីស្តហ្នឹង គឺថាយើងអត់ដឹងច្បាស់ទេ មិនមានប្រភពច្បាស់លាស់ពាក់ព័ន្ធទៅនឹងភាពសាហាវឃោរឃៅនៃខ្មែរ -- របស់ពួកខ្មែរក្រហមនោះទេ។

ដូច្នេះការលើក -- ឯកសារនេះនិយាយតែពីការរៀបរាប់អំពីរឿងរ៉ាវរបស់ជនភៀសខ្លួន ហើយនិង អត្ថបទកាសែតតែប៉ុណ្ណោះ។ ដូច្នេះដោយសារហេតុផលនេះហើយ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះជំទាស់ នូវការស្នើសុំរបស់សហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារ D366/7.1.366 នេះ។

[១៣:៤៦:១០]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវឯកសារមួយទៀត។ បាទ ខ្ញុំអត់ដឹងទេលោកប្រធាន គឺមកពី អម្បាញ់មិញវាដាច់ខ្លួនឯង មីក្រូ។

ឥឡូវនេះ ខ្ញុំលើកឡើងនូវចំណុចមួយទៀតដែលពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងប្រាំ ដែល យើងឯកភាពគ្នាហៅតាំងពីដីកាដំណោះស្រាយមកនោះ គឺថាយើងហៅថាជាគោលនយោបាយដែល អនុវត្តដោយខ្មែរក្រហមក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ គឺដីកាដំណោះស្រាយបានបញ្ជាក់ថាប្រាំ ហើយ យើងបានមើលប្រតិចារឹកនៃសវនាការទៅលើឯកសារគន្លឹះ ជាពិសេសគឺពាក្យពេចន៍របស់ដើមបណ្ដឹង រដ្ឋប្បវេណី គាត់លើកឡើងថាមានច្រើនជាងហ្នឹងទៅទៀត មិនមែនមានតែត្រឹមប្រាំទេ។ ចំពោះខ្ញុំហ្នឹង ខ្ញុំអត់ដែលឮទេ ក៏ប៉ុន្តែពួកគាត់ហ្នឹង គាត់បញ្ជាថាអ៊ីចឹង នៅពេលដែលគាត់បង្ហាញអំពីឯកសារគន្លឹះហ្នឹង ដើមបណ្ដឹងរដ្ឋប្បវេណីថាមានគោលនយោបាយច្រើនជាងហ្នឹងទៅទៀត។

[១៣:៤៧:៣១]

អង្គជំនុំជម្រះបានសម្រេចបំបែកដីកាដំណោះស្រាយជាការជំនុំជម្រះច្រើនវគ្គ។ ហើយវគ្គទី១ នៃ ការជំនុំជម្រះនេះ គឺមានគោលដៅក្នុងការពិនិត្យទៅលើអង្គហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋ-កម្មដែលត្រូវបានប្រព្រឹត្តដោយអនុវត្តទៅនឹងគោល -- ដោយអនុវត្តគោលនយោបាយពីរដែលមាន បង្ហាញនៅក្នុងដីកាដំណោះស្រាយ គឺការជម្លៀសប្រជាជនដោយបង្ខំ និងការប្រព្រឹត្តចំពោះអតីតមន្ត្រី រដ្ឋការនៃសាធារណរដ្ឋខ្មែរ។

ចំពោះយើង ការវិភាគទៅលើព្រឹត្តិការណ៍តាំងពីមានការសម្រេចមកនោះ ហើយមិនមែនខ្ញុំតែ ម្នាក់ឯងដែលជាអ្នកនិយាយនោះទេ គឺថាអង្គជំនុំជម្រះមានការលំបាកតាំងពីខ្លួនសម្រេចបំបែកដីកា -- តាំងពីខ្លួនសម្រេចបំបែកនីតិវិធីមក គឺថាយើងមិនដឹងច្បាស់ថាមានលក្ខខណ្ឌៗអ្វីខ្លះ ហើយមានគោល នយោបាយអ្វីខ្លះដែលអាចលើកឡើងនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១។

ឥឡូវនេះ ខ្ញុំចង់និយាយអំពីគោលនយោបាយដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងយើង នេះ គឺការបង្កើតសហករណ៍ និងជំរំការងារ ការប្រព្រឹត្តចំពោះខ្មាំងខាងក្នុង និងខាងក្រៅ ការធ្វើទុក្ខបុក

ម្នេញជនជាតិចាម ជនជាតិខាងពុទ្ធសាសនិកជន ជនជាតិចាម ហើយនិងការគ្រប់គ្រងទៅលើការរៀប អពាហ៍ពិពាហ៍។

មូលហេតុដែលអង្គជំនុំជម្រះមិនបានផ្តល់នូវស្ថិរភាពគតិយុត្តដែលយើងត្រូវតែទទួលបាន។ នេះ ជាការវិភាគផ្ទាល់ខ្លួនរបស់ខ្ញុំ គឺដោយសារតែមានបញ្ហាដែលកើតចេញមកពីជម្រើសរបស់អង្គជំនុំជម្រះ ក្នុងការបំបែកនីតិវិធី គឺមានការសម្រេចពិភាក្សាដេញដោលទៅលើទម្រង់នៃការទទួលខុសត្រូវសហ ឧក្រិដ្ឋកម្មរួម។ ហើយភាពមិនច្បាស់លាស់គិតយុត្តិនោះក៏វាកើតចេញមកពីសំណើជាបន្តបន្ទាប់របស់ សហព្រះរាជអាជ្ញា ដើម្បីស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី។ អង្គជំនុំជម្រះតុលាការកំពូលបាន វិភាគរួចទៅហើយ ហើយការដេញ ជជែកដេញដោលរបស់យើងចេះតែបន្តវិវត្តន៍ទៅមុខ។

[១៣:៥០:២៦]

**ប្រធានអង្គជំនុំ៖**

សូមផ្អាកបន្តិចលោកមេធាវី! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក្រោកឈរឡើងដើម្បីជំទាស់នូវការអះអាងរបស់មេធាវីការពារ ក្តីមិនត្រូវ -- ដែលគាត់ការឆ្លើយ មិនបានឆ្លើយទៅនឹងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាទេ ដូចដែលមេធាវី សុន អរុណ ត្រូវបានណែនាំដោយតុលាការផងដែរ គឺថាមិនគប្បីលើកឡើងដូច្នេះទេ។ លោក វែកគែន ក៏ដូចគ្នាដែរ គឺថាយើងយល់ហើយ គឺយើងត្រូវតែឆ្លើយតបទៅនឹងឯកសាររបស់សហ ព្រះរាជអាជ្ញា ហើយនិងផ្តល់ឱកាសឲ្យមេធាវី ហើយនិងជនជាប់ចោទដើម្បីឆ្លើយតប។ ហើយប៉ុន្តែគាត់ លើកឡើងពីភាពមិនប្រាកដនៃដំណើរការនីតិវិធី ហើយខ្ញុំមិនធ្វើសេចក្តីសន្និដ្ឋានទេ ប៉ុន្តែខ្ញុំជំទាស់។ ប៉ុន្តែ សូមកត់សម្គាល់ថា និយាយអំពីដីកាបំបែកសំណុំជាដើមហ្នឹង វិសាលភាពគឺត្រូវបានបែងចែកទាក់ទង ទៅនឹងកថាខណ្ឌមួយចំនួននៅក្នុងដីកាដំណោះស្រាយ ជាពិសេសទៅនឹងវិធានបទមួយចំនួន។

ខ្ញុំជំទាស់ទៅនឹងការលើកឡើងរបស់មេធាវី ប៉ុន្តែនេះជាកម្មវត្ថុដែលគាត់អាចនឹងប្តឹងឧទ្ធរណ៍ទៅ អង្គជំនុំជម្រះសាលាកំពូល មិនអាចលើកឡើងនៅពេលនេះនោះទេ។ សូមអរគុណ។

[១៣:៥២:០០]

**លោក អាកទូរ វែកគែន៖**

ការជំទាស់របស់សហព្រះរាជអាជ្ញានឹងផ្តល់ឱកាសដល់ខ្ញុំ ក្នុងការគូសបញ្ជាក់ភាពមិនច្បាស់

លាស់មួយទៀត ភាពមិនប្រាកដប្រជាមួយទៀត គឺវាពាក់ព័ន្ធនឹងយើងខ្ញុំចាប់តាំងពីយើងព្យាយាមក្នុងការរៀបចំពាក់ព័ន្ធទៅនឹងសវនាការនៃឯកសារគន្លឹះ គឺភាពមិនច្បាស់លាស់ដែលបង្កើតឡើងដោយថាជាអ្វីដែលយើងត្រូវតែនិយាយនៅថ្ងៃនេះ គឺក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ត្រូវតែនិយាយ។

ខ្ញុំសូមយោងទៅលើពាក្យ ការលើកឡើងពីរ។ ទី១ គឺជាការលើកឡើងរបស់លោកប្រធាននៅពេលបើកសវនាការនេះ លោកប្រធានបានបញ្ជាក់ហើយថា យើងមានឱកាសក្នុងការឆ្លើយតបទៅនឹងឯកសារគន្លឹះដែលបានបង្ហាញកាលពី២សប្ដាហ៍មុនដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយមានការលើកឡើងទី២ មួយទៀត ដែលមានការវិភាគជាលក្ខណៈទូលំទូលាយជាងនេះ គឺអនុស្សរណៈរបស់អង្គជំនុំជម្រះ E288/1/1 ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ហើយនៅកថាខណ្ឌ៦ ដែលបានបញ្ជាក់ថា "អង្គជំនុំជម្រះយល់ព្រមនៅក្រោយពេលសវនាការទៅលើឯកសារគន្លឹះនោះ គឺថាផ្ដល់ពេលកន្លះថ្ងៃដើម្បីឱ្យមេធាវីការពារក្ដី ខៀវ សំផន លើកឡើងអំពីមតិអត្ថាធិប្បាយទៅលើឯកសារដែលលើកឡើងដោយភាគី"។ ខ្ញុំសូមបន្តទៅទៀត៖ "ឬមួយក៏ដើម្បីលើកឡើងអំពីទិដ្ឋភាពនៃឯកសារជាភស្តុតាងផ្សេងទៀតទៅតាមទស្សនៈរបស់លោក ខៀវ សំផន"។ សូមបញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំមិនចង់ធ្វើឱ្យមានការភ្ញាក់ផ្អើលដល់មេធាវីអីផ្សេងទៀតទេ ហើយខ្ញុំក៏មិនចង់តវ៉ាអ្វីច្រើនដែរ។ ដូច្នេះខ្ញុំសូមឱ្យបញ្ជាក់ឱ្យបានច្បាស់ថា តើវិសាលភាពនៃអន្តរាគមន៍របស់ខ្ញុំនេះ វាមានត្រឹមកម្រិតណា? ពីព្រោះថាខ្ញុំមិនដូចជាមិនដឹងទេឥឡូវនេះ។ ខ្ញុំមិនដឹងថា តើគេអនុញ្ញាតឱ្យខ្ញុំនិយាយអ្វីខ្លះនោះទេ។

[១៣:៥៤:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៨:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីជំទាស់ និងការដាក់បង្ហាញឯក -- ការធ្វើអត្ថាធិប្បាយ ហើយនិងកត់សម្គាល់ទៅលើបណ្ដាឯកសារទាំងឡាយដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅថ្ងៃនេះ គឺការអត្ថាធិប្បាយ ឬក៏ការកត់សម្គាល់តបទៅនឹងបណ្ដាឯកសារគន្លឹះដែលបានបង្ហាញដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកកែន ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោក អង្គជំនុំជម្រះស្នើខ្ញុំបញ្ជាក់ជូនលោកដូចតទៅ។ សវនាការនៅរសៀលនេះ គឺដើម្បីអនុញ្ញាតឲ្យលោកក្នុងការបង្ហាញនូវមតិអត្ថាធិប្បាយរបស់លោកទៅនឹងឯកសារ ដែលបានបង្ហាញដោយសហព្រះរាជអាជ្ញា ក៏ដូចជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាលពីសវនាការចុងក្រោយស្តីអំពីឯកសារ។

[១៣:៥៩:៣០]

សវនាការនេះក៏សម្រាប់ឲ្យលោកផ្តល់នូវការបង្ហាញអំពីឯកសាររបស់លោក ដែលលោកចង់បង្ហាញជូនអង្គជំនុំជម្រះ។ ហើយដោយសារតែលោកមិនទទួលយកនូវឱកាសដែលបានផ្តល់ជូនលោកកាលពីមុនក្នុងការបង្ហាបទអត្ថាធិប្បាយទៅលើឯកសារគន្លឹះ ដែលបានបង្ហាញកាលពីសវនាការមុនអំពីឯកសារនោះ លោកក៏មានលទ្ធភាពក្នុងធ្វើមតិអត្ថាធិប្បាយទៅលើឯកសារទាំងមូលដែលត្រូវបានបង្ហាញតាំងពីពេលចាប់ផ្តើមសវនាការស្តីអំពីឯកសារនេះមក។ ដូច្នេះ ខ្ញុំគិតថាអ្វីដែលបានជម្រាបជូនលោកនេះគឺថាច្បាស់ហើយ។

**លោក អាកទួរ វែកកែន៖**

បាទ លោកចៅក្រម គឺច្បាស់ណាស់។ ខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះថា នៅក្នុងពេលសវនាការឯកសារគន្លឹះដែលបានប្រព្រឹត្តទៅកាលពីខែកមរា កុម្ភៈ មីនា ឆ្នាំ២០១២ គឺភាគីមិនអាចឆ្លើយតបបានទេនៅពេលនោះ គឺមានតែជនជាប់ចោទទេដែលមានសិទ្ធិឆ្លើយតប។ ហើយឆ្លើយតបនោះ គឺថានៅក្នុងការកម្រិតព្រំដែនទៀត។ នេះជាការឆ្លើយតបទៅនឹងសំណួរដែលបានសួរមកកាន់ខ្ញុំអម្បាញ់មិញនេះ។

[១៤:០១:០៥]

ការវិភាគស្ថានភាពរបស់ខ្ញុំនោះ គឺថានៅពេលដែលអង្គជំនុំជម្រះបញ្ជាក់ជាសាធារណៈថា យើងមិនចង់ឆ្លៀតទទួលយកឱកាសដែលបានផ្តល់ជូនមកយើងកាលពីសវនាការមុនៗ ក្នុងការឆ្លើយតបក្នុងកម្រិតព្រំដែនដែលកំណត់ដោយអង្គជំនុំជម្រះទៅលើឯកសារគន្លឹះ ដែលបង្ហាញដោយភាគីផ្សេងទៀតនោះ។ តាមពិតនោះ គឺថាលទ្ធភាពក្នុងការឆ្លើយតប ប្រតិកម្មតបបែបនេះគឺមិនមានទេ។ នេះគឺជាមូលដ្ឋាននៃបញ្ហាហើយ ដែលខ្ញុំព្យាយាមលើកឡើងអម្បាញ់មិញនេះ។

បន្ទាប់មកទៀត ខ្ញុំចង់បញ្ជាក់ជូនសហព្រះរាជអាជ្ញាផងដែរថា សវនាការនៅថ្ងៃនេះ ពាក់ព័ន្ធនឹង

សហឧក្រិដ្ឋកម្មរួម។ ដូច្នេះច្បាស់ណាស់ថា បញ្ហាដែលខ្ញុំកំពុងតែលើកឡើងទាំងអស់នេះ គឺវានិយាយអំពីការប្រព្រឹត្តពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានបែងចែកនៅក្នុងសវនាការវគ្គផ្សេងៗគ្នា។

[១៤:០២:២២]

ហើយជាចុងក្រោយដើម្បីឆ្លើយតបទៅនឹងអ្វីដែលអង្គជំនុំ -- ដែលសហព្រះរាជអាជ្ញាលើកឡើងអម្បាញ់មិញនេះថាគឺថាថ្ងៃនេះ យើងមានឱកាសក្នុងការលើកឡើងនៃការកត់សម្គាល់ទៅលើឯកសាររបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាលពីសវនាការលើកមុនៗស្តីពីឯកសារគន្លឹះនោះ។ ខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះថាឯកសារ៨៤៧ ត្រូវបានបង្ហាញនៅក្នុងសវនាការទាំងបួនស្តីពីឯកសារគន្លឹះ។ គឺថាកាត់៨៩ នៅពេលទី១ ហើយ១៣៩ នៅសវនាការទី២។ ២៨២នៅសវនាការទី៣ និង៣៣៧ ឯកសារនៅក្នុងសវនាការស្តីពីឯកសារលើកចុងក្រោយ។

ដូច្នេះ នៅពេលដែលចៅក្រមប្រាប់ថា ផ្តល់ឱកាសឲ្យខ្ញុំនៅថ្ងៃនេះ ក្នុងការឆ្លើយតបក្នុងរយៈពេលតែ២ម៉ោង១០នាទីទៅនឹងការបង្ហាញឯកសារ៨៤៧នោះ។ ខ្ញុំគិតថា គឺដូចជាការប្រាប់ខ្ញុំថាឲ្យជជែកពិភាក្សាទៅលើតម្លៃជាភស្តុតាងនៃឯកសារ៦.៥០០ ក្នុងរយៈពេល២០ខែ ហើយនិងមានដើម -- មានសាក្សី និងមានអ្នកជំនាញ៩២នាក់ ក្នុងរយៈពេលតែប៉ុណ្ណឹង ហើយនិងឲ្យខ្ញុំដេញដោលពិភាក្សាចុងក្រោយតែត្រឹម៩ម៉ោង៤០នាទី។ ដូច្នេះ ខ្ញុំមិនមែនជាមនុស្សវេទមន្តទេ ខ្ញុំមិនអាចធ្វើអភូតហេតុអីបានត្រឹមតែរយៈកាលប៉ុណ្ណឹង រយៈពេលប៉ុណ្ណឹងទេ។

[១៤:០៤:២៦]

ដូច្នេះ បើសិនជាអង្គជំនុំជម្រះឲ្យខ្ញុំបន្តការនិយាយអន្តរគមន៍ពាក់ព័ន្ធទៅនឹងគោលនយោបាយនោះ ខ្ញុំគិតថាវាស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះសេចក្តីយើង។ ដូច្នេះ ខ្ញុំគិតថាមិនគួរមានការជំទាស់នោះទេ។ ដូច្នេះ យើងឃើញហើយថាឯកសារ៨៤៧នោះ គឺថាមិនអាចធ្វើបានទេ ក្នុងត្រឹមតែរយៈពេល២ម៉ោងជាងនេះនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ដើម្បីកំណត់ត្រាផង ជាពិសេសសំណើដែលខ្ញុំបានស្តាប់កាលព្រឹកមិញនេះ គឺពាក់ព័ន្ធទៅនឹងការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះរបស់

លោក ខៀវ សំផន ដោយយុត្តិធម៌។

[១៤:០៥:១៧]

អង្គជំនុំជម្រះមានពេលវេលាជាច្រើនដើម្បីឲ្យធ្វើការទាំងឆ្លើយតប ក៏ដូចជាឆ្លើយតបទៅនឹងការធ្វើបទបង្ហាញក៏ដូចជាការជំទាស់តវ៉ាទៅនឹងឯកសារដែលដាក់ដោយតំណាងព្រះរាជអាជ្ញា ជាជាងការចំណាយពេលលើកឡើងតែឯកសារមួយ ចំណាយពេលវាឥតប្រយោជន៍នេះ។

ដូច្នេះសំណើរបស់យើងខ្ញុំយល់ឃើញថាមិនមានអ្វីពាក់ព័ន្ធទៅនឹងឯកសារសោះ។ តាមដែលខ្ញុំយល់គឺថាគាត់ហាក់បីជាដូចជាចង់ស្នើសុំពេលវេលាបន្ថែម ដើម្បីដោះស្រាយទៅលើឯកសារ៤៤៩នេះទាំង -- ដោយសារខ្ញុំ ហើយខ្ញុំមុនដំបូងខ្ញុំយល់ឃើញថា ១ថ្ងៃកន្លះគឺវាជាការគ្រប់គ្រាន់ហើយ ហើយអាចនឹងផ្តល់ពេលវេលាបន្ថែមទៀត។ យើងខ្ញុំអាចនឹងស្តាប់នូវការធ្វើបទបង្ហាញ ក៏ដូចការជំទាស់តវ៉ាទៅលើឯកសារ។ ហើយជាពិសេសឯកសារដែលយើងខ្ញុំបានដាក់ជូនដើម្បីធ្វើការជំទាស់តវ៉ានេះ។ ដើម្បីចៀសវាងការលើកឡើងថាការខ្វះឱកាស ការខ្វះពេលវេលា។

ដូច្នេះ យើងខ្ញុំស្នើសុំដល់អង្គជំនុំជម្រះឲ្យពិចារណាទៅលើពេលវេលាផ្តល់ទៅដល់មេធាវីការពារក្តីក្រុមនេះ បើអង្គជំនុំជម្រះធ្វើទៅបាន។ សូមអរគុណ។

[១៤:០៦:៣០]

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ បាទ ខ្ញុំសូមរំឭកទៅសហព្រះរាជអាជ្ញាថា ការកំណត់នៃពាក្យថាសវនាការលើឯកសារគន្លឹះនេះ គឺជាឯកសារដែលមានលក្ខណៈគរុកោសល្យ គឺជាសវនាការដែលធ្វើមកដើម្បីជូនដំណឹងដល់សាធារណជនអំពីគោលគំនិតរបស់ភាគីរៀងខ្លួន ហើយគឺជាហើយកាលពីសវនាការមុនៗនោះក៏យ៉ាងដូច្នេះដែរ ក៏ប៉ុន្តែកាលណោះគេហាមឃាត់មិនឲ្យមេធាវីធ្វើការៗកត់សម្គាល់អ្វីទេលើឯកសារដ៏ច្រើននោះ។ អង្គាល់នោះ គាត់បានប្រាប់យើងថាគោលបំណងនៃសវនាការទាំងអស់នេះ គឺមានលក្ខណៈជាគរុកោសល្យបង្រៀន។ ប្រាប់ថាន៎ែឲ្យប្រាប់ឲ្យអង្គជំនុំជម្រះដឹង ហើយនិងឲ្យសាធារណជនដឹងអំពីអ្វីដែលកើត ដែលកំពុងតែដំណើរការនៅទីនេះ អំពីទំហំនៃឯកសារ។ យើងបានសរសេរនៅក្នុងសំណើយើង។ ខ្ញុំមិនដឹងថាសហភាតាខ្ញុំបានអានដែរឬទេ សហព្រះរាជអាជ្ញានេះ។ ខ្ញុំបានសូមការបំភ្លឺជាបន្តបន្ទាប់ដដែលៗសុំ -- ខ្ញុំដឹងថាសវនាការនៃឯកសារគន្លឹះនេះប្រហែលជាសំខាន់ហើយ ក៏ប៉ុន្តែពុំមានៗចំណងពាក់ព័ន្ធអីជាមួយនឹងការជម្រះសេចក្តីនោះទេ។ ហើយ

ដោយសារហេតុនេះហើយ បានជាយើងមិនពុំមានការពិភាក្សាឲ្យចំៗកន្លែងលើតម្លៃជាភស្តុតាង។

[១៤:០៨:២៤]

ម្សិលមិញហ្នឹងក៏ដូចជាហ្នឹងដែរ គឺថាមានការជំទាស់ពីសំណាក់សហព្រះរាជអាជ្ញាទៅលើការងារត្រួតពិនិត្យលើតម្លៃភស្តុតាងរបស់ក្រុមមេធាវីលោក នួន ជា ហើយរាល់ដងគឺថាត្រូវបានព្រះរាជអាជ្ញាទំនាស់រហូតទាក់ទងទៅនឹងតម្លៃជាភស្តុតាង។ ហើយការងារនេះ ជាការងាររបស់អ្នកជំនាញ ត្រូវតែបង្ហាញបរិបទ ត្រូវមកធ្វើការប្រៀបធៀប ត្រូវធ្វើការលើទំហំនៃភស្តុតាងទាំងមូលតែម្តង។ ហើយអាស្រ័យហេតុដូច្នេះហើយ បានយើងតែងតែនិយាយថា ការងារនេះជាការងារពិភាក្សាអំពីតម្លៃជាភស្តុតាង ហើយការពិភាក្សាហ្នឹងត្រូវតែបង្ហាញឲ្យចប់ គឺថាឧទាហរណ៍ដូចថាស្អែក ឬក៏ៗថ្ងៃមុខទៀត បើសិនជាគេកាត់ខ្ញុំនោះ អាចថ្ងៃស្អែកទៀតមិនដឹង។

សាក្សីមកទីនេះ ឧទាហរណ៍ដើម្បីនិយាយអំពីអ្វី? មកនិយាយអំពីភស្តុតាងដែលពួកគេបានប្រមូលផ្តុំមកជារាប់ឆ្នាំមកហើយ។ ហើយយើងនៅទីនេះ យើងឥឡូវនេះយើងត្រូវពិភាក្សាអំពីតម្លៃឯកសារទាំង៨០០ជាងហ្នឹង ហើយដោយមិនទាន់ទាំងបានឮ មិនបានស្តាប់លោក ស្ទីវ ហេដឌ័រ ផង។ ហើយយើងចង់ស្តាប់គាត់ហ្នឹង ដោយសារគាត់ចង់ស្តាប់អំពីរបៀបគាត់ប្រមូលភស្តុតាងហ្នឹងហើយ។

[១៤:០៩:៥៩]

អ៊ីចឹងមិនត្រឹមត្រូវទេ ក្នុងការធ្វើការដូច្នេះ គឺថាស្តាប់សវនាការពីឯកសារគន្លឹះនេះ មិនមែនជាការជម្រះសេចក្តីទេ។ ការកាត់សេចក្តីគឺថាការពិភាក្សាអំពីតម្លៃជាភស្តុតាង ពីភស្តុតាងទាំងអស់ក្រោយពេលដែលគេបានស្តាប់សក្ខីកម្ម ឬក៏ប្រមូលភស្តុតាងអស់ហើយ។ ហើយនៅពេលដែលចៅក្រមកំណត់ឲ្យខ្ញុំសរសេរត្រឹមតែ១០០ទំព័រ សារណាចុងបញ្ចប់នេះហើយឲ្យខ្ញុំតែជាង៩ម៉ោងនេះ ខ្ញុំមិនដឹងថាធ្វើយ៉ាងម៉េចឲ្យកាត់ក្តីកើតនោះទេក្នុងលក្ខខណ្ឌបែបនេះនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ចារីក៖**

ខ្ញុំសូមអភ័យទោសលោកប្រធានចំពោះការឡើងរំខាន ប៉ុន្តែខ្ញុំមិនមានបំណងចង់ឆ្លើយតបនោះទេ។ ខ្ញុំមានសំណើសុំ បើសិនជាមេធាវីការពារក្តីស្នើសុំពេលវេលាបន្ថែម ស្នើសុំអង្គជំនុំជម្រះតែម្តងទៅ។ ហើយបើចង់ធ្វើការបង្ហាញឯកសារប្រហែលជាក្រោយពីសួរសាក្សីបន្ទាប់នោះគឺថាអាចនឹងធ្វើការ

ដាក់ស្នើពាក្យស្នើសុំពេលវេលាបន្ថែមដើម្បីមានឱកាសឆ្លើយតបទៅនឹងឯកសារជាង៨០០នេះ។ ដោយគិតទៅ១ថ្ងៃកន្លះ មេធាវីការពារក្តីបើមិនប្រើពេលឲ្យមានប្រយោជន៍ទេ ហើយបែរជាទៅធ្វើផ្សេង ហើយបើមិនដូច្នោះទេ គឺថាស្នើសុំអង្គជំនុំជម្រះសុំពេលវេលាបន្ថែមទៅ។ កុំឲ្យចេះតែលើកឡើងថាខ្លួនខ្វះឱកាសក្នុងការលើកឡើងជំទាស់តវ៉ាទៅលើឯកសារ។ គឺមេធាវីការពារក្តីស្នើសុំត្រង់ៗតែម្តង ឬក៏ថាអង្គជំនុំជម្រះគឺថាអាចនឹងពិចារណាទៅតាមនោះ ជាជាងការប្រើពេលវេលាចេះតែនិយាយពីនេះពីនោះ។

[១៤:១១:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៤:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន អង្គជំនុំជម្រះបានផ្តល់ពេលវេលាឲ្យលោកដើម្បីឲ្យលោកឆ្លើយតបទៅនឹងឯកសារគន្លឹះ ហើយយើងឥឡូវនេះយើងមានអារម្មណ៍ថា ឃើញថាលោកនៅតែត្អូញត្អែរដដែលៗតាំងពីម្សិលមិញមកនេះ។ យើងចង់ដឹងថា ហេតុអ្វីបានជាពីមុនមកលោកមិនដែលធ្វើសំណើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងឯកសារគន្លឹះ? ហើយចង់សួរថាហេតុអ្វីក៏ថ្ងៃនេះលោកចង់ឆ្លើយតបទៅនឹងសំណើរបស់ព្រះរាជអាជ្ញាដើម្បីទទួលបានពេលវេលាបន្ថែម ដើម្បីធ្វើការកត់សម្គាល់ទៅលើឯកសារគន្លឹះទាំងអស់ ឬក៏យ៉ាងម៉េច? សំណួររបស់យើងខ្ញុំ។

**លោក អាកទួរ វែកគែន៖**

លោកចៅក្រម ខ្ញុំមានអារម្មណ៍ថា យើងដូចជាស្តាប់គ្នាមិនសូវបាន។ រាប់ខែមកហើយ ជាច្រើនដងហើយ គឺខ្ញុំបានធ្វើសំណើជាច្រើនដើម្បីពន្យល់ ហើយនិងសុំការបំភ្លឺ។ នេះមិនមែនជាលើកទី១ទេ។ ប្រហែលជាលោកចៅក្រមគិតថា ខ្ញុំនិយាយដដែលៗក៏មិនដឹង ការពិតហើយខ្ញុំនិយាយដដែលៗ គឺចង់និយាយថា បើយើងមិនបានសុំពេលេវេលាឆ្លើយបន្ថែម ឆ្លើយទៅលើឯកសារគន្លឹះរបស់សហព្រះរាជអាជ្ញា ហើយនិងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះ យើងមិនសុំដោយសារសវនាការលើឯកសារគន្លឹះនេះមិនមែនជាផ្នែកមួយនៃសវនាការទេ នៃការជំនុំជម្រះសេចក្តីទេ ក៏ប៉ុន្តែតុលាការកំណត់សវនាការនេះឡើងដើម្បីក្នុងគោលបំណងពិភាក្សាគ្នាតែប៉ុណ្ណឹងទេ។

[១៤:១៦:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី យើងយល់អ្វី ពាក្យដែលលោកចង់និយាយហើយ។ ខ្ញុំគ្រាន់តែចង់សួរថា តើលោកចង់ទទួលយកសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីឲ្យបន្ថែមពេលវេលាឲ្យលោកក្នុងការធ្វើការកំណត់សម្គាល់ទៅលើឯកសារគន្លឹះ។ ការកំណត់សម្គាល់របស់លោកមិនមានប្រយោជន៍អ្វីទេ។ យើងយល់ច្បាស់ហើយ អ្វីដែលលោកចង់និយាយនោះ។ អ៊ីចឹងសូមឲ្យតែឆ្លើយឲ្យតែច្បាស់តែប៉ុណ្ណឹងទេ។

**លោក អាកឡូរ វែកគែន៖**

បាទចម្លើយរបស់យើងខ្ញុំខ្លីទេ។ យើងបានសុំពេលវេលាបន្ថែមដើម្បីឲ្យការជជែកតទល់គ្នាអំពីភស្តុតាងហ្នឹងឲ្យប្រព្រឹត្តឡើង--

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

លោកមេធាវី ខ្ញុំមិនចង់និយាយពីពេលវេលាបន្ថែមនៅពេលជជែកនៅថ្ងៃចុងក្រោយទេ។ ខ្ញុំសួររឿងឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

**លោក អាកឡូរ វែកគែន៖**

លោកចៅក្រម លោកប្រធានបានចុះហត្ថលេខាលើអនុស្សរណៈមួយ។ គាត់សរសេរថា បើសិនជាយើងជំទាស់មិនចូលរួមក្នុងពិភាក្សាលើសវនាការឯកសារគន្លឹះទេ។ អង្គជំនុំជម្រះនឹងបដិសេធមិនផ្តល់ពេលវេលាបន្ថែមនៅពេលធ្វើការសន្និដ្ឋានចុងក្រោយ។ ដូច្នេះទំនាក់ទំនងនោះ គឺថាអង្គជំនុំជម្រះបានបង្ហាញខ្លួនឯងហើយនៅក្នុងអនុស្សរណៈនោះ គឺថាសវនាការលើឯកសារគន្លឹះនេះគឺថាជាសវនាការសម្រាប់អ្នកកាសែតទេ យើងមិនចង់មកលេងល្ខោននៅកន្លែងនេះទេ។ យើងត្រូវការពេលវេលាដើម្បីពិភាក្សាគ្នា ដើម្បីជជែកតវ៉ាគ្នា ដើម្បីសរសេរសារណារបស់យើង ដើម្បីពិភាក្សាអំពីភស្តុតាងទាំងអស់។

[១៤:១៨:៥១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន លើកណាតែមេធាវីការពារក្ដីកែប្រែ គឺថាខ្ញុំមើលទៅដូចជាពួកគាត់មិនបានស្នើសុំពេលវេលាបន្ថែមនោះទេ។ គេបានបដិសេធក្នុងការបង្ហាញរឿងក្ដីរបស់ខ្លួនទៅវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន បន្តការកត់សម្គាល់ ឬក៏អត្ថាធិប្បាយរបស់លោកលើបណ្ដាឯកសារគន្លឹះដែលបានដាក់បង្ហាញដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលដំណើរការសវនាការក្នុងសំណុំរឿង០០២/០១ នេះបន្ត។

**លោក អាកទូរ វែកគែន៖**

បាទ ដើម្បីចៀសវាងកុំឲ្យគេកាត់ផ្ដាច់ខ្ញុំនេះ កាត់សម្ដីខ្ញុំ។ ខ្ញុំសូមឲ្យការជំទាស់របស់សហព្រះរាជអាជ្ញាពីដើមនេះ គឺថាចង់ដឹងជាអនុញ្ញាតឲ្យខ្ញុំបន្តនិយាយអំពីគោលនយោបាយទាំងប្រាំ ហើយនិងសហឧក្រិដ្ឋកម្មរួម ឬក៏យ៉ាងម៉េច? ដោយសារមានការជំទាស់ពីដើម ពីសហព្រះរាជអាជ្ញា។ ខ្ញុំមិនចង់បន្តធ្វើបទបង្ហាញទៀត ហើយក្រោយមកមានសហព្រះរាជអាជ្ញាជំទាស់ទៀត។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន អង្គជំនុំជម្រះបានបើកសវនាការជាច្រើនណាស់មកហើយអំពីការបំបែកដំណើរការនីតិវិធី ហើយនិងអំពីផលប៉ះពាល់នៃការបំបែកដំណើរការនីតិវិធីនេះ ហើយយើងបានស្ដាប់ការកត់សម្គាល់ទូទៅទាក់ទងទៅនឹងផលប៉ះពាល់នៃការបំបែក និងការពិនិត្យលើគោលនយោបាយទាំងអស់នេះហើយ។ ហើយយើងគ្រាន់តែចង់ដឹងថា តើលោកមានការកត់សម្គាល់អ្វីទៅលើឯកសារដែលត្រូវបានបង្ហាញ ហើយនិងការកត់សម្គាល់ជាក់លាក់ណាមួយទៅលើឯកសារទាំងនេះ បើសិនជាលោកមាន លោកអាចធ្វើបាន បើលោកមិនមានទេយើងចប់ត្រឹមហ្នឹងតែម្ដង។

**លោក អាកទូរ វែកគែន៖**

ខ្ញុំចង់ធ្វើ ក៏ប៉ុន្តែមិនពេលឥឡូវនេះទេ មិនមែនឥឡូវនេះទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងបានន័យថាលោកពុំមានការកត់សម្គាល់ឥឡូវនេះទេ ចំពោះឯកសារដែលត្រូវបានបង្ហាញទាំងប៉ុន្មាននោះ។

**លោក អាកទូរ វែកគែន៖**

ខ្ញុំមានច្រើនណាស់ ក៏ប៉ុន្តែឥឡូវនេះមិនមែនជាពេលវេលាដែលត្រូវធ្វើទេ ពីព្រោះថាភស្តុតាងមិនទាន់ត្រូវបានបង្ហាញទាំងស្រុងទេ ហើយតុលាការបានប្រាប់ថា សវនាការលើឯកសារគន្លឹះនេះគឺជាឯកសារពិភាក្សាតទល់គ្នាអំពីតម្លៃភស្តុតាង។ អ៊ីចឹងគឺជាការគិតអំពីគោលការណ៍តែប៉ុណ្ណោះឯង។ ខ្ញុំជំទាស់ ឬជាគោលការណ៍។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៤:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន អង្គជំនុំជម្រះចង់ដឹងថា តើមូលដ្ឋានផ្លូវច្បាប់របស់លោកជាក់លាក់នេះ ដើម្បីឲ្យលោកអាចធ្វើការអះអាងថា ថ្ងៃនេះមិនមែនជាពេលវេលាដែលត្រូវជជែកតវ៉ាគ្នាអំពីតម្លៃជាភស្តុតាងនៃឯកសារគន្លឹះដែលត្រូវបានបង្ហាញរហូតមកដល់ពេលនេះៗ។ ខ្ញុំចង់ដឹងអំពីមូលដ្ឋានផ្លូវច្បាប់ជាក់លាក់ ពីព្រោះថាអង្គជំនុំជម្រះត្រូវបាន -- បានបញ្ជាក់ប្រាប់ហើយថាជាសវនាការដើម្បីជជែកតវ៉ាគ្នា។ ហើយខ្ញុំមិនយល់ថា ហេតុអ្វី យើងមិនយល់ថាហេតុអ្វីបានជាលោកមិនចង់ធ្វើ មិនចង់ធ្វើការកត់សម្គាល?

**លោក អាកទូរ វែកគែន៖**

បាទ លោកចៅក្រម ខ្ញុំរកឯកសារ ប៉ុន្តែឥឡូវវិធាន៨៧(២) នេះតាមវិធាននេះខ្ញុំមិនដឹងថាហេតុអីក៏នៅសវនាការទី៤ លើឯកសារគន្លឹះនេះភ្លាមៗហ្នឹង ក្នុងខណៈដែលមេធាវីរបស់ នួន ជា ហ្នឹងត្រូវបានទទួលទណ្ឌកម្មនៅពេលដែលត្រូវថា ក្នុងពេលវិភាគអំពីតម្លៃភស្តុតាងនោះកាលពីម្សិលមិញ។ ហើយនៅ

ពេលសវនាការបីមុនៗនោះ ក៏អត់តែ -- មានឲ្យជជែកតវ៉ាគ្នាដែរ បង្ហាញ ឬក៏វិភាគភស្តុតាងនោះដែរ ក៏ប៉ុន្តែភ្លាមៗសវនាការទី៤ សល់២អាទិត្យទៀតចប់ការជំនុំជម្រះសេចក្តី ស្រាប់តែប្រាប់ថាឥឡូវពេលហ្នឹងត្រូវការនិយាយអំពីតម្លៃភស្តុតាង ហើយការពិនិត្យមើលភស្តុតាងមិនទាន់បានធ្វើចប់ផង។ យើងមិនទាន់មួលទេ ហើយយើងពុំទាន់បានទទួលសេចក្តីសម្រេចរបស់តុលាការទាក់ទងនឹងការដាក់ឯកសារជាង ១.៥០០ ហើយនិងការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់។

[១៤:២៦:៥៥]

ហើយម្សិលមិញនេះ យើងក៏មិនទាន់បានចម្លើយតបនឹងពាក់ព័ន្ធនឹង ម៉ាកសែល ឡឺម៉ុងដ៍ ហើយនិងសេចក្តីសម្រេចមួយចំនួនទាក់ទងទៅនឹងការទទួលយកបាននៃឯកសារ ដែលភាគីបានស្នើសួរនោះ ហើយគ្រាន់តែឥឡូវនេះបែរជានៅថ្ងៃសវនាកាទី៤ នោះបែរមកធ្វើហាក់ដូចជាក្នុងរយៈពេលកន្លះថ្ងៃហ្នឹងត្រូវតែពិភាក្សាដេញដោលគ្នាលើឯកសារទាំង៨៥០ -- ដែល ៨៤៧។ អ៊ីចឹងខ្ញុំថា ទោះបីជាខ្ញុំមេធាវីដែលថានៅក្រោមកម្រិតដែលគេៗហៅថា មេធាវីជាអាជីពដែលថាអាចមកការពារក្តីនៅទីនេះបានក៏ដោយ ក៏ប៉ុន្តែទោះយ៉ាងក្តីខ្ញុំមិនអាចទទួលយកបានការបកស្រាយដោយភ័ន្តច្រឡំបានដែរ អំពីវិធាន៨៧នៃវិធានផ្ទៃក្នុងដែលចែងថា -- នៅវិធាន៨៧(២) “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយភស្តុតាងទាំងអស់នេះត្រូវការឆ្លងកាត់ការដេញដោល។ ហើយរហូតដល់ពេលនេះមិនដែល មិនទាន់មានការពិភាក្សាដេញដោលគ្នានោះទេ អំពីឯកសារនេះ។ ហើយអង្គជំនុំជម្រះបានប្រើសវនាការលើភស្តុតាងគន្លឹះនេះដើម្បីហាមបន្ទប់បង្អាក់មិនឲ្យមានការដេញដោលគ្នាទៅវិញ។ ហើយសហព្រះរាជអាជ្ញាវិញបាននិយាយថា “អ្ហេ! លោកមិនដែលបានទាមទារការដេញដោលគ្នាផង!”។ ហើយខ្ញុំបានធ្លាប់និយាយហើយ ធ្លាប់ឆ្លើយហើយៗពីរឿងហ្នឹង។ ថាភាគីសុំថា សុំពេលវេលាសុំទំព័រច្រើននៅពេលដែលសារណាចុងក្រោយបញ្ចប់នោះ ហើយខ្ញុំមិនយល់ទេ ដែលថាហេតុអីក៏គេថាគោលជំហរខ្ញុំមិនច្បាស់។ តាមពិតសំណើខ្ញុំសុទ្ធតែច្បាស់ទាំងអស់។

[១៤:២៩:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំដូចជាស្ងាត់មកដល់ពេលនេះ។ ជាមូលដ្ឋាន គឺដោយសារមានការពិភាក្សារវាងមេធាវី

ការពារលោក ខៀវ សំផន និងសហព្រះរាជអាជ្ញា ហើយនិងចៅក្រមផងដែរ។ ប៉ុន្តែឥឡូវនេះយើងខ្ញុំយល់ថាយើងដល់ដំណាក់កាលមួយដែលមានផលវិបាក ដែលថាយើងត្រូវបានតុលាការមើលឃើញថាការបង្ហាញពី -- ការឆ្លើយតបទៅនឹងឯកសារគន្លឹះនោះ ខ្ញុំឮពាក្យចៅក្រម ឡាវែន៍ ប្រើពាក្យថា “ការសវនាការតទល់ដេញដោលគ្នា”។ ដូច្នេះ វាផ្ទុយពីអ្វីទៅនឹងការឆ្លើយតបរបស់យើង អ្វីដែលយើងយល់។

ដំណើរការនីតិវិធីនេះគឺថាកា លពីម្សិលមិញ ឬក៏មុនម្សិលមិញទៅទៀតនោះ យើងត្រូវបានអនុញ្ញាតឲ្យផ្តល់យោបល់លើតម្លៃភស្តុតាងលើឯកសារគន្លឹះ។ យើងបកស្រាយពីម្សិលមិញនោះ ក្នុងន័យថា យើងក៏អាចនឹងផ្តល់នូវបរិបទទាក់ទងទៅនឹងទឡ្ហីករណ៍មួយចំនួនទៅលើឯកសារមួយចំនួននោះដែរ។ ប៉ុន្តែនៅក្នុងឱកាសមួយចំនួនពីម្សិលមិញ តុលាការមិនអនុញ្ញាតឲ្យយើងខ្ញុំធ្វើនូវបរិបទ ឬក៏ទឡ្ហីករណ៍ជាបរិបទទូលាយបានទេ។ ឥឡូវនេះ លោកចៅក្រមនិយាយថា ផ្អែកទៅលើការវាយតម្លៃទៅលើតម្លៃជាភស្តុតាងនោះ គឺដូចគ្នានឹងគំនិតនៃការសវនាការដេញដោលតទល់លើឯកសារនោះដែរ។ ប្រហែលជាខ្ញុំយល់ខុស ប៉ុន្តែហាក់ដូចជាតុលាការប្តូរទិសដៅមកដល់ពេលនេះ។

[១៤:៣១:១១]

តាមពិត គឺជាការតទល់ ប្រសិនបើតុលាការអនុញ្ញាតឲ្យយើងខ្ញុំលើកឡើងនូវសុន្ទរកថាលោក ចច ប៊ូស ទាក់ទងទៅនឹងការតាមរកប្រមាញ់ពួកអ្នកដែលគាត់ចាត់ថាជាខ្មាំងជាដើម ជាសត្រូវនោះ។ ប៉ុន្តែឥឡូវនេះ លោកចៅក្រមនិយាយថា សវនាការពីម្សិលមិញគឺថាមានន័យថាឲ្យលោកផ្តល់ទឡ្ហីករណ៍នៅតាមអត្ថន័យនៃការតទល់ដេញដោលគ្នានៅចំពោះមុខ។ មិនដូច្នោះទេ ពីព្រោះម្សិលមិញតុលាការមិនអនុញ្ញាតឲ្យធ្វើដូច្នោះ ឲ្យប្រើសេចក្តីដកស្រង់ពីប្រតិចារឹក ពីសាក្សីរស់មកបង្ហាញពីសក្ខីកម្មនោះទេ។ ហើយព្រឹកមិញនេះ គឺមេធាវីដៃគូរបស់ខ្ញុំ គាត់មិនអាចលើកឡើងអំពីទឡ្ហីករណ៍មួយដែលគាត់ថា គាត់យោងទៅរកសៀវភៅរបស់ចៅក្រម ឡឺម៉ុងដ៍ នោះ។ ដូច្នេះ ជាមតិយោបល់របស់យើង ខ្ញុំយល់ហើយពីនិយាយអំពីយោបល់ទៅលើតម្លៃភស្តុតាងហ្នឹង។

ឥឡូវនេះ លោកចៅក្រមនិយាយថា អាចនឹងធ្វើជាតាមបែបជាសវនាការចំពោះមុខតទល់បាន។ បាទ។ ដូច្នេះបើមានឱកាសនឹងធ្វើដូច្នោះបាន ខ្ញុំនឹងមានឱកាសជាថ្មីម្តងទៀត ដើម្បីនឹងធ្វើបែបនោះ។

[១៤:៣២:៣៣]

**លោក អាកឡូវ វែកគែន៖**

សូមអរគុណលោកប្រធាន។ ដើម្បីឲ្យទៅមុខ ហើយនិងដើម្បីឆ្លើយតបទៅនឹងសំណួរលោក

ចៅក្រម ឡាវែន៍ បន្តទៀត ខ្ញុំសូមអានសម្រង់មួយនៃសេចក្ដីនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងរឿងក្ដី អ៊ុតឆាឡាន់។ ខ្ញុំសូមដកស្រង់ មុននឹងដកស្រង់នេះ ខ្ញុំសូមកំណត់និយមន័យនៃសវនាការតទល់ គឺមានន័យថា ជនជាប់ចោទ ក៏ដូចជាខាងភាគីការពារក្ដីត្រូវតែដឹងអំពីការកត់សម្គាល់ ហើយនិងភស្តុតាងដែលម្ខាងទៀតបង្ហាញ ហើយនិងពិភាក្សាអំពីភស្តុតាងទាំងអស់នេះ។ ច្បាប់ជាតិអាចបំពេញលក្ខខណ្ឌតាមរបៀបផ្សេងៗ ក៏ប៉ុន្តែវិធិសាស្ត្រដែលធ្វើនោះ ត្រូវតែធ្វើយ៉ាងណាឲ្យភាគីការពារក្ដីទទួលបានលទ្ធភាពបានពិតប្រាកដក្នុងការធ្វើការការអត្ថាធិប្បាយអំពីបទចោទប្រកាន់។

[១៤:៣៣:៣៣]

យោង សេអឺដេអាស រឿងក្ដី អ៊ុតឆាឡាន់ លេខ 46.28199 កថាខណ្ឌ១៤៦។ អ៊ីចឹងពាក្យថាលទ្ធភាពពិតប្រាកដក្នុងការធ្វើការកត់សម្គាល់ទៅលើបទចោទ ការចោទប្រកាន់។ តើម្សិលមិញនេះ ហើយព្រឹកមិញនេះ តើយើងទទួល ឬក៏ក្រុម នួន ជា នេះ បានទទួលការអនុញ្ញាតក្នុងការធ្វើការកត់សម្គាល់លើភស្តុតាងនេះ ចោទប្រកាន់ទេ?

តើ៣ថ្ងៃកន្លងមកនេះ ភាគីការពារក្ដីនេះ ត្រូវបានហាមឃាត់មិនឲ្យនិយាយទេ ប៉ុន្មានថ្ងៃកន្លងផុតមកនេះ? ខ្ញុំ តាមខ្ញុំចាំគឺថាហៅ មានឃើញហៅលោក នួន ជា កាលពីសវនាការមុនៗនោះ គេអនុញ្ញាតឲ្យគាត់ឡើងមកធ្វើការកត់សម្គាល់ ប៉ុន្តែមេធាវីរបស់ពួកគាត់មិនមានសិទ្ធិធ្វើការកត់សម្គាល់អ្វីទេ។ នេះគឺជាចំណុចទី១។

ចំណុចទី២ គឺសំខាន់ណាស់ចំពោះខ្ញុំ គឺទាក់ទងទៅនឹងការពិភាក្សាតទល់អំពីភស្តុតាង។ កម្រិតទទួលបានដែលតុលាការយើងនេះកំណត់ចំពោះឯកសារដែលយកមកជម្រះសេចក្ដី គឺថាមានកម្រិតទាបណាស់ ទាបមែនទែនរហូតដល់ឯកសាររាប់ពាន់ត្រូវបានទទួល ហើយឥឡូវនេះតុលាការមិនទាន់ទាំងបានធ្វើការសម្រេចលើបញ្ហានេះផង ព្រោះកម្រិតនេះទាបពេក ហើយឯកសាររាប់ពាន់ត្រូវបានទទួលស្គាល់ ទទួលយក ហើយយើងមិនទាន់បានធ្វើការអត្ថាធិប្បាយលើឯកសារហ្នឹងផង ហើយឥឡូវនេះយើងព្យាយាមធ្វើការវិភាគលើឯកសារទាំងអស់ហ្នឹងទាំងដុំៗ ហើយដែលធ្វើមិនអាចធ្វើទៅបានដោយយោងទៅពេលវេលាដែលផ្ដល់ជូននោះវាតិចពេក។

[១៤:៣៥:៥៣]

ដូចលោកមេធាវី សុន អរុណ បានចង់លើកឡើងនិយាយអំពីយថាភាពនៃឯកសារកាលពីម្សិលមិញអ៊ីចឹង គេកាលណោះគេឆ្លើយប្រាប់គាត់ថា មិនមែនជាពេលវេលាត្រូវនិយាយពីរឿងហ្នឹងទេ។

ហើយបើអ៊ីចឹងបើលោកចង់និយាយពីយថាភាពនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ លោកទៅកន្លែងហ្នឹងខ្លួនឯងទៅ មើលឯកសារដើមខ្លួនឯងទៅ។

ហើយខ្ញុំសូមបញ្ចប់ជាចុងក្រោយ គ្រាន់តែសូមរំឭកថា ការផ្ដល់សក្ខីកម្មពីថ្ងៃទី០១ ដល់ទី០៦ កុម្ភៈ ឆ្នាំ២០១២ របស់លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនត្រឹមតែបានជំទាស់ក្នុងការបង្ហាញគឺថាកន្លែងដែលវត្ថុតាង ដែលមជ្ឈមណ្ឌលនេះមានទេ ហើយដែលវត្ថុតាងហ្នឹងយើងប្រើនៅទីនេះ។ ហើយគេថាវត្ថុតាងទាំងអស់នោះត្រូវរប៉ាត់រប៉ាយនៅក្នុងប្រទេសកម្ពុជា ហើយមាន -- ក៏ប៉ុន្តែមានឯកសារនៅទីនោះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា យើងឃើញថាឯកសារនេះជាឯកសារចម្លងទេ យើងនៅនេះៗ មានតែជាមៃក្រូហ្វីម។ អ៊ីចឹង ហើយហេតុអីក៏មជ្ឈមណ្ឌលនេះមិនព្រមផ្ដល់ឯកសារដើមឲ្យយើង។ លោកមេធាវី នួន ជា និយាយកាលពីម្សិលមិញ គេជំទាស់គាត់--

**ប្រធានអង្គជំនុំ៖**

បានហើយៗលោកមេធាវី!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:៣៧:៣៥]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយសង្ខេបទេ។ ខ្ញុំនឹងព្យាយាមលើកឡើងទឡ្ហីករណ៍ទៅតបទៅនឹងមេធាវីទាំងពីរក្រុម។ ដូច្នេះឧបសគ្គដែលអង្គជំនុំជម្រះជួបប្រទះនោះ គឺថាមេធាវីមកតុលាការដោយគាត់មិនបានត្រៀមរៀបចំខ្លួនឲ្យបានគ្រប់គ្រាន់ ហើយគាត់ចេះតែពង្រីកវិសាលភាពដែលគាត់លើកតាមអ្វីដែលគាត់ចង់បាន។ ប៉ុន្តែមិនមានផ្អែកទៅលើអង្គហេតុអ្វីដែលតុលាការតម្រូវនោះទេ។

ខ្ញុំសូមអនុញ្ញាតចាប់ផ្ដើមពីទឡ្ហីករណ៍របស់លោក កូប៉េ ជាមេធាវីការពារក្ដីនោះ។ ខ្ញុំគិតថាលោកមេធាវីនោះយល់ច្រឡំហើយពីបញ្ហាគោលការណ៍នៃការដេញដោលតទល់មុខនោះ ហើយបញ្ហាដែលទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះ ហើយនិងភាពពាក់ព័ន្ធនៃសំណើ។

ដូចដែលអង្គជំនុំជម្រះបានចង្អុលបង្ហាញនោះ។ មូលហេតុនោះគឺថាមិនអនុញ្ញាតទៅដែលថាគាត់ផ្ដល់ពេលវេលឲ្យលើកនូវសេចក្ដីសន្និដ្ឋានទូលំទូលាយទៅលើភស្តុតាងនោះទេ។ គាត់ត្រូវមានសម្រាប់សហព្រះរាជអាជ្ញាផងដែរ។

[១៤:៣៨:៤៩]

យើងទទួលបានការណែនាំឱ្យអានតែឯកសារពាក់ព័ន្ធ។ ដូច្នេះ តាមវិសាលភាពដែលអង្គជំនុំជម្រះណែនាំឱ្យយើងធ្វើថាលើកឡើងត្រឹមណា គឺថាយើងមានយុត្តិធម៌ស្មើភាពគ្នារវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី។ នេះហើយគឺជាគោលការណ៍អនុវត្តន៍ស្តង់ដារច្បាស់ដែលអង្គជំនុំជម្រះបានកំណត់នោះ។

ដូច្នេះខ្ញុំជម្រាបថា លោកមេធាវីហ្នឹងគឺយល់ច្រឡំទេ ដែលថាគាត់មិនអាចលើកពីសុន្ទរកថារបស់លោក ប៊ូស បានមានការរារាំង ប៉ុន្តែគំនិតនេះគឺខុសទេ គឺថាការដែលដេញដោលតទល់ហ្នឹង គឺថាគឺផ្អែកទៅលើការសម្រេចរបស់តុលាការថាលើកឡើងពីបញ្ហាណាដែលពាក់ព័ន្ធ ភស្តុតាងណាដែលពាក់ព័ន្ធ ហើយយើងមិនយល់ស្របទាល់តែសោះអំពីការអះអាងបែបនេះ។ រីឯកសារដេញដោលតទល់ទាក់ទងទៅនឹងការដាក់ឯកសារនេះ ចំពោះមេធាវីលោក ខៀវ សំផន ក៏ដូច្នោះដែរ ពួកគាត់បានទទួលឱកាស ប៉ុន្តែគាត់មិនប្រើឱកាសនោះទេ។

មូលហេតុមួយផ្សេងទៀត ដែលអង្គជំនុំជម្រះបញ្ជាក់ថាមេធាវីបានងាកឆ្ងាយពីវិសាលភាពនោះ គឺមេធាវីខ្លួនឯងហ្នឹងគាត់បានធ្វើសក្ខីកម្ម មិនបានពិភាក្សាតទល់ទៅលើភស្តុតាងដែលយើងដាក់នោះទេ។

បើនិយាយអំពីបញ្ហាការជំនុំជម្រះសិទ្ធិនៃការជំនុំជម្រះដោយយុត្តិធម៌វិញគឺថា គាត់បានងាកទៅរកការពិភាក្សាជាទូទៅដែលលើកឡើងពីគំនិតដែលថាមិនស្ថិតនៅក្នុងវិសាលភាព។ ការគោរពសិទ្ធិទទួលបានយុត្តិធម៌នេះគឺថាត្រូវបានគោរព។ ហើយយើងដាក់ឯកសារជាភស្តុតាង យើងបានកោះហៅសាក្សី តុលាការផ្តល់ឱ្យឱកាសស្មើគ្នាដូចនឹងសហព្រះរាជអាជ្ញាសួរនូវសាក្សីទាំងអស់។ ប៉ុន្តែគាត់ក៏ទទួលបានសិទ្ធិក្នុងការធ្វើសក្ខីកម្មនោះដែរ ហើយធានាថាឱ្យឯកសារទាំងអស់នោះបានបកប្រែ ហើយពេលវេលាដែលពួកគាត់ត្រូវបានទទួលសម្រាប់ការរៀបចំ។

[១៤:៤០:៥១]

ដូច្នេះគាត់បានទទួលសិទ្ធិក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌។ ដូច្នេះក្នុងដំណាក់កាលចុងក្រោយដែលមេធាវីប្តូរទិសដៅបែបនេះ ខ្ញុំយល់ឃើញថាគាត់មិនបានត្រៀមរៀបចំឱ្យបានគ្រប់គ្រាន់ក្នុងការឆ្លើយតបតទល់ទៅនឹងឯកសារគន្លឹះដែលយើងបានបង្ហាញទេ។ បើសិនជាអ្វីដែលគាត់អាចប្រើបាននោះ គាត់គ្រាន់តែទទួលស្គាល់ថា គាត់មិនបានប្រើឱកាស មិនបានត្រៀមខ្លួនរួចជាស្រេចនោះទេ។ អ្វីដែលគាត់អះអាង ហើយគាត់តវ៉ាទូលំទូលាយបែបនេះគឺគ្មានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់នោះទេ។

ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ សូមណែនាំឲ្យមេធាវីទាំងពីរក្រុមឆ្លើយតបទៅនឹងឯកសារគន្លឹះដែលសហព្រះរាជអាជ្ញាបានបង្ហាញ។ បើសិនជាគាត់មិនធ្វើដូច្នោះទេ ពួកគាត់ដូចជាមានការយល់ច្រឡំខ្លាំងហើយគាត់បានបំពានទៅលើយុត្តាធិការរបស់តុលាការនេះផងដែរ បើគាត់មិនគោរពតាមនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៣:២៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អង្គជំនុំជម្រះបានផ្តល់ពេលវេលាទៅភាគីការពារក្តីក្នុងការនូវឱកាសនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយទៅលើបណ្តាឯកសារគន្លឹះដែលបានដាក់ដោយភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសមស្របដោយមានការជូនដំណឹងជាមុនរួចហើយ ប៉ុន្តែមេធាវីការពារក្តីលោក ខៀវ សំផន មិនបានប្រើប្រាស់នូវពេលវេលាដែលបានបែងចែកឲ្យនេះឲ្យមានប្រសិទ្ធភាពក្នុងការដាក់បង្ហាញឯកសារទេ ហើយការសួរនាំអំពីថាតើតម្រូវការពេលវេលាបន្ថែមប៉ុន្មាន ដើម្បីសមស្របក្នុងការដាក់បង្ហាញឯកសារ ក៏មេធាវីការពារក្តីមិនបានឆ្លើយតបលើ និងបង្ហាញជំហរច្បាស់លាស់ក្នុងការត្រូវការពេលវេលានេះផងដែរ។ ហើយមិនមែនពេលនេះទេ គឺតាំងពីកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ កន្លងមកគឺអង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងចំណុចនេះដែរ ហើយមិនមានការឆ្លើយតប និងការស្នើសុំជាក់លាក់ទេ។

ដូច្នេះ ឥឡូវឃើញថា អង្គជំនុំជម្រះកំណត់ថា មេធាវីការពារក្តីលោក ខៀវ សំផន គឺសម្រេចមិនប្រើប្រាស់ពេលវេលាក្នុងការធ្វើអត្ថាធិប្បាយ ឬក៏ការធ្វើការកត់សម្គាល់ទៅលើបណ្តាឯកសារគន្លឹះដែលដាក់ដោយភាគីម្ខាងទៀតនោះឡើយ។

[១៤:៤៥:០០]

ហើយកិច្ចដំណើរការសវនាការក្នុងការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម ទម្រង់នៃការទទួលខុសត្រូវ តួនាទីរបស់ជនជាប់ចោទ និងបណ្តាឯកសារគន្លឹះផ្សេងទៀតដែលពាក់ព័ន្ធនឹងការដាក់បង្ហាញដោយភាគី សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកន្លងមកនេះ ឃើញថាបានចប់ហើយ។

ដូច្នេះ ហើយពេលវេលាសមស្របនឹងសម្រាកដែរ។ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី

ចាប់ពីពេលតទៅ រហូតដល់ម៉ោងបី ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅពេលដែលចូលត្រឡប់មកវិញនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាមដើម TCE-33 ដែលមានបានបម្រុងទុករួចហើយនៅអង្គជំនុំជម្រះសាលាដំបូង -- នៅក្នុងបរិវេណនៃ អ.វ.ត.ក យើងនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦នាទី ដល់ម៉ោង ១៥:០៥នាទី)*

[១៥:០៥:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាមដើម TCE-33។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[១៥:០៦:៣០]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:០៧:៣១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក ស្មីវ ហេងឆ័រ៖**

**ឆ៖** ខ្ញុំឈ្មោះ ស្មីវ ហេងឆ័រ យើងហៅថា ភី.អេច។

**ស៖** អរគុណលោក ស្មីវ ហេងឆ័រ។ ហើយតើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ឆ្នាំនេះខ្ញុំមានអាយុ ៦០ឆ្នាំហើយ។

**ស៖** បាទ អរគុណ។ ហើយតើសព្វថ្ងៃនេះ តើលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំជាអ្នកប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ។

**ស៖** បាទ អរគុណ។ ហើយតើលោក ស្ទីវ ហេដឌ័រ តើសព្វថ្ងៃនេះលោករស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំមាននិវេសនដ្ឋាននៅសហរដ្ឋអាមេរិក និងនៅចក្រភពអង់គ្លេស។ ខ្ញុំរស់នៅកន្លែងទាំងពីរ ហើយក៏មានការស្នាក់នៅកន្លែងដទៃទៀតផងដែរ។

**ស៖** បាទអរុណ តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំជាជនជាតិអាមេរិកាំង កាន់លិខិតឆ្លងដែនអាមេរិកាំង។

[១៥:០៩:១៨]

**ស៖** បាទ អរគុណ។ ហើយលោក ស្ទីវ ហេដឌ័រ តើឪពុកបង្កើតរបស់លោកឈ្មោះអី និងម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ រ៉ូប៊ីត ហេដឌ័រ ហើយម្ដាយខ្ញុំឈ្មោះ ប្រូទ្រីស៊័រ ម៉ៅវើ។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយាខ្ញុំឈ្មោះ ម៉ារីអ៊ែល រីល័រប៊ើក ខ្ញុំមានកូនស្រីពីរនាក់។

**ស៖** លោក ស្ទីវ ហេដឌ័រ ក្នុងនាមលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថទៅតាមជំនឿ ឬសាសនារបស់លោក តើលោកយល់ព្រមដែរឬទេ?

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការអន្តរជាតិ សូមឡើងណែនាំដល់លោកសាក្សីដើម្បីធ្វើសម្បថ មីរាម ម៉ាហ្វេសាន់ទិ! លោកស្រីក្រឡាបញ្ជីសូមណែនាំសាក្សីធ្វើសម្បថ!

[១៥:១១:១៤]

**ក្រឡាបញ្ជី៖**

លោក ហេដឌ័រ សូមលោកថាតាមខ្ញុំ៖ “ខ្ញុំសូមស្បថថា ខ្ញុំនិយាយតែការពិត ការពិតទាំងស្រុង គ្មានអ្វីដែលមិនមែនជាការពិតនោះទេ”។

**លោក ស៊ីវ ហេងឆ័រ៖**

ខ្ញុំសូមប្រកាសជាឱឡារិក គឺថាខ្ញុំប្រាប់ការពិតទាំងស្រុង គឺខ្ញុំនិយាយតែការពិតទាំងស្រុង គ្មានអ្វីក្រៅពីការពិតនោះឡើយ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោក ស៊ីវ ហេងឆ័រ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹងបាន លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០២ នេះទេ។ ហើយក៏មិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ សំផន។ តើពិតមែនដែរឬទេ?

[១៥:១២:១០]

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** បាទ ត្រឹមត្រូវហើយលោកប្រធាន។

**ស៖** ជាបន្តទៅនេះអង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក ក្នុងនាមលោកជាសាក្សី។ អំពីសិទ្ធិ លោក ស៊ីវ ហេងឆ័រ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលសុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សី ត្រូវតែផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ លោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែករណីដែលលោកប្រើសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយលោកលោកត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នៅព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

[១៥:១៣:២៣]

លោក ស៊ីវ ហេងឆ័រ តើលោកមានដែរធ្លាប់បានផ្តល់កិច្ចសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ នៅក្នុង

កិច្ចដំណើរការនៃតុលាការនេះក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ?

**ឆ៖** អត់ទេ ខ្ញុំអត់ដែលបានផ្ដល់កិច្ចសម្ភាសន៍ទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមរំឭកបញ្ជាក់ផងដែរថាសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេល ២ថ្ងៃកន្លះក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម ជម្រាបសួរដល់មេធាវីការពារក្ដីទាំងអស់ ហើយជាពិសេស គឺថាសូមជម្រាបសួរលោកបណ្ឌិត ហេដឌ័រ។ ខ្ញុំសប្បាយរីករាយណាស់ដែលជួបលោកនៅទីនេះ។ មនុស្សជាច្រើននៅតុលាការនេះ គឺថារង់ចាំវត្តមានរបស់លោក ហើយនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺថាលោកជាសាក្សី។ ខ្ញុំចង់ឲ្យលោកមានបង្កលក្ខណៈងាយស្រួលបន្តិចសិន គឺថាលោកមិនមែនជាសាក្សីជំនាញទេ នៅពេលនេះ។ ហើយខ្ញុំនឹងមិនសួរលោកឲ្យលោកបង្ហាញនូវគំនិតយោបល់ក្នុងឋានៈជាអ្នកជំនាញនោះទេ។ ហើយខ្ញុំបានការអនុញ្ញាតពីលោកប្រធាន គឺថាខ្ញុំនឹងគ្របដណ្ដប់ទៅលើសៀវភៅដែលលោកនិពន្ធ និងគ្របដណ្ដប់ទៅលើកិច្ចសម្ភាស ដែលលោកបានសម្ភាសជាមួយមនុស្សជាច្រើនក្នុងរយៈពេលជាឆ្នាំកន្លងមក។ ហើយគឺថាខ្ញុំនឹងធ្វើយ៉ាងម៉េចឲ្យការសួររបស់ខ្ញុំស្ថិតនៅក្នុងកម្រិតនេះឯង គឺថាត្រូវតែសាកសួរដោយមានការជ្រើសរើសបំផុត។ បើសិនណាជាខ្ញុំសួរលម្អិតនោះ ប្រហែលជាលោកត្រូវនៅទីនេះរហូតដល់ទៅ២សប្ដាហ៍ឯណោះ។

[១៥:១៥:៥៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** ដូច្នេះខ្ញុំសូមចាប់ផ្ដើមលោកសួរអំពីសំណួរពាក់ព័ន្ធទៅនឹងភូមិសាស្ត្រផ្សេងៗទៅនឹងប្រវត្តិ-រូប ថាតើលោកមានអនុបណ្ឌិតមកពីសាកលវិទ្យាល័យខូណែលមែនទេ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ជាការត្រឹមត្រូវហើយ ខ្ញុំមានទាំងកន្លែងទាំងពីរនេះឯង។

**ស៖** ដូច្នេះ ក្នុងពេលមួយនោះ លោកគឺជាសាស្ត្រាចារ្យផ្នែកខាងវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យឡុងដ៍ យើងហៅថាសាកលវិទ្យាល័យបូព៌ាប្រទេស និងអាហ្វ្រិក។ តើនេះជាការត្រឹមទេដែលលោកបានសម្គាសលើកំណត់សម្គាសឈ្មោះ វៃ ពេលដែលលោកធ្វើការនៅខាងផ្នែក *យូម៉ែន-រ៉ាយវ៉ថ?*

[១៥:១៦:៥៥]

**ឆ៖** បាទ ជនជាតិអង់គ្លេសផ្នែកខាងសាលាជាច្រើន គឺមិនជឿនៅក្នុងផ្នែកវិទ្យាសាស្ត្រនយោ-បាយនោះទេ។ គេគិតឃើញថា វាជាល្បិចកលរបស់ខាងផ្នែកអាមេរិកទេ។ ដូច្នេះនិយាយតាមន័យបច្ចេកទេស ខ្ញុំជាសាស្ត្រាចារ្យខាងផ្នែកវិទ្យាសាស្ត្រនយោបាយ និង -- វិទ្យាសាស្ត្រ និងនយោបាយនៅបូព៌ាប្រទេស និងអាហ្វ្រិក។ ហើយខ្ញុំមិនមែនធ្វើតែអ្នកសាស្ត្រាចារ្យ ក៏អ្នកសិក្សាស្រាវជ្រាវនៅផ្នែកខាងក្រៅនោះផងដែរ។ បាទ គឺថាខ្ញុំគឺជាអ្នកសិក្សាស្រាវជ្រាវផងដែរ។

**ស៖** តើត្រឹមត្រូវទេ ដែលកាលពីមុនលោកធ្វើជាអ្នកឆ្លើយឆ្លងសារព័ត៌មាននៅប្រទេសចិន ថៃ កម្ពុជា ឡាវ និងនៅតៃវ៉ាន់ សម្រាប់ទស្សនាវដ្ដីថាមស៍ សម្រាប់ទស្សនាវដ្ដីញូវស្វីក ហើយនិងវិទ្យុអ៊ិុន.ប៊ី.ស៊ី ហើយក្នុងនោះក៏គ្របដណ្ដប់មកលើប្រទេសកម្ពុជាក្នុងឋានៈលោកជាអ្នកសារព័ត៌មានចន្លោះពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ អ៊ីចឹងទេ?

[១៥:១៨:២០]

**ឆ៖** បាទ ទាំងអស់នេះគឺជាការត្រឹមត្រូវហើយ។ នេះគឺជាកិច្ចការជាអ្នកកាសែតដ៏ទូលំទូលាយរបស់ខ្ញុំនៅចន្លោះពីឆ្នាំ១៩៧៣ ទៅដល់៧៥។

**ស៖** តើវាត្រឹមត្រូវផងដែរទេ ជួយប្រាប់ខ្ញុំដល់ឆ្នាំផងបើសិនណាលោកអាចជួយបាន គឺថាពេលមួយនោះលោកធ្វើជានាយករងនៃអាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ដែលយើងហៅកាត់ថា អ៊ុនតាក់ គឺលោកធ្វើនៅខាងផ្នែកព័ត៌មាន និងអប់រំ អ៊ីចឹងទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវហើយ។ ប៉ុន្តែវាមានការពាក់ព័ន្ធទៅនឹងប្រព័ន្ធ យូ.អ៊ិន ក្នុងការថាខ្ញុំជានាយករង គឺថាតាមអត្ថន័យ យូ.អ៊ិន នោះជារឿងមួយផ្សេង។ ប៉ុន្តែចំណងជើងមិនបានប្រើប្រាស់ទេ ខ្ញុំគ្រាន់តែប្រើប្រាស់ចំណងជើងថា "ជាប្រធានផ្នែកវិភាគ និងផ្នែកវាយតម្លៃព័ត៌មាន និងអប់រំ"។

**ស៖** បាទ សូមអរគុណ។ តើវាត្រឹមត្រូវដែរទេ ដែលលោកទទួលរ៉ាប់រងសិក្សាស្រាវជ្រាវនៅតាមព្រំដែនកម្ពុជា-ថៃ និងនៅភ្នំពេញពីឆ្នាំ១៩៧៩ ដល់១៩៨៣ ក្នុងអ្នកដែលទទួលបានអាហារូបករណ៍

ផ្នែកការសិក្សានៅអាស៊ីដែល -- ពីសាកលវិទ្យាល័យ ជូឡាឡុងកន។

**ឆ៖** បាទ ជាការត្រឹមត្រូវហើយ ក្នុងអំឡុងពេលនោះ ខ្ញុំសិក្សាស្រាវជ្រាវ។ ក្នុងជាអ្នកទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យ ជូឡាឡុងកន អំពីខ្មែរក្រហម។ ពេលខ្មែរក្រហមស្ថិតនៅក្នុងអំណាចនៅឡើយ។ គឺទាក់ទងទៅនឹងខ្មែរក្រហម គឺក្នុងអំឡុងពេលយុត្តាធិការរបស់តុលាការនោះ។

**ស៖** តើត្រឹមត្រូវទេ ដែលលោកក៏ទទួលខុសត្រូវក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវទៅលើការសិក្សាជាក់លាក់មួយចំនួនពីសាកលវិទ្យាលអូស្ត្រាលីនោះ?

[១៥:២១:០១]

**ឆ៖** បាទ ខ្ញុំនៅក្នុងផ្នែកមួយដែលធ្វើកិច្ចខាងផ្នែកប្រវត្តិសាស្ត្រ។ គេមិនជឿខាងកិច្ចការវិទ្យាសាស្ត្រនយោបាយទេ។ ខ្ញុំជាអ្នកប្រវត្តិវិទូវិទ្យាសាស្ត្រនយោបាយ។ ដូច្នេះការសិក្សាស្រាវជ្រាវរបស់ខ្ញុំពេលនោះ គឺស្រាវជ្រាវអំពីខ្មែរក្រហម ក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់តុលាការនេះ។

**ស៖** តើត្រឹមត្រូវទេ ដែលថានៅក្នុងពេលខ្លះ ហើយជម្រាបខ្ញុំផង ក្រែងលោថ្មីៗលោកនៅធ្វើដដែល គឺថាលោកជាអ្នកពិគ្រោះយោបល់ទៅលើសិក្សាស្រាវជ្រាវផ្នែកខាងឧក្រិដ្ឋកម្មសង្គ្រាមនៅសាកលវិទ្យាល័យអាមេរិកាំងនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំស្តាប់ឮសំណួររបស់តំណាងសហព្រះរាជអាជ្ញាសួរជាសំណួរនាំមុខ អំពីប្រវត្តិរូបរបស់លោក ស្ទីវ ហេដឌ័រ ទាំងអស់។ កន្លងមកនេះ ហើយខ្ញុំមិនដឹងថា តើលោកតំណាងសហព្រះរាជអាជ្ញាប្រើឯកសារអី ដែលជាមូលដ្ឋានសម្រាប់ការតាំងសំណួរនាំមុខទាំងអស់នេះ? ដោយហេតុថាលោក ស្ទីវ ហេដឌ័រ គាត់មិនដែលបានធ្វើសម្ភាសជាមួយនឹងតុលាការនេះ ដូចជាចៅក្រមស៊ើបអង្កេតជាដើម គឺមិនដែលបានធ្វើការសម្ភាសទេ។ ដូច្នេះ ខ្ញុំសូមឲ្យលោកតំណាងសហព្រះរាជអាជ្ញាពីឯកសារដែលគាត់លើកឡើង បើសិនជាមានជាប់ពាក់ព័ន្ធតុលាការនេះ។ បើមិនអ៊ីចឹងទេ ខ្ញុំសូមជំទាស់ពីរបៀបតាំងសំណួរទាំងអស់នេះ។ សូមអរគុណ។

[១៥:២២:៥៧]

**លោក ឃីត រេយ៉ន៍ៈ**

ខ្ញុំជឿថា មេធាវីការពារក្ដីដឹងអំពីហ្គូហ្គលហើយ។ នេះគឺជាប្រភពគេហទំព័រនិយាយអំពីប្រវត្តិរូប ហើយខ្ញុំគិតថាឃើញថាគេហទំព័រ ហ្គូហ្គល នេះ គឺជាគេហទំព័រមួយត្រឹមត្រូវហើយ។ លោកប្រធាន ខ្ញុំសូមបន្តទៅទៀតបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឃីត រេយ៉ន៍ៈ**

**ស៖** លោក ហេដឌ័រ តើត្រឹមត្រូវដែរទេ? ហើយសូមជួយប្រាប់ឆ្នាំដល់ខ្ញុំផង ជួនកាលនិយាយពីពេលវេលាក្នុង ហ្គូហ្គល ហ្នឹង ឆ្នាំនោះគឺមិនអាចត្រឹមត្រូវទេ។

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** តើលោកមានបញ្ហាជាមួយក្បាលមីក្រូហ្វូនរបស់លោក? លោក ហេដឌ័រ ខ្ញុំមានសំណួរមួយទៀត គឺថាចង់បន្ថែមអ្វី ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំមិនដឹង ខ្ញុំឆ្លើយសំណួររបស់លោកអំពីឆ្នាំជាក់លាក់ណាមួយ ធ្វើការជាមួយអ៊ុនតាក់ គឺពីឆ្នាំ៩២ ទៅដល់៩៣។ ប៉ុន្តែទោះបីជាមានកិច្ចការបឋមខ្លះក្នុង ខ្ញុំធ្វើពីមុនជាមួយ *យូណាមិច* គឺយូណាមិចនៅក្នុង៩១ មុនអ៊ុនតាក់បន្តិចនោះ។

[១៥:២៤:១៨]

**ស៖** តើត្រឹមត្រូវទេ ដែលថាលោកក៏បំពេញការងារ ជួយប្រាប់ឆ្នាំផងបើខុស គឺក្នុងនាមជាអ្នកស៊ើបអង្កេត និងវិភាគនៅក្នុងការិយាល័យសហព្រះរាជអាជ្ញាតុលាការនេះ ហើយក្រោយមកធ្វើការជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រូវមានការបញ្ជាក់ខ្លះៗត្រង់ចំណុចនេះ។ ពីដើមមកគឺថាអង្គការសហប្រជាជាតិហ្នឹងគឺឲ្យផ្ដល់កិច្ចសន្យាខ្ញុំក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ និងជាអ្នកវិភាគនៅជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ គឺនៅពេលដែលបុគ្គលិកនៅការិយាល័យសហព្រះរាជអាជ្ញាគឺថាអត់ទាន់ មានប៉ុស្តិ៍អីនៅឡើយ កាលហ្នឹងសូន្យតែម្ដង។ គឺខ្ញុំបានទទួលកុងត្រាជាអ្នកវិភាគជាអ្នកសិក្សាស្រាវជ្រាវ និងជាអ្នកវិភាគព័ត៌មាន។ ទោះបីជាអង្គការសហប្រជាជាតិឲ្យ ជាធ្វើការជាមួយការិយាល័យសហចៅក្រម

ស៊ើបអង្កេតក្តីក៏មានកិច្ចព្រមព្រៀងរវាងចៅក្រម ឡឺម៉ុងដ៍ ហើយនឹងសហព្រះរាជអាជ្ញា រ៉ូប៊ឺត ពើទីត ពេលនោះ ដែលបានឲ្យខ្ញីខ្ញុំឲ្យទៅធ្វើការជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១៥:២៥:៥៧]

អ៊ីចឹងហើយ បានជាខ្ញុំទៅធ្វើការជាមួយការិយាល័យជាសហចៅក្រមស៊ើបអង្កេតដោយសារតែកិច្ចព្រមព្រៀងរវាងចៅក្រម ឡឺម៉ុងដ៍ និងសហព្រះរាជអាជ្ញា រ៉ូប៊ឺត ពើទីត។ អ៊ីចឹងនិយាយតាមន័យបច្ចេកទេសគឺខ្ញុំផ្តល់កិច្ចសន្យាទៅធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនដែលបានទទួលកិច្ចសន្យាធ្វើការជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញានោះទេ។ តែបានធ្វើការជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញាពីថ្ងៃដំបូងបំផុតដែលតុលាការនេះកកើតឡើង។ បើខ្ញុំចាំមិនច្រឡំទេគឺឆ្នាំ២០០៦។ ហើយខ្ញុំក៏សូមបន្ថែមផងដែរ ខ្ញុំធ្លាប់ធ្វើការជាមួយនឹងអង្គការសហប្រជាជាតិនៅសាលាក្តីនេះរយៈពេលប៉ុន្មានខែគឺនៅឆ្នាំ២០០៦ ក្នុងឋានៈជាអ្នកទីប្រឹក្សាឲ្យខាងផ្នែកអង្គការសហប្រជាជាតិ។

**ស៖** សូមអរគុណ គឺមិនមានការជំទាស់ទៅនឹងសំណួររបស់ខ្ញុំនោះទេ។ ប៉ុន្តែសូមលោកជួយបញ្ជាក់ផង ថាលោកធ្វើជាទីប្រឹក្សាឲ្យសិក្សាស្រាវជ្រាវផ្នែកខាងឧក្រិដ្ឋកម្មសង្គ្រាមនៅសាកលវិទ្យាល័យអាមេរិកាំងនោះ?

**ឆ៖** បាទ ខ្ញុំគិតថា ហ្នឹងក្នុងឆ្នាំ១៩៩៨ ឬក៏៩៩។ នេះជាឱកាសមួយដែលអាចឲ្យខ្ញុំបញ្ជាក់ផងដែរថា នោះគឺជាអំឡុងពេលមួយដែលខ្ញុំធ្វើការសរសេរទាក់ទងទៅនឹងការបោះពុម្ពផ្សាយសៀវភៅហៅថាបេក្ខជនទាំងប្រាំពីររូបប្រឈមនឹងការចោទប្រកាន់នោះ។ ហើយការសិក្សាស្រាវជ្រាវហ្នឹង ក្រោយមកខ្ញុំធ្វើការជាមួយខាងផ្នែកអង្គការសង្គមសេរីហៅថា *"អូភិន សូសាយអេតធី អ៊ីនទីស៊ីអេតធីវ"* ដែលមានថវិកាសម្រាប់ការសិក្សាស្រាវជ្រាវ។ ពេលនោះគឺថាតាមដែលខ្ញុំចាំ គឺថាសៀវភៅនេះក៏បានដាក់ ទៅក្នុងសំណុំរឿងផងដែរ។

[១៥:២៨:០៧]

**ស៖** សូមអរគុណ។ អ៊ីចឹងអាចឲ្យខ្ញុំសួរទៅឯកសារទាក់ទងបន្ទាប់ទៅទៀតនេះ។ ខ្ញុំបានរៀបចំឯកសារនៅទីនេះលោកប្រធាន ដែលបង្ហាញនូវឯកសារទាំងអស់ដែលលោក ហេដឌ័រ ជាអ្នកនិពន្ធដែលមាននៅក្នុងសំណុំរឿងហើយ ហើយក៏វាមាននៅក្នុងបញ្ជីអនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង។

ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញ ជាពិសេសសូមទោសចំពោះលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដោយសារមិនមានភាសាអង់គ្លេស។ ខ្ញុំសូមជូនឯកសារនេះជូនទៅតុលាការ។

**អ្នកបកប្រែ៖**

បាទ សូមទោស កែតម្រូវមានតែអង់គ្លេសអំបាញ់មិញ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមពន្យល់អំពីឯកសារនេះទៅចៅក្រម ខាតវ៉ាយថ៌ ជាសង្ខេបទេ ហើយសុំការអនុញ្ញាតពីលោកប្រធានដើម្បីចែកជូនឯកសារនេះ។ សៀវភៅនេះគឺសរសេរដោយលោក ហេដឌ័រ វាជាការជ្រើសរើសនូវសេចក្តីថ្លែងការណ៍ ដែលគាត់ជ្រើសរើសឡើងនៅពេលគាត់ធ្វើការជាមួយនឹងសាលានៅបូព៌ាប្រទេស និងអាហ្វ្រិកនោះ។ ហើយគាត់បានជ្រើសរើសធ្វើការសម្ភាសនេះ ពេលគាត់ធ្វើការនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជា។ កិច្ចសម្ភាសន៍គាត់សម្ភាសន៍ជាមួយ ខៀវ សំផន, កិច្ចសម្ភាសន៍ជាមួយ អៀង សារី, កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួននៅព្រំដែនកម្ពុជាថៃក្នុងទសវត្សរ៍៨០, កិច្ចសម្ភាសន៍ដែលគាត់ធ្វើពេលគាត់ធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត និងកិច្ចសម្ភាសន៍ដទៃៗទៀត។

[១៥:៣០:២០]

តើលោកស្រីចៅក្រម ខាតវ៉ាយថ៌ ថាតើឯកសារទាំងអស់នេះ គឺវាអាចនឹងជួយឲ្យចៅក្រមបានយល់ ក៏ដូចជាភាគីដទៃទៀតមានឯកសារយោង។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីចែកជូននូវឯកសារនេះ។ ខ្ញុំមានឯកសារនេះតែជាភាសាអង់គ្លេសទេ មិនទាន់បានបកប្រែជាភាសាខ្មែរនៅឡើយទេ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣១:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

អរគុណលោកប្រធាន។ ជាសំណួរបន្ថែម លោកសហព្រះរាជអាជ្ញា នេះបញ្ជីដែលសហព្រះរាជអាជ្ញាបានរៀបចំឡើង។ តើលោកបានចុះបញ្ជីឯកសារទាំងអស់នេះនៅក្នុងអ៊ីនធីហ្វេស ដែរឬទេ? ហើយចំណុចទី២ តើអាចមើលឃើញនៅក្នុងភាសាទាំងបីហ្នឹងអាចរកមើលឃើញដែរឬទេ?

**លោក ឃីត រេយ័ន័រ៖**

បាទ គឺថាខ្ញុំបានដាក់ចូលទៅក្នុងអ៊ីនធីហ្វេស។ សំណួរទី២ មានភាសាផ្សេងទៀត មានជាភាសាអង់គ្លេស ប៉ុន្តែមានភាសាខ្លះមានតែការបកប្រែមួយផ្នែកទេ ជាភាសាបារាំង ឬភាសាខ្មែរ។ ដូច្នេះខ្ញុំមិនអាចសន្យាជាមួយលោកស្រីចៅក្រមថាទំព័រនីមួយៗអាចនឹងមានជាភាសាបារាំង ឬភាសាខ្មែរនោះទេ។ ប៉ុន្តែភាគច្រើនគឺពិតជាមាន។ បទសម្ភាសន៍ទាំងអស់ គឺតាមពិតនោះគឺមានបីភាសា ហើយចម្លើយទាំងអស់ដែលយើងមាននោះគឺថា មួយដែលមានទាំងបីភាសានោះគឺសៀវភៅនិយាយពីលទ្ធិកុម្មុយនីស្តកម្ពុជា។ ប៉ុន្តែសៀវភៅ ឯកសារ និងបទសម្ភាសន៍ផ្សេងទៀត គឺមានជាបីផ្សេងនោះភាគច្រើន បាទ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៤:៣៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សំណួរមួយបន្ថែមទៀតទៅសហព្រះរាជអាជ្ញា តាមពិតតាមការដែលយើងពិនិត្យមើលឯកសារភាគច្រើនដែលបញ្ជាក់ពីលោក ហេនឌ័រ នេះ គឺថាឯកសារភាគច្រើននោះគឺមិនបានបកប្រែទៅជាខ្មែរទាំងស្រុងទេ។ ប៉ុន្តែការព្រួយបារម្ភរបស់យើងនោះគឺថា ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងយោងទៅរកផ្នែកដែលមិនត្រូវបានបកប្រែទេ ប្រសិនបើលោកធ្វើដូច្នោះ តើលោកត្រូវធ្វើសំណើឲ្យមានការបកប្រែទៅជាភាសាខ្មែរដែរឬទេ?

**លោក ឃីត រេយ័ន័រ៖**

ចៅក្រម ខាតវ៉ាយថ៍ ខ្ញុំសូមជម្រាបថា ខ្ញុំមិនទាន់បានធ្វើសំណើនោះទេ។ ខ្ញុំនឹងពន្យល់ពីមូលហេតុខ្ញុំៗបានត្រៀមរៀបចំសម្រាប់បណ្ឌិត ហេឌឌ័រ នេះគឺថាមានរយៈពេលខ្លី។ ខ្ញុំស្នើតែម្សិលមិញនេះឯង ពីសៀវភៅដែលនិយាយពីលទ្ធិកុម្មុយនីស្តនោះ។ ចំពោះសៀវភៅអំពីកាលៈទេសៈ ហ្វីលីព ស្សូត ហើយនិងនិយាយគឺថាមិនមានបកប្រែទាំងស្រុងនោះគឺថា ខ្ញុំមិនបានទាក់ទងទៅនឹងការបង្ហាញឯកសារ ដូច្នេះខ្ញុំបានដាក់សំណើសុំឲ្យបកប្រែបន្ទាប់ពីមានការបង្ហាញនូវឯកសារទាំងនោះតែប៉ុណ្ណោះ។

[១៥:៣៦:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៦:៤៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកបន្តដោយផ្អែកលើមូលដ្ឋានថា អាចនឹងមានការសម្រេចប្រឆាំងនឹងលោក ដោយផ្អែកលើមូលដ្ឋានដែលលោកស្វែងរកឲ្យមានការបកប្រែ ប៉ុន្តែយើងចង់ជម្រាបឲ្យច្បាស់ថា គឺថាមិនមែនទាំងអស់គ្នាយល់ជាភាសាអង់គ្លេសទាំងអស់ទេ ទោះបីមិនយល់ក៏ដោយគឺថាសូមឲ្យចៅក្រមគ្រប់រូបបានឯកសារទាំងអស់នេះ។

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំជូនទៅលោកស្រីចៅក្រមម្នាក់គឺថាមិនមែនមានន័យថា ខ្ញុំមិនចង់ជូនចៅក្រមផ្សេងទេ គឺខ្ញុំមាន ១៥ច្បាប់នៅទីនេះ ហើយខ្ញុំនឹងចែកជូនទៅមេធាវីការពារក្តី លោកចៅក្រម ហើយនិងភាគី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកចែកចាយដល់ចៅក្រម ហើយនិងភាគីពាក់ព័ន្ធនៃកច្ចដំណើរការនេះ!

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធាន ក៏ខ្ញុំសូមជូនមួយច្បាប់ទៅលោកបណ្ឌិត ហេងឌ័រ នោះផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៣៩:០៦]

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកបណ្ឌិត ហេងឌ័រ សូមលោកពិនិត្យមើលចំណងជើងនេះ ហើយខ្ញុំនឹងប្រើឯកសារនេះដើម្បីបញ្ជាក់ផ្ទៀងផ្ទាត់តែប៉ុណ្ណោះ ហើយយើងមើលទំព័រទី១១នៃឯកសារនេះ យើងឃើញចំណុចមួយ និយាយពីសៀវភៅ ហើយនិងរបាយការណ៍ដោយរូបលោក ប៉ុន្តែមិនដាក់ទាំងអស់ទេ។ តើលោកអាចបញ្ជាក់បានដែរឬទេថា លោកជាអ្នកនិពន្ធ ឬសហនិពន្ធពីសៀវភៅ ឬក៏របាយការណ៍ពីលេខ១ ដល់លេខ៥ នេះបាទ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ចំពោះលេខ៥, ៤ ហើយនិងលេខ៣ ខ្ញុំដឹងប្រាកដថា ចំណងជើង ហើយឯកសារនេះជាអ្វីច្បាស់លាស់ ហើយទី១ ក៏ខ្ញុំដឹងច្បាស់ដែរ។ លោកមិនទាន់បានផ្តល់អំពីការយោងជាកម្រិតបណ្ឌិតសភាទាំងស្រុងទេ។ ដូច្នេះ ខ្ញុំមានការលំបាកបន្តិចក្នុងការស្គាល់ ដែលថាឯកសារនេះនិយាយអំពីអ្វី ១, ៣, ៤ ហើយនិង៥ គឺជាស្នាដៃក្នុងន័យជាកម្រិតបណ្ឌិតសភានោះមែនពិត ហើយលេខ២នេះបើខ្ញុំមិនយល់ច្រឡំទេនោះ គឺមិនបោះពុម្ពផ្សាយជាកម្រិតបណ្ឌិតសភានោះទេ គឺជាអ្វីដែលត្រូវបានគេប្រើជាមូលដ្ឋាន ឬក៏ជាសេចក្តីព្រាងដែលនាំឲ្យមានការសរសេរជាអត្ថបទទី៣ ជាសៀវភៅដែលគេបោះពុម្ពផ្សាយជាកម្រិតបណ្ឌិតសភា។ ដូច្នេះ ខ្ញុំនិយាយអំពីចំណុចទាំងប្រាំនេះ។

[១៥:៤១:២០]

**ស៖** ខ្ញុំនឹងអានសម្រាប់កំណត់ត្រាតុលាការទី១ ឯកសារ E3/3169 គឺជារបាយការណ៍ដោយលោក ស្ទីវហ្វេន ហេដឌ័រ មានចំណងជើងថា "ប៉ុល ពត ហើយនិង ខៀវ សំផន"។

ឯកសារទី៣ គឺ E3/48 គឺជាសៀវភៅដោយ ស្ទីវហ្វេន ហេដឌ័រ និង ប្រាយអ៊ិន ធីធ័រម៉័រ មានចំណងជើងថា "បុគ្គលប្រាំពីររូបដែលត្រូវចោទប្រកាន់ ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៃខ្មែរក្រហម"។

ឯកសារទី៤ E190.1.398 នេះជារបាយការណ៍របស់ ស្ទីវហ្វេន ហេដឌ័រ មានចំណងជើង "ការវាយតម្លៃឡើងវិញនៃតួនាទីមេដឹកនាំជាន់ខ្ពស់ និងមន្ត្រីកម្ពុជាប្រជាធិបតេយ្យ និងបទឧក្រិដ្ឋ ហើយការទទួលខុសត្រូវរបស់កម្ពុជា ហើយនិងទស្សនៈវិស័យប្រៀបធៀប"។

លេខ៥ ឯកសារ ហើយនិងសៀវភៅគឺ E3/22 សៀវភៅសរសេរដោយ ស្ទីវហ្វេន ហេដឌ័រ មានចំណងជើងថា "លទ្ធិកុម្មុយនីស្តកម្ពុជា គំរូវៀតណាម ការត្រាបតាម ហើយនិងឯករាជ្យ ចាប់ពីឆ្នាំ១៩៣០ ដល់ ១៩៧៥"។ លោកបណ្ឌិត ហេដឌ័រ ខ្ញុំសូមចូលទៅដល់ប្រភេទបន្ទាប់ទៀតហ្នឹង-- ខ្ញុំឃើញថា លោកចង់ឆ្លើយ។

[១៥:៤២:៥៧]

**ឆ៖** ខ្ញុំមិនប្រាកដទាំងស្រុងអំពីចំណុចលេខ៤ នេះទេ ដោយហេតុថាវាមានឯកសារជាកាសែត ហើយវាមានការបោះពុម្ពផ្សាយ ហើយខ្លឹមសារនៅក្នុងសារព័ត៌មាននោះគឺវាវែងទូលាយជាងការបោះពុម្ពផ្សាយជាសៀវភៅ គឺគេសង្ខេបអំពីឯកសារនៅក្នុងសន្និសីទ ដូច្នេះវាខ្លីជាង។ ខ្ញុំមិនប្រាកដ ១០០ភាគ

រយថា តើណាមួយស្ថិតនៅក្នុងផ្នែកនេះទេ។ ខ្ញុំគិតថា នេះជាអត្ថបទពុំ -- បោះពុម្ពផ្សាយមិន មិនមែនជាឯកសារផ្អែកលើសន្និសីទនោះទេ។ ខ្ញុំចង់ឃើញឯកសារដើម្បីខ្ញុំអាចច្បាស់។

**ស៖** ខ្ញុំនឹងបង្ហាញជូន --

**លោក ឃីត វេយ្យ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាបង្ហាញឯកសារដែលនៅក្នុងសំណុំរឿង ដើម្បីឲ្យលោកផ្ទៀងផ្ទាត់ថា តើនេះជាស្នាដៃដែលបានបោះពុម្ពផ្សាយរបស់គាត់ផ្នែកណាមួយបាទ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:៤៤:១៩]

**សួរដោយលោក ឃីត វេយ្យ៍ន័រ៖**

**ស៖** ខ្ញុំសូមអនុញ្ញាត គឺឯកសារនៅក្នុងឯកសារ នៅក្នុងសំណុំរឿង គឺឯកសារ E190.1.398។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើការជំទាស់ ការប្រើពាក្យរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងលោកសាក្សីនេះ។ អ្វីដែលឃើញ -- ខ្ញុំក្រោកឈរនេះ អាចថាការជំទាស់នោះមិនសូវល្អាសវៃសោះ ក៏ប៉ុន្តែយើងមានឃើញមានថា ទាក់ទងនឹងគោលការណ៍ដ៏សំខាន់លោក ស្ទីវហ្វេន ហេដឌ័រ គាត់អញ្ជើញមកក្នុងឋានៈជាសាក្សី ត្រូវបានកោះអញ្ជើញពីដំបូងជាអ្នកជំនាញទេ។ គាត់មិនចង់ធ្វើជាអ្នកជំនាញ នេះជាមូលហេតុរបស់គាត់ យើងជាប្រធានបទដែលនឹងខ្ញុំនឹងសួរ។ ប៉ុន្តែឥឡូវនេះគាត់អញ្ជើញមកក្នុងឋានៈជាសាក្សី។ ប៉ុន្តែយើងឃើញថា សហព្រះរាជអាជ្ញាលោកហៅគាត់ថាជា "លោកសាក្សី" មិនគួរហៅគាត់ថា "បណ្ឌិត" នោះទេ។ ប៉ុន្តែការប្រើពាក្យនេះលោកអាចនឹងគិតថា ខ្ញុំធ្វើហ្នឹងដូចជាល្ងង់ពេក។ ក៏ប៉ុន្តែគាត់ជាសាក្សី គឺថាតាមច្បាប់របស់តុលាការ គឺថាយើងមិនហៅសាក្សីទៅតាមឋានៈជាបណ្ឌិតសភាររបស់គាត់ទេ ហៅគាត់ត្រឹមជាធម្មតា ហៅថា "លោកសាក្សី" ឬក៏លោក "ហេដឌ័រ" មិនត្រូវហៅគាត់ថា "បណ្ឌិត" នោះទេ។

[១៥:៤៦:០៥]

**លោក ឃីត រេយ៉ន័រ៖**

ខ្ញុំគិតថា ការជំទាស់នេះដូចជាលក្ខណៈកូនក្មេង។ ប៉ុន្តែខ្ញុំលើក ខ្ញុំធ្វើជាអនុសេនីយ៍ឯកនៅកងនាវាអង់គ្លេសនោះក៏គេហៅខ្ញុំបែបនោះដែរ។ ខ្ញុំមិនដែលហៅថាគេហៅខ្ញុំអ៊ីចឹងខុសទេ។ បាទ ស៊្មីហ្វេន ហេដឌ័រ គាត់ជាបណ្ឌិត នេះគឺជាគុណវុឌ្ឍិនៃការសិក្សារបស់គាត់។ បើសិនជាគាត់ជាឧត្តមសេនីយ៍ទោក៏ត្រូវហៅអ៊ីចឹងទៅតាមហ្នឹង។ អ៊ីចឹងហើយគឺយើងមានសេរីភាពក្នុងការឲ្យគេហៅគាត់ឋានៈរបស់យើង។ បាទ អ៊ីចឹងគឺយើងត្រូវហៅគាត់ទៅតាមឋានៈអ្វីដែលគាត់ទទួលបាន ដែលគាត់មាននោះឯង។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៧:២៤]

**ប្រធានអង្គជំនុំ៖**

បាទ ទំនងជាមិនមានបញ្ហាអីធំដុំទេ ប៉ុន្តែដោយសារមានការជំទាស់ហើយ គប្បីប្រើប្រាស់ត្រឹមកម្រិតជាសាក្សីទៅ។ ហៅគាត់ជា “សាក្សី” ទៅជាការសមស្រប ហើយសម្រួលបញ្ហានេះឲ្យបានរលូន និងឆាប់ដំណើរការឆាប់បានទៅមុខផង។

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលឯកសារនេះ ដែលខ្ញុំជូនទៅលោក ហើយខ្ញុំនឹងសួរសំណួរ គឺឯកសារ E190.1.398 គឺជាអត្ថបទជាភាសាអង់គ្លេសបាទ។

[១៥:៤៨:២៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ នេះពិតហើយគឺជាអត្ថបទដែលខ្ញុំបានកែសម្រួល។

**ស៖** ខ្ញុំនឹងសួរលោកបន្តទៅទៀត ដើម្បីឲ្យធ្វើការផ្ទៀងផ្ទាត់បញ្ជាក់។ ឥឡូវយើងមើលលេខឯកសារ ដែលយើងបញ្ជាក់ជូនគឺនៅទំព័រទី១ គឺចំណងនៅត្រង់ចំណុចដែលនិយាយថា “ពីសាលាសិក្សាអាហ្វ្រិក និងបូព៌ាប្រទេស”។ យើងមានឯកសារពីលេខ៦ រហូតទៅដល់ឯកសារ៥៧ ដោយរាប់បញ្ចូលទាំងដែលជា មានចម្លើយសារភាពមួយចំនួនដែលលោកបានសម្ភាសជាមួយសាក្សី ទាក់ទងនឹងកាលបរិច្ឆេទដែលពាក់ព័ន្ធ។ ខ្ញុំសួរថា តើលោកនៅកម្ពុជាដែរឬទេ ជាមួយស្ថាប័ន អេស.អូ.អេ.អេស ឬក៏ អេច.អ័រ.ដាប់ប៊ែលយូ ហ្នឹងនៅពេលដំណាក់កាល និងកាលបរិច្ឆេទទាំងអស់នោះ?

**ឆ៖** បាទ។

**ស៖** តើដោយសារលោកមានពេលខ្លី តើលោកអាចបញ្ជាក់ថាលោកពិតជាបានសម្ភាស និងកត់ត្រាចម្លើយទាំងអស់ហ្នឹងទេ បទសម្ភាសន៍ទាំងអស់ហ្នឹងទេ?

**ឆ៖** កាលបរិច្ឆេទ ខ្ញុំនៅចាំ នៅនឹកឃើញ។ ខ្ញុំពិនិត្យដំបូងគឺថាយើងឃើញឈ្មោះភាគច្រើន ក៏ខ្ញុំនៅស្គាល់ ចាំបានមួយចំនួន ប៉ុនដោយឈ្មោះត្រង់ ខ្ញុំមិនស្គាល់ឈ្មោះទាំងអស់ភ្លាមៗនោះទេ។ ប៉ុន្តែមានលក្ខណៈពិសេសដែលឈ្មោះទាំងអស់នោះ ដែលអាចនឹងសរសេរចេញជាឈ្មោះដែលប្រាប់ខ្ញុំថា ខ្ញុំគឺជាអ្នកធ្វើសរសេរឈ្មោះហ្នឹងទៅជាអង់គ្លេស បានសម្ភាសអ្នកទាំងនោះ។

[១៥:៥០:៥១]

**ស៖** តើមានអ្នកណាម្នាក់មកពីសាលា អេស.អូ.អេ.អេស ដែលធ្វើបទសម្ភាសន៍ក្រៅពីលោកដែរឬទេ ក្នុងអំឡុងពេលទាំងអស់នោះ?

**ឆ៖** នេះប្រហែលជានឹងត្រូវមានការពន្យល់ថាតើការសិក្សាបែបបណ្ឌិតសភានោះ ត្រូវធ្វើដូចម្តេច? ជាពិសេសពីវិធីដែលគេផ្តល់មូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ការសិក្សានេះ គឺផ្តល់មូលនិធិដោយលុយមកពី គឺវិទ្យាស្ថានហៅថា *"អូភិន សូសាយអេតធី"* បន្ទាប់ពីនោះមក គឺមិនគប្បីមានការច្រឡំជាមួយ -- មួយទៀត គំនិតផ្តួចផ្តើម *"អូភិន សូសាយអេតធី អ៊ីនទីស៊ីអេតធីវ"* ដែលជាអង្គការមួយផ្សេងដាច់ដោយឡែកទេ។ របៀបដែលការងារធម្មតានៅក្នុងស្ថាប័ន វិទ្យាស្ថានកម្រិតបណ្ឌិតសភានេះ គឺថាជាអង្គការផ្តល់មូលនិធិ ផ្តល់នូវថវិកាទៅឲ្យទៅនិយោជកដែលជាបណ្ឌិតសភាដើម្បីឲ្យអនុវត្តនូវការងារកម្រិតបណ្ឌិតសភា ដែលរៀបទាំងការបង្រៀនផងដែរ។ ហើយគេអាចនឹងឲ្យគ្រូចេញពីការបង្រៀនដើរទៅខាងក្រៅ ធ្វើការស្រាវជ្រាវក្រៅសាលារៀន។ សាកលវិទ្យាល័យតែងតែកាត់យកមូលនិធិមួយចំនួន ប៉ុន្តែយើងផ្អែកទៅលើប្រាក់ខែនៅក្នុងសាកលវិទ្យាល័យ ប៉ុន្តែលុយដែលចាយនោះ មិនចូលទៅហោប៉ៅអ្នកធ្វើការងារនោះទេ។

[១៥:៥៣:០១]

នេះយើងមានថវិកាបន្ថែមដែលបន្ថែមឲ្យសាកលវិទ្យាល័យ គឺពីមកដល់សាកលវិទ្យាល័យដែលហៅថា"សូអាស"(SOAS)នេះឯង ដើម្បីឲ្យមនុស្សមួយចំនួនដែលធ្វើការជាមួយខ្ញុំក្នុងការធ្វើបទសម្ភាសន៍ដែលអ្នកទាំងអស់នោះក៏ទទួលការបង់ប្រាក់ដោយ សូអាស។ ប៉ុន្តែគេមិនមែននិយោជិករបស់សាលាសិក្សាអាហ្វ្រិក និងបូព៌ាប្រទេសនោះទេ។ អានេះហើយជាដំណើរការ។

**ស៖** តើលោកបានមកប្រទេសកម្ពុជាក្នុងឆ្នាំ២០០៥ហ្នឹង ក្នុងការធ្វើការសម្ភាសក្នុងឋានៈជាអ្នក

ស្រាវជ្រាវរបស់ សូអាស ហ្នឹងរយៈពេលប៉ុន្មាន?

**ឆ៖** តាមដែលខ្ញុំចាំគឺថាគឺជារយៈពេលវែងជាងដែលបានបញ្ជាក់នៅលើបញ្ជីនេះ។ ប៉ុន្តែប្រហែលជាមិនអ៊ីចឹងទេ ប៉ុន្តែអ្វីដែលបានធ្វើនោះ គឺនៅដើមឆ្នាំ២០០៥ មានការសិក្សាមួយដែលបានធ្វើឡើងដោយប្រើមូលនិធិដដែលហ្នឹង ប៉ុន្តែមិនបានពាក់ព័ន្ធក្នុងការសម្ភាសទេ ប៉ុន្តែគេពិនិត្យមើលឯកសារទាំងឡាយ។ ហើយការថវិកាសម្រាប់សិក្សាស្រាវជ្រាវរួមនោះ គឺថាគ្របដណ្ដប់ទៅលើភាគមួយចំនួន មិនក្នុងឆ្នាំសារពើពន្ធ ឆ្នាំ២០០៥ទាំងមូលនោះទេ។ ប៉ុន្តែគឺមានផ្នែកមួយគឺថាគេធ្វើការងារពិនិត្យឯកសារនៅក្នុងដើមឆ្នាំ។ ប៉ុន្តែកម្ពុជាយើងគឺថាស្ទើរតែពេញ១ឆ្នាំ ២០០៥ ប៉ុន្តែការសម្ភាសធ្វើពាក់កណ្ដាលឆ្នាំចុងក្រោយ។

[១៥:៥៥:០៨]

**ស៖** តើលោកជាអ្នកដឹកនាំគម្រោងហ្នឹង ឬក៏អ្នកណាផ្សេង?

**ឆ៖** ខ្ញុំគិតថា ខ្ញុំជាអ្នកដឹកនាំ។

**ស៖** ឥឡូវនេះខ្ញុំមើលទៅទំព័រទី៤ នៅក្នុងឯកសារនេះ យើងនៅខាងលើឃើញដាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា។ ចម្លើយនៅទីនេះគឺថាមានបទសម្ភាសន៍ អ៊ុក ប៊ុនឈឿន រហូតដល់ខែ កញ្ញា ឆ្នាំ២០០៥ គឺមានបទសម្ភាសន៍របស់បុគ្គលមួយចំនួន។ ថាតើលោកអាចជម្រាបបានទេតើបទសម្ភាសន៍ដែលលោកធ្វើការនៅជាមួយ ឌី.ស៊ី.ខេម នៅពេលនោះគឺមានលក្ខណៈដូចម្ដេច?

**ឆ៖** ខ្ញុំពិនិត្យឃើញថាឯកសារមួយចំនួន គឺអាចធ្វើឲ្យមានការភាន់ច្រឡំបន្តិច។ ការរៀបចំការងារដែលខ្ញុំធ្វើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានោះគឺភាគច្រើនក្នុងឆ្នាំ២០០៤។ បាទគឺក្នុងរបៀបមួយខុសពីមុនដែលខ្ញុំនិយាយ។ គឺថាលុយនោះគឺថាគេឲ្យមកខាងមកពីស្ថានទូតអង់គ្លេសនៅភ្នំពេញទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងមានការរៀបចំផ្សេងទៀតដែលគេបង់ទៅឲ្យសាកលវិទ្យាល័យរបស់ខ្ញុំដើម្បីឲ្យសាលាហ្នឹងអនុញ្ញាតឲ្យខ្ញុំធ្វើការងារស្រាវជ្រាវជំនួសឲ្យការបង្រៀន។ គម្រោងនេះគឺមានជាបឋមនោះ គឺការពិនិត្យមើលបទសម្ភាសន៍ដែលគេធ្វើពីមុនមកគឺដោយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនធ្វើឡើងដោយខ្ញុំ ហើយដែលខ្ញុំមើលទៅ ខ្ញុំសង្ខេបទៅជាភាសាអង់គ្លេស ហើយចងក្រងទៅជាសេចក្ដីសង្ខេបជាមួយចំនួនច្រើនគឺថា ចំណុចមួយចំនួននៅទីនេះគឺថាគឺគេត្រូវបានចងក្រងមកពេលក្រោយទេក្នុងឆ្នាំ២០០៥ ដែលខ្ញុំនិយាយថា ខ្ញុំអាចនឹងធ្វើការសម្ភាសជាច្រើននៅពេល -- សង្ខេបជាច្រើននៅពេលដែលមុននឹងមានការងារក្នុងឆ្នាំ២០០៥នេះ។ ពេលខ្លះគឺវាមិនចូលទៅក្នុងការពន្យល់នោះទេ។

[១៥:៥៨:១០]

ជាឧទាហរណ៍ នៅក្នុងលេខ៦៥ នេះឯកសារ E3/387 ដែលជាឯកសារ D210/5 មិនមែនជាបទសម្ភាសន៍ដែលខ្ញុំធ្វើ ដែលពាក់ព័ន្ធទៅនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាទេ គឺបទសម្ភាសន៍ដែលខ្ញុំបានធ្វើនៅធ្វើការឱ្យសាកលវិទ្យាល័យអូស្ត្រាលី ប្រតិចារឹកនេះខ្ញុំបានផ្តល់ទៅឱ្យ ឌី.ស៊ី.ខេម ហើយដូច្នេះ ហើយយើងឃើញថាអាចទៅចូលប្រព័ន្ធរបស់លោកទៅជាសំណុំរឿងគេយល់ថា ជាឯកសាររបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា។ ខ្ញុំក៏មិនសូវច្បាស់ទៅលើឯកសារ៥៩ ដែលមាននៅក្នុងឆ្នាំ១៩៩៩។ ឈ្មោះនេះ គឺខ្ញុំឃើញខ្ញុំមិនស្គាល់ភ្លាមទេ ខ្ញុំឆ្លល់ថាគឺអាចជាបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនជាកាលបរិច្ឆេទដែលខ្ញុំធ្វើនោះទេ។

កាលបរិច្ឆេទផ្សេងៗទៀតគឺថា បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនមែន ជាកាលបរិច្ឆេទដែលខ្ញុំបានកែសម្រួលទេ គឺថាអាចហ្នឹងនៅក្នុង៦៤ គឺថាកាលបរិច្ឆេទឆ្នាំ២០០៤ ប៉ុន្តែខ្ញុំបានកែសម្រួលនៅឆ្នាំ២០០៥ គឺថាអាច អ៊ីចឹងគឺថានឹងច្រឡំ គឺថាខ្ញុំធ្វើការកែសម្រួលទេឆ្នាំ២០០៥ ប៉ុន្តែខ្ញុំមិនបានធ្វើសម្ភាសទេ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងនិយាយអំពីបទសម្ភាសន៍នីមួយៗ គឺខ្ញុំនឹងសូមអនុញ្ញាតពីប្រធានចៅក្រម ដើម្បីបង្ហាញជូនលោកដើម្បីសួរបញ្ជាក់។ ចូលទៅដល់ប្រធានបទមួយទៀត--

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំមើលម៉ោងទៅឃើញថា យើងម៉ោងបួនទៅហើយ។ តើអនុញ្ញាតឱ្យខ្ញុំបន្ត ឬលោកប្រធានពិចារណាយ៉ាងដូចម្តេច?

[១៦:០០:២១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បើខ្ញុំឮថាអ្នកបកប្រែនិយាយអម្បាញ់មិញ គាត់ថានៅពេលដែលលោក ស្ទីវ ហេដឌ័រ និយាយនោះផ្តល់សក្ខីកម្ម សុំឱ្យឃ្លាតឆ្ងាយពីមីក្រូបន្តិច ពីព្រោះកាលណានៅកៀកពេក ធ្វើឱ្យដាច់សំឡេងហើយធ្វើឱ្យអ្នកបកប្រែពិបាកបកប្រែ។ អ៊ីចឹងសូមឱ្យគាត់ឃ្លាតឆ្ងាយពីមីក្រូបន្តិច ដើម្បីសម្រួលដល់ការងារបកប្រែ។ សូមអរគុណ។

[១៦:០០:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយអរគុណលោក ស៊្វីរ ហេងឆ័រ។ អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ កិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១០ ខែកក្កដា ឆ្នាំ២០១៣។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊្វីរ ហេងឆ័រ ដែលនឹងបន្តសួរដេញដោលដោយភាគីសហព្រះរាជអាជ្ញា។ សូមភាគីនៃរឿងក្តី មន្ត្រីបុគ្គលិកគាំទ្រកិច្ច-ដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

លោក ស៊្វីរ ហេងឆ័រ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះត្រឡប់ទៅកាន់ទីកន្លែងដែលស្នាក់នៅវិញចុះ។ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក វេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំមកត្រឹមបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការនេះ ដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*